ឆ្នាំនៃជំនឿ ២០១២ ២០១៣

# យើងរួមរស់ជា
# ព្រះសហគមន៍
## ២០១៣





# ធម៌ប្រកាសជំនឿរបស់គ្រីស្តបរិស័ទទាំងឡាយ

## (ជាសេចក្តីប្រកាសបុរាណជាងគេនៃព្រះសហគមន៍ក្រុងរ៉ូម)

-ខ្ញុំជឿព្រះបិតា ដ៏មានតេជានុភាពសព្វប្រការ ជាព្រះបង្កើតមេឃ និងដី។

-ខ្ញុំជឿព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាតែមួយនៃព្រះបិតា ហើយជាអម្ចាស់យើងខ្ញុំ។ ព្រះអង្គចាប់កំណើតជាមនុស្ស ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ហើយទ្រង់បានប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី ព្រះអង្គបានសោយទុក្ខលំបាកនៅជំនាន់លោក ប៉ុនពីឡាត។ ព្រះអង្គត្រូវគេឆ្កាងសោយព្រះទិវង្គត ហើយព្រះសពព្រះអង្គត្រូវគេបញ្ចុះក្នុងរូងថ្មមួយ។ ព្រះអង្គបានយាងចុះទៅស្ថានក្រោម លុះដល់ថ្ងៃទី៣ ទ្រង់មានព្រះជន្មរស់ឡើងវិញ រួចព្រះអង្គបានយាងឡើងស្ថានបរមសុខ ទៅគង់ខាងស្តាំព្រះបិតាដ៏មានតេជានុភាពសព្វប្រការ។ ព្រះអង្គនិងយាងមកវិញ ដើម្បីកាត់ក្តីបាបកុសលឲ្យមនុស្សទាំងរស់ទាំងស្លាប់។

-ខ្ញុំជឿព្រះវិញ្ញាណដ៏វិសុទ្ធ ខ្ញុំជឿព្រះសហគមន៍កាតូលិក និងសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ ខ្ញុំជឿថាមានការលើកលែងទោសរំដោះបាប ហើយរូបកាយមនុស្សនឹងរស់ឡើងវិញ ព្រមទាំងមានជីវិតរស់នៅអស់កល្បជានិច្ចផង។ អាម៉ែន។

យើងរួមរស់ជា

# ព្រះសហគមន៍

២០១៣



"ព្រះគ្រីស្តជាពន្លឺបំភ្លឺប្រជាជាតិនានា។ ព្រះវិញ្ញាណដ៏វិសុទ្ធបានប្រជុំមហាសន្និបាតដ៏វិសុទ្ធនេះ ដែលប្រាថ្នាយ៉ាងខ្លាំងចង់ផ្សព្វផ្សាយពន្លឺរបស់ព្រះគ្រីស្តទៅលើមនុស្សទាំងអស់ គឺជាពន្លឺដែលចែងចាំងលើមុខព្រះសហគមន៍ ដោយប្រកាសដំណឹងល្អឲ្យសត្វលោកទាំងឡាយ (**Lumen Gentium 1**)"

បងប្អូនជាទីស្រឡាញ់!

ល្ងាចថ្ងៃសៅរ៍ ខ្ញុំបានចូលរួមក្នុងពិធីតាំងព្រះកាយព្រះគ្រីស្ត។ ពេលនោះ មានគ្នាប្រហែលជាង៥០នាក់ ទាំងចាស់ទាំងក្មេង គ្រីស្តបរិស័ទផង អ្នកស្វែងយល់ផង អ្នកពិការ អ្នកជំងឺ ពុទ្ធបរិស័ទដែលចង់ដឹងចង់ស្គាល់ បព្វជិតបព្វជិតា លោកបូជាចារ្យម្នាក់ និងលោកអភិបាលរបស់បងប្អូនផងដែរ។ យើងទាំងអស់គ្នាអង្គុយស្រួលបួលជាមួយព្រះយេស៊ូជាព្រះអម្ចាស់ និងជាគង្វាលរបស់យើង។

នៅពេលដែលខ្ញុំសម្លឹងមើលព្រះកាយព្រះគ្រីស្ត ខ្ញុំបានប្រាប់ខ្លួនឯងថា "ល្ងាចនេះ ខ្ញុំឃើញព្រះសហគមន៍ គឺព្រះសហគមន៍ដែលព្រះយេស៊ូសព្វព្រះហឫទ័យ ជាព្រះសហគមន៍ដែលតាំងពី ២០០០ឆ្នាំមកហើយ ប្រកាសដំណឹងល្អដល់ជនក្រីក្រ។

ខ្ញុំបានឃើញព្រះសហគមន៍ជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដែលរួមជាមួយគ្នាជាធ្លុងតែមួយ រួមជាមួយព្រះយេស៊ូផងដែរ។

ខ្ញុំបានឃើញព្រះសហគមន៍ជាព្រះកាយព្រះគ្រីស្ត ដែលថ្វាយសុខទុក្ខទៅព្រះអង្គ និងទទួលស្នាព្រះហស្តដ៏អស្ចារ្យ

របស់ព្រះជាម្ចាស់។

ខ្ញុំបានឃើញព្រះសហគមន៍ជាអ្នកបម្រើដ៏ក្រីក្រ ដែលលុតជង្គង់ចំពោះព្រះរបស់ខ្លួន ដើម្បីបម្រើឲ្យបានល្អ អ្នកតូចតាចដែលត្រូវគេប្រមាថក្នុងសង្គមយើង។

ជាមួយបងស្រីថេរេសានៃទីក្រុងលីស៊ីយើ ខ្ញុំបានសួរខ្លួនឯងថា តើយើងម្នាក់ៗអាចចូលរួមក្នុងព្រះសហគមន៍នេះ ដែលត្រាស់ហៅយើងឲ្យទៅជាសន្តៈសន្តីបុគ្គលយ៉ាងដូចម្ដេច?

ខ្ញុំបានបែរមុខទៅរករូបចម្លាក់របស់ព្រះនាងព្រហ្មចារិនីម៉ារី ដែលញញឹមរាក់ទាក់យើង ទាំងផ្ដល់បុត្ររបស់ព្រះនាងឲ្យយើង។ ព្រះនាងម៉ារី ដែលជាមាតារបស់ព្រះសហគមន៍ និងជាគំរូសម្រាប់ព្រះសហគមន៍ មានសូរសៀងមកខ្ញុំថា ចូរទាំងអស់គ្នាដើរទៅមុខ ឆ្ពោះទៅព្រះយេស៊ូដែលជាព្រះពន្លឺរបស់ប្រជាជាតិនានា!

នៅឆ្នាំនេះ ព្រះសហគមន៍រំឭកខួប៥០ឆ្នាំនៃមហាសន្និបាតវ៉ាទីកង់ទីពីរ និងខួប២០ឆ្នាំនៃការបោះពុម្ពសៀវភៅស្ដីអំពីលទ្ធិនៃគ្រីស្តសាសនា តាមព្រះសហគមន៍កាតូលិក។ សម្ដេចប៉ាបអញ្ជើញយើងឲ្យឧទ្ទិសឆ្នាំនេះចំពោះជំនឿ ឯខ្ញុំវិញ ខ្ញុំអញ្ជើញបងប្អូនឲ្យរិះគិតអំពីអាថ៌កំបាំងនៃព្រះសហគមន៍។

អស់រយៈពេលមួយឆ្នាំ កូនសៀវភៅនេះនឹងជួយយើងឲ្យពិចារណាអំពីព្រះសហគមន៍ ជាព្រះសហគមន៍របស់យើង ហើយអំពីមុខងាររបស់យើងក្នុងព្រះសហគមន៍។

កូនសៀវភៅនេះចែកជា ៤ វគ្គគឺៈ

*១- គម្រោងការដ៏អស្ចារ្យរបស់ព្រះសហគមន៍*

*២- ព្រះសហគមន៍ជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់*

*៣- ព្រះសហគមន៍ត្រាស់ហៅយើងឲ្យបានវិសុទ្ធ*

*៤- ព្រះនាងម៉ារីជាគំរូសម្រាប់ព្រះសហគមន៍*

នៅខែមករា យើងនឹងមានប្រជុំអំពីមហាសន្និបាតវ៉ាទីកង់ទីពីរ នៅខែមេសា ធាតុរបស់សន្តីថេរេសានឹងមកសួរសុខទុក្ខយើង។

សូមបងប្អូននឹកឃើញឡើងវិញម្ដងទៀតអំពីអំណរសប្បាយរបស់យើង ដែលជាសមាជិកព្រះសហគមន៍។

សូមបងប្អូនអង្វរមរណសាក្សីរបស់យើង គឺលោកយ៉ូសែប ឆ្មារ សាឡាស និងសហការី ឲ្យពួកលោកជួយអង្វរព្រះជាម្ចាស់សម្រាប់ឆ្នាំនេះ។

ខ្ញុំអង្វរព្រះជាម្ចាស់សម្រាប់បងប្អូនផងដែរ។

ព្រះសង្ឃអភិបាលរបស់បងប្អូន





# ព្រះសហគមន៍
# តាមមហាសន្និបាតវ៉ាទីកង់ទី២

## ១-សម្ដេចប៉ាប យ៉ូហានទី ២៣

នៅឆ្នាំ១៩៥៨ សម្ដចប៉ាប យ៉ូហានទី ២៣ មានជន្មាយុ ៧៧ឆ្នាំ។ ពីមុនលោកធ្លាប់បំពេញមុខងារជាអគ្គរាជទូតនៅប្រទេសជាច្រើន។ លោកសង្កេតឃើញថា មានមនុស្សជាច្រើនមិនរវីរវល់នឹងព្រះសហគមន៍។ ដូច្នេះលោកមានបំណងឲ្យព្រះសហគមន៍ «រលាស់ធូលីដែលជាប់ពីចក្រភពចេញពីព្រះសហគមន៍» គឺធ្វើឲ្យព្រះសហគមន៍តបឆ្លើយនឹងសេចក្ដីរង់ចាំរបស់មនុស្ស។

## ២-មហាសន្និបាតវ៉ាទីកង់ទី ២

ថ្ងៃទី២៥ មករា ១៩៥៩ សម្ដេចប៉ាប យ៉ូហានទី ២៣ កោះហៅអស់លោកអភិបាលក្នុងពិភពលោកមកជួបជុំជាមហាសន្និបាតសកល។ លោកមានបំណងឲ្យព្រះសហគមន៍រករបៀបប្រកាសដំណឹងល្អឲ្យស្របតាមអរិយធម៌បច្ចុប្បន្ន  ព្រមទាំងណែនាំគ្រីស្ដបរិស័ទគ្រប់និកាយឲ្យរួបរួមគ្នាជាធ្លុងតែមួយ។ លោកស្នើបង្កើតគណៈកម្មាធិការរៀបចំឯកសារ ៧០ច្បាប់ទុកជាសេចក្ដីដែលត្រូវពិនិត្យ និងរិះគិត។

## ៣-ប្រជុំទី១ (១៩៦២)

លោកអភិបាល ២៤០០ រូប មកពីគ្រប់ទ្វីបចូលរួមមហាសន្និបាត។ ក្នុងអង្គប្រជុំលើកដំបូងមានបែកគំនិតពីរយ៉ាងគឺ ក្រុមអភិបាលភាគច្រើនមានបំណងតាមសម្ដេចប៉ាប យ៉ូហានទី ២៣ ដោយចង់សម្របសម្រួលព្រះសហគមន៍តាមអរិយធម៌នាបច្ចុប្បន្នកាល ចង់សន្ទនាជាមួយនិកាយផ្សេងៗ  និងចង់ឲ្យព្រះសហគមន៍យោងកម្លាំងថ្មីពីព្រះគម្ពីរវិញ។  ឯក្រុមអភិបាលភាគតិចមានបំណងឲ្យព្រះសហគមន៍ស្ថិតនៅមាំមួនដូចពីដើម។

ឆ្នាំ១៩៦៣ សម្តេចប៉ាប យ៉ូហានទី ២៣ សរសេរសារលិខិតមួយច្បាប់មានចំណងជើងថា «សេចក្តីសុខសាន្តនៅលើផែនដី»។ មានមនុស្សជាច្រើនពេញចិត្តនឹងលិខិតនេះ ពីព្រោះលោកសរសេរជូនទៅ «អស់មនុស្សដែលមានឆន្ទៈល្អ» ទាំងអស់។



## ៤-សម្តេចប៉ាប ប៉ូលទី ៦

នៅឆ្នាំ១៩៦៣ សម្តេចប៉ាប ប៉ូលទី ៦ សម្រេចថានឹងបន្តមហាសន្និបាតនេះតទៅទៀត។ ពេលប្រជុំលើកទីពីរនៅចុងឆ្នាំ១៩៦៣ អស់លោកអភិបាលរិះគិតអំពីមុខងាររួមរបស់អស់លោក អំពីគ្រីស្តបរិស័ទរួបរួមគ្នាជាផ្លូងតែមួយ និងអំពីសេរីភាពខាងសាសនា។ សម្តេចប៉ាបប្រកាសគោលលទ្ធិស្តីអំពីពិធីបុណ្យ និងក្រិត្យស្តីអំពីទំនាក់ទំនងក្នុងសង្គម។




ពេលប្រជុំលើកទី៣ នៅចុងឆ្នាំ១៩៦៤ អស់លោកអភិបាលប្រកាសគោលលទ្ធិស្តីអំពីព្រះសហគមន៍ «ពន្លឺបំភ្លឺមនុស្សគ្រប់ជាតិសាសន៍» អំពី «ចលនាបង្រួបបង្រួមគ្រីស្តបរិស័ទជាផ្លូងតែមួយ» និងអំពី «ព្រះសហគមន៍នានានៅមជ្ឈិមបូព៌ា»។

ប្រជុំលើកទី៤ នៅឆ្នាំ១៩៦៥ អស់លោកប្រកាសអត្ថបទទាំងអស់ដែលអស់លោកបានពិនិត្យមើលកាលពីប្រជុំមុនៗមក។ នៅថ្ងៃទី៨ ធ្នូ សម្តេចប៉ាប ប៉ូលទី ៦ បិទមហាសន្និបាត។ គ្រីស្តបរិស័ទសង្ឃឹមថា ព្រះសហគមន៍នឹងប្រែតាមបំណងរបស់គេ។

## ៥-មហាសន្និបាតវ៉ាទីកង់ទី ២ បើកផ្លូវថ្មីឲ្យព្រះសហគមន៍

### ក-ទេវវិជ្ជា និងគម្ពីរ



«គោលលទ្ធិស្តីអំពីព្រះជាម្ចាស់សម្តែងព្រះអង្គ» មានព្រះជាម្ចាស់តែមួយព្រះអង្គគត់តាំងពីដើមរៀងមក។ ដូច្នេះមិនត្រូវបំបែកព្រះគម្ពីរពីព្រះសហគមន៍ និងពីការបកស្រាយអត្ថន័យឲ្យអ្នកជឿតាមកាលៈទេសៈដែរ។ ព្រះជាម្ចាស់មិនបានកំណត់នូវសេចក្តីដែលព្រះអង្គសម្តែងម្តងជាស្រេចនោះទេ គឺអ្នកជឿរកឃើញសេចក្តីថ្មីជានិច្ចស្របទៅតាមគម្ពីរនោះ។ ព្រះសហគមន៍កាតូលិកនឹករឭកឡើងវិញថា៖

-គ្រីស្តបរិស័ទទាំងអស់ជាក្រុមបូជាចារ្យ។

-ព្រះសហគមន៍ជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ មិនគ្រាន់តែជាអង្គការស្របតាមច្បាប់ប៉ុណ្ណោះ។

-អភិបាលទាំងអស់រួបរួមគ្នាក្នុងការណែនាំព្រះសហគមន៍ គឺរួមជាមួយសម្តេចប៉ាប។





### ខ-ការប្រែសម្រួលពិធីបុណ្យឲ្យបានស្របតាមសម័យ

«គោលលទ្ធិស្តីអំពីពិធីបុណ្យ» ត្រូវប្រែសម្រួលព្រះសហគមន៍ឲ្យបានស្របតាមសភាពការណ៍បច្ចុប្បន្ន ជាពិសេសឲ្យគ្រីស្តបរិស័ទប្រើភាសាប្រជាជនក្នុងពិធីបុណ្យនានា។ ភាសាជាតិនីមួយៗទទួលតម្លៃជាភាសាសក្ការៈ សម្រាប់ថ្វាយបង្គំព្រះអម្ចាស់។

### គ-ទំនាក់ទំនងជាមួយសាសនាដទៃ

«សេចក្តីប្រកាសអំពីសេរីភាពខាងសាសនា» មនុស្សគ្រប់ៗរូបមានសិទ្ធិសេរីភាពដែលបំបាត់មិនបាន គឺម្នាក់ៗមានសិទ្ធិសេរីភាពអាចទៅកាន់សេចក្តីពិតតាមមនសិការរបស់ខ្លួន។ មិនត្រូវទាមទារសេរីភាពសម្រាប់តែគ្រីស្តបរិស័ទកាតូលិកប៉ុណ្ណោះទេ គឺត្រូវទាមទារសេរីភាពសម្រាប់មនុស្សទាំងអស់។ អ្នកមិនកាន់សាសនាកាតូលិក ដែលរស់នៅក្នុងស្រុកដែលមានកាតូលិកច្រើន ក៏មានសិទ្ធិសេរីភាពខាងសាសនាដែរ។

«គ្រីស្តបរិស័ទរួបរួមគ្នាជាធ្លុងតែមួយ» ដាស់តឿនគ្រីស្តបរិស័ទគ្រប់និកាយឲ្យរិះគិតអំពីសម្បត្តិរួម ពោលគឺព្រះគ្រីស្ត និងដំណឹងល្អ។ កុំចោទនិកាយឯទៀតៗថាគេបែកចេញពីឯកភាពឡើយ។

«ទំនាក់ទំនងព្រះសហគមន៍ និងសាសនាដទៃ» គ្រប់សាសនាទាំងអស់ជាពិសេសសាសនាយូដា និងសាសនាអ៊ីស្លាម សុទ្ធតែបញ្ចេញរស្មីពន្លឺនៃសេចក្តីពិត គឺជួយមនុស្សឲ្យស្គាល់ព្រះជាម្ចាស់។

«ព្រះសហគមន៍នឹកស្តាយដោយគ្រីស្តបរិស័ទខ្លះស្អប់បៀតបៀនប្រឆាំងនឹងជាតិសេមទោះជានៅសម័យណាក្តី ឬជាជនណាប្រព្រឹត្តជំទាស់នឹងជនជាតិយូដាក្តី»។

## ៦-ព្រះសហគមន៍ទាក់ទងជាមួយមនុស្សលោកនាបច្ចុប្បន្នកាល

«ព្រះសហគមន៍ជាពន្លឺបំភ្លឺជាតិសាសន៍ទាំងឡាយ» ព្រះជាម្ចាស់ត្រាស់ហៅព្រះសហគមន៍ធ្វើជាប្រជារាស្ត្ររបស់ព្រះអង្គឲ្យបានវិសុទ្ធ។ អភិបាល និងបូជាចារ្យបំពេញមុខងារពិសេសនៅក្នុងការណែនាំព្រះសហគមន៍ ប៉ុន្តែគ្មានឋានៈលើគេទេ។ ព្រះនាងម៉ារីជាតំណាងព្រះសហគមន៍ ជាគ្រីស្តបរិស័ទមុនគេ ដោយនាងជឿលើព្រះជាម្ចាស់មុនគេ និងជាគ្រីស្តបរិស័ទគំរូ។

«អំណរសប្បាយ និងសេចក្តីសង្ឃឹម» កាលពីសម័យមុន ព្រះសហគមន៍ និងមនុស្សលោកទាស់ទែងគ្នាជាញឹកញាប់ ដូច្នេះត្រូវរិះគិត

អំពីរបៀបទំនាក់ទំនងថ្មីជាមួយមនុស្សលោក គឺព្រះសហគមន៍នៅក្នុងមនុស្សលោកតែម្តង។ ត្រូវខិតខំរិះគិតអំពីលទ្ធិ និងមូលហេតុរបស់មនុស្សដែលប្រកាន់ថាគ្មានព្រះជាម្ចាស់សោះ។ ព្រះសហគមន៍ក៏រិះគិតយ៉ាងល្អិតល្អន់អំពីបញ្ហាអាពាហ៍ពិពាហ៍ ក្រុមគ្រួសារ វប្បធម៌ សេដ្ឋកិច្ច នយោបាយ សង្គម និងការកសាងសន្តិភាពជាដើម។ គ្រីស្តបរិស័ទត្រូវយល់ថា ខ្លួនមានភារកិច្ចបម្រើមនុស្សលោកទូទៅឲ្យបានសេចក្តីសុខតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។



## ៧-សម័យថ្មីកើតឡើង

គ្រីស្តបរិស័ទជាច្រើនស្មានថា ព្រះសហគមន៍ចាប់ផ្តើមរស់នៅតាមរបៀបថ្មីទាំងស្រុងហើយ។ មហាសន្និបាតវ៉ាទីកង់ទី២ នាំឲ្យគ្រីស្តបរិស័ទមានសេរីភាពក្នុងការរិះគិតពិតមែន ប៉ុន្តែសេដ្ឋកិច្ច និងអរិយធម៌ក៏ប្រែប្រួលយ៉ាងលឿនដែរ។ ដូច្នេះព្រះសហគមន៍ពិបាកបំពេញតាមសេចក្តីរង់ចាំរបស់គ្រីស្តបរិស័ទ ហើយគ្រីស្តបរិស័ទខ្លះគិតថា មហាសន្និបាតវ៉ាទីកង់ទី២ ក៏ហួសសម័យដែរ។



## ៨-លទ្ធផលនៃមហាសន្និបាតវ៉ាទីកង់ទី ២

នៅឆ្នាំ១៩៦៧ សម្តេចប៉ាប ប៉ូលទី ៦ បើកសន្និបាតអភិបាលនៅក្រុងរ៉ូម ដើម្បីជួយអស់លោកអភិបាលក្នុងការណែនាំព្រះសហគមន៍ទាំងមូល។ បន្ទាប់ពីនោះមកក្រុមប្រឹក្សាបូជាចារ្យក៏កើតឡើងក្នុងភូមិភាគនីមួយៗ។ បព្វជិតបព្វជិតាក៏កែសម្រួលធម្មនុញ្ញក្រុមគ្រួសាររបស់ខ្លួនតាម «ក្រឹត្យស្តីអំពីការប្រែសម្រួលការរស់នៅជាបព្វជិតតាមសម័យ» ដែរ។ អស់លោកកែសម្រួលពិធីបុណ្យតាម «គោលលទ្ធិពិធីបុណ្យ» គឺគ្រីស្តបរិស័ទអាចប្រើភាសាជាតិក្នុងពិធីបុណ្យនានា អាចទទួលព្រះកាយ និងព្រះលោហិតបាន និងមានចែងអំពីពិធីលើកតម្កើងព្រះបន្ទូលបានល្អជាងពីមុន បូជាចារ្យរួមគ្នាថ្វាយអភិបូជា។ល។ ប៉ុន្តែ គ្រីស្តបរិស័ទខ្លះនៅតែអាឡោះអាល័យភាសាឡាតាំងដែលគេចាត់ទុកថាជាភាសាសក្ការៈតែមួយគត់។

# ព្រះសហាគមន៍

## ប្រទេសកម្ពុជា

# ផែនទីព្រះសហគមន៍នៅកម្ពុជា



# ព្រះសហគមន៍បញ្ជូនបន្តជំនឿ







*សាវ័កទាំងនោះព្យាយាមស្តាប់សេចក្តីបង្រៀនរបស់ក្រុមគ្រីស្តទូត * រួមរស់ជាមួយគ្នាជាបងប្អូនធ្វើពិធីកាច់នំប៉័ង * និងព្យាយាមអធិដ្ឋាន។ (កក ២,៤២)*

ពេលព្រះសហគមន៍ដើមដំបូងចាប់ផ្តើម ក្រុមសាវ័កតែងតែនាំគ្នាស្តាប់សេចក្តីបង្រៀនរបស់ក្រុមគ្រីស្តទូត។ គេផ្លាស់ប្តូររបៀបរស់នៅរបស់ខ្លួន និងចេញទៅប្រកាសដំណឹងល្អដល់មនុស្សគ្រប់ជាតិសាសន៍ ឲ្យធ្វើជាសាវ័ករបស់ព្រះយេស៊ូ។

សព្វថ្ងៃគ្រីស្តបរិស័ទនៅប្រទេសកម្ពុជាយើង ក៏និយាយអំពីជំនឿរបស់ខ្លួនប្រាប់ទៅមិត្តភក្តិ បងប្អូនជិតខាងដែរ។ ដោយសារសក្ខីភាពរបស់គ្រីស្តបរិស័ទ នោះមានបងប្អូនជាច្រើនចូលរួមស្វែងយល់អំពីជំនឿរបស់ព្រះសហគមន៍។

ក្រោយពេលបងប្អូនមានជំនឿសមល្មមហើយ នោះបងប្អូនទទួលអគ្គសញ្ញាជ្រមុជទឹកទៅជាបុត្រធីតារបស់ព្រះបិតា។ ព្រះសហគមន៍យកចិត្តទុកដាក់នឹងបងប្អូនថ្មីៗ ដោយមានរៀបចំអង្គប្រជុំ សិក្ខាសាលា ឬមហាសន្និបាត ដើម្បីឲ្យបងប្អូនមានជំនឿកាន់តែរឹងមាំឡើង ធ្វើជីវិតទាំងស្រុងលើព្រះជាម្ចាស់ និងចេះស្រឡាញ់គ្នាដូចបងប្អូនផង។











# ព្រះសហគមន៍សម្ដែងមេត្តាករុណា

*អស់អ្នកដែលបានជឿលើព្រះអម្ចាស់ មានចិត្តគំនិតតែមួយ ហើយយករបស់របរដែលខ្លួនមាន មកដាក់រួមគ្នាទាំងអស់។ គេលក់ទ្រព្យសម្បត្តិ និងអ្វីៗជារបស់ខ្លួនយកប្រាក់មកចែកគ្នាតាមសេចក្ដីត្រូវការរបស់ពួកគេម្នាក់ៗ។ (កក ២,៤៤-៤៥)*



តាំងពីដើមរហូតដល់សព្វថ្ងៃ ព្រះសហគមន៍នៅតែបន្តបេសកកម្មរបស់ព្រះយេស៊ូ។ គ្រីស្តបរិស័ទផ្តល់សក្ខីភាពអំពីព្រះហឫទ័យមេត្តាករុណាដល់ជនក្រីក្រ និងដល់អ្នកជំងឺ។ល។

សព្វថ្ងៃព្រះសហគមន៍កំពុងបន្តបេសកកម្មរបស់ព្រះគ្រីស្ត។ គ្រីស្តបរិស័ទបង្ហាញព្រះហឫទ័យករុណារបស់ព្រះបិតា។ គេរំលែកសុខទុក្ខគ្នាទៅវិញទៅមក ជាពិសេសជាមួយអស់បងប្អូនដែលរងទុក្ខលំបាក ក្រីក្រជាងគេ តាមព្រះបន្ទូលរបស់ព្រះយេស៊ូ «គ្រប់ពេលដែលអ្នករាល់គ្នាបានប្រព្រឹត្តអំពើអ្វីមួយចំពោះអ្នកតូចតាច នោះក៏ដូចអ្នករាល់គ្នាបានប្រព្រឹត្តចំពោះខ្ញុំដែរ»។









# ព្រះសហគមន៍លើកតម្កើងព្រះជាម្ចាស់







*ជារៀងរាល់ថ្ងៃ គេរួមចិត្តគំនិតគ្នាព្យាយាមចូលព្រះវិហារ *ធ្វើពិធីកាច់នំប៉័ងនៅតាមផ្ទះ ព្រមទាំងបរិភោគអាហារជាមួយគ្នាយ៉ាងសប្បាយរីករាយ និងដោយចិត្តស្មោះសរផង។ (កក ២,៤៦)*

តាំងពីដើមរហូតដល់សព្វថ្ងៃ ព្រះយេស៊ូគង់នៅជាមួយព្រះសហគមន៍ និងប្រទានឲ្យគ្រីស្តបរិស័ទមានចិត្តស្រឡាញ់។

«ព្រះសហគមន៍មិនគ្រាន់តែយើងរួមគ្នានៅទីនេះទេ គឺសំដៅទៅលើគ្រីស្តបរិស័ទទូទាំងពិភពលោក ដែលបានរស់នៅតាំងពីសម័យមុនៗកំពុងរស់នៅសព្វថ្ងៃ និងគ្រីស្តបរិស័ទដែលនឹងរស់នៅក្នុងសម័យក្រោយៗទៀត រហូតដល់អវសានកាលនៃពិភពលោក។

មនុស្សទាំងអស់ដែលកើតមក នឹងបង្កើតកូនតទៅទៀត ព្រមទាំងមនុស្សសុចរិតដែលឆ្លងកាត់ជីវិតនេះ ក៏សុទ្ធតែជាព្រះសហគមន៍ដែរ»។






## ដំណាក់កាលទី ១

# គម្រោងការដ៏អស្ចារ្យរបស់ព្រះសហគមន៍

### វដ្ដូវអបអរសាទរ និងវដ្ដូវបុណ្យព្រះយេស៊ូប្រសូត

## ១.ព្រះសហគមន៍ជាអគ្គសញ្ញា



ព្រះសហគមន៍រួមក្នុងអង្គព្រះគ្រីស្ត ហាក់ដូចជាអគ្គសញ្ញាម៉្យាង គឺជាសញ្ញាសម្គាល់បង្ហាញពីព្រះជាម្ចាស់ និងជាមធ្យោបាយដែលនាំឲ្យមនុស្សអាចរួមរស់យ៉ាងជិតស្និទ្ធជាមួយព្រះអង្គបាន។ (**Lumen Gentium 1**)

**សំណួរ**
តើអ្វីទៅជាអគ្គសញ្ញា ?
-តើព្រះសហគមន៍ទៅជាអគ្គសញ្ញាយ៉ាងដូចម្ដេច ?
-តើបងប្អូនយល់ថាព្រះសហគមន៍ជាអ្វី ?



## ២.ព្រះសហគមន៍ប្រកាសព្រះរាជ្យរបស់ព្រះជាម្ចាស់

ដូច្នេះព្រះសហគមន៍បានទទួលព្រះអំណោយទានផ្សេងៗពីព្រះគ្រីស្តដែលបានបង្កើតព្រះសហគមន៍។ ព្រះសហគមន៍ក៏យកចិត្តទុកដាក់កាន់តាមបទបញ្ញារបស់ព្រះគ្រីស្តដោយចិត្តស្មោះ ពោលគឺមានចិត្តស្រឡាញ់ មានចិត្តសុភាពរាបសា មានចិត្តលះបង់។ ព្រះសហគមន៍ក៏ទទួលបេសកកម្មប្រកាសថា ព្រះគ្រីស្ត និងព្រះជាម្ចាស់គ្រងរាជ្យ និងព្រះសហគមន៍ក៏មានមុខងារតែងតាំងព្រះរាជ្យក្នុងប្រជាជាតិនានាដែរ។ ព្រះសហគមន៍ជាពន្លក និងជាដើមកំណើតនៃព្រះរាជ្យនេះនៅលើផែនដី។ (**Lumen Gentium 5**)

**សំណួរ**
តើអ្វីទៅជាព្រះរាជ្យរបស់ព្រះជាម្ចាស់ ?
-តើយើងប្រកាសព្រះរាជ្យរបស់ព្រះជាម្ចាស់យ៉ាងដូចម្ដេច ?



## ៣.ព្រះសហគមន៍ជាព្រះកាយព្រះគ្រីស្ត

ព្រះអង្គនៅតែចាត់ចែងព្រះអំណោយទានជានិច្ច ជាមុខងារបម្រើព្រះកាយព្រះអង្គ គឺព្រះសហគមន៍។ តាមព្រះអំណោយទាននៃមុខងារបម្រើទាំងនោះ និងតាមអានុភាពរបស់ព្រះអង្គផង យើងបម្រើគ្នាទៅវិញទៅមក តាមសេចក្តីត្រូវការ ដើម្បីឲ្យយើងទទួលការសង្គ្រោះ។ ដោយយើងមានចិត្តស្មោះស្រឡាញ់គ្នាទៅវិញទៅមក "យើងនឹងអាចចម្រើនឡើងគ្រប់វិស័យទាំងអស់ឆ្ពោះទៅកាន់ព្រះគ្រីស្តជាសិរសា" (អភ ៤,១១-១៦)។ (**Lumen Gentium 7**)

**សំណួរ**
សូមស្វែងរកក្នុងលិខិតរបស់គ្រីស្តទូតប៉ូលនូវអត្ថបទដែលពន្យល់ថា យើងជាព្រះកាយព្រះគ្រីស្ត។
-តើខ្ញុំជាសរីរាង្គនៃព្រះកាយព្រះគ្រីស្តយ៉ាងដូចម្តេច?



## ៤.ព្រះសហគមន៍ជាការរួបរួមក្នុងព្រះវិញ្ញាណ

ព្រះគ្រីស្តប្រទានព្រះវិញ្ញាណរបស់ព្រះអង្គឲ្យយើង ដើម្បីឲ្យយើងអាចប្រែខ្លួនឲ្យបានជាថ្មី ឥតឈប់ឈរក្នុងព្រះអង្គ។ មានព្រះវិញ្ញាណតែមួយដដែលក្នុងព្រះសិរសា និងក្នុងសរីរាង្គទាំងប៉ុន្មាន ព្រះអង្គផ្តល់ជីវិតដល់ព្រះកាយទាំងមូល ទ្រង់ប្រោសឲ្យព្រះកាយភ្ជាប់គ្នា និងកម្រើកឡើងបាន។... (**Lumen Gentium 7**)

**សំណួរ**
តើព្រះវិញ្ញាណដ៏វិសុទ្ធមានសកម្មភាពអ្វីក្នុងព្រះសហគមន៍?
តើខ្ញុំបង្ហាញផលនៃព្រះវិញ្ញាណអ្វីខ្លះក្នុងការរស់នៅប្រចាំថ្ងៃរបស់ខ្ញុំ?

## ៥.ព្រះសហគមន៍គ្មានធនធានបម្រើអ្នកក្រីក្រ

ប៉ុន្តែ ព្រះគ្រីស្តបានរំដោះមនុស្សលោកដោយព្រះអង្គរស់នៅជាអ្នកក្រីក្រ និងដោយត្រូវគេបៀតបៀនយ៉ាងណា ព្រះជាម្ចាស់ក៏ត្រាស់ហៅព្រះសហគមន៍ឲ្យរស់នៅតាមផ្លូវនេះដែរ គឺរស់នៅជាអ្នកក្រីក្រ និងត្រូវគេបៀតបៀន ដើម្បីចែករំលែកផលនៃការសង្គ្រោះឲ្យមនុស្សលោក។ ព្រះគ្រីស្តយេស៊ូ "ដែលមានសភាពជាព្រះជាម្ចាស់ បានលះបង់អ្វីៗទាំងអស់មកយកសភាពជាទាសករវិញ" (ភល ២,៦) ព្រះអង្គ "ដែលមានសម្បត្តិដ៏ច្រើន ទ្រង់ដាក់ខ្លួនជាអ្នកក្រីក្រ" ព្រោះតែយើង (២ករ ៨,៩)។ ហេតុនេះហើយ ទោះបីព្រះសហគមន៍ត្រូវការធនធានមនុស្សដើម្បីបំពេញបេសកកម្មរបស់ខ្លួនក្តី ក៏ព្រះសហគមន៍មិនកើតមកដើម្បីស្វែងរកមុខមាត់ក្នុងលោកនេះទេ តែដើម្បីបញ្ចាំងឲ្យមនុស្សលោកស្គាល់តម្លៃនៃចិត្តសុភាពរាបសា និងនៃការលះបង់ ដោយធ្វើជាគំរូឲ្យគេឃើញ។ ព្រះបិតាចាត់ព្រះគ្រីស្តឲ្យយាងមកនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ...ព្យាបាលអស់អ្នកមានចិត្តក្រៀមក្រំ (លក ៤,១៨)។ "ស្វែងរក និងសង្គ្រោះមនុស្សដែលវិនាសបាត់បង់" (លក ១៩,១០)។ ព្រះសហគមន៍ក៏មានចិត្តមេត្តាករុណាចំពោះអស់អ្នកដែលរងទុក្ខដោយភាពទន់ខ្សោយរបស់ខ្លួនជាមនុស្សដែរ។ លើសពីនេះទៅទៀត ពេលព្រះសហគមន៍ឃើញអ្នកក្រីក្រ និងអ្នកកើតទុក្ខ ព្រះសហគមន៍ក៏ទទួលស្គាល់ព្រះភ័ក្ត្ររបស់ព្រះយេស៊ូជាអ្នកក្រីក្រ និងជាអ្នករងទុក្ខលំបាកដែលបានបង្កើតព្រះសហគមន៍នោះដែរ។ ព្រះសហគមន៍ក៏ខិតខំជួយសម្រាលទុក្ខគេ ព្រោះព្រះសហគមន៍ចង់បម្រើព្រះគ្រីស្តក្នុងគេ។ (**Lumen Gentium 8**)

**សំណួរ**

តើព្រះសហគមន៍យើងបម្រើអ្នកក្រីក្រដូចម្តេច?

តើយើងអាចធ្វើជាសាក្សីអំពីព្រះហឫទ័យស្រឡាញ់របស់ព្រះបិតាចំពោះអ្នកក្រីក្រដូចម្តេចបាន?

តើព្រះសហគមន៍យើងអាចរស់នៅតាមបែបជាអ្នកក្រីក្រជាងសព្វថ្ងៃដូចម្តេចបាន? គឺរស់នៅតាមលទ្ធភាពរបស់ខ្លួន?









# និមិត្តសញ្ញាអំពីព្រះសហគមន៍

តាមគម្ពីរសម្ពន្ធមេត្រីចាស់ ព្រះជាម្ចាស់តែងតែសម្ដែងអំពីព្រះអង្គគ្រងរាជ្យតាមនិមិត្តសញ្ញាផ្សេងៗ។ សព្វថ្ងៃ ព្រះអង្គក៏សម្ដែងឲ្យយើងស្គាល់អំពីលក្ខណៈពិសេសដ៏ជ្រៅបំផុតរបស់ព្រះសហគមន៍ តាមនិមិត្តរូបផ្សេងៗដែរ គឺជានិមិត្តរូបដកស្រង់ពីការរស់នៅរបស់គង្វាលសត្វ ពីការរស់នៅរបស់កសិករ ពីការសាងសង់សំណង់ ពីការរស់នៅក្នុងក្រុមគ្រួសារ និងពីអាពាហ៍ពិពាហ៍ ដូចមានចែងក្នុងគម្ពីរព្យាការីជាប្រផ្នូលស្រាប់។

ព្រះសហគមន៍ប្រៀបដូចជាក្រោលសត្វ រីឯព្រះគ្រីស្ដវិញ ព្រះអង្គប្រៀបដូចជាទ្វារចេញចូលតែមួយ ដែលត្រូវការជាចាំបាច់ (យហ ១០,១-១០)។ ព្រះសហគមន៍ជាហ្វូងសត្វដែលព្រះជាម្ចាស់បានប្រកាសជាមុនថា ព្រះអង្គនឹងទៅជាគង្វាល (អស ៤០,១១; អគ ៣៤,១១ត)។ ទោះបីមានមនុស្សជាគង្វាលណែនាំក្ដី ក៏ព្រះគ្រីស្ដផ្ទាល់ណែនាំ និងចិញ្ចឹមចៀមទាំងនោះជានិច្ចដែរ ព្រះអង្គជាគង្វាលដ៏សប្បុរស ជាម្ចាស់លើគង្វាលទាំងប៉ុន្មាន (យហ ១០,១១; ១សល ៥,៤) ព្រះអង្គបានស៊ូប្ដូរជីវិតដើម្បីចៀមរបស់ព្រះអង្គ (យហ ១៩,១១-១៥)។

ព្រះសហគមន៍ប្រៀបដូចស្រែចម្ការ គឺជាស្រែចម្ការរបស់ព្រះជាម្ចាស់ (១ករ ៣,៩)។ ក្នុងចម្ការនោះមានដើមអូលីវមួយដើមដុះឡើងតាំងពីដើមមក គឺដើមអូលីវដែលមានអស់លោកបុព្វបុរសជាឫសដ៏វិសុទ្ធ។ នៅលើដើមអូលីវនោះ មានផ្សាំមែកថ្មីជាជនជាតិយូដា និងសាសន៍ដទៃ ដែលកំពុងសម្រុះសម្រួលគ្នា និងគង់តែនឹងស្រុះស្រួលគ្នាជាស្ថាពរនៅថ្ងៃណាមួយមិនខាន (រម ១១,១៣-២៦)។ ព្រះជាម្ចាស់ប្រៀបដូចជាម្ចាស់ចម្ការនៃស្ថានបរមសុខ ព្រះអង្គបានដាំដើមទំពាំងបាយជូរដែលទ្រង់បានជ្រើសរើស (មថ ២១,៣៣-៤៣; អស ៥,១ក)។ ដើមទំពាំងបាយជូរដ៏ពិតប្រាកដ គឺព្រះគ្រីស្ដ។ ព្រះអង្គប្រទានឲ្យយើងទៅជាមែកដែលមានជីវិត និងដែលអាចបង្កើតផលផ្លែបាន។ ដោយសារព្រះសហគមន៍ យើងស្ថិតនៅក្នុងអង្គព្រះគ្រីស្ដ។ បើដាច់ពីព្រះអង្គ យើងពុំអាចធ្វើអ្វីបានឡើយ (យហ ១៥,១-៥)។

ក្នុងគម្ពីរមានចែងជាញឹកថា ព្រះសហគមន៍ជាសំណង់របស់ព្រះជាម្ចាស់ (១ករ ៣,៩)។ ព្រះយេស៊ូជាអម្ចាស់បានប្រៀបព្រះអង្គ

ផ្ទាល់ទុកដូចជាថ្មដែលជាងសំណង់បោះបង់ចោល តែត្រឡប់ទៅជាថ្មគ្រឹះដ៏សំខាន់បំផុតវិញ (មថ ២១,៤២; កក ៤, ១១; ១សល ២,៧; ទន ១១៧,២២)។ ក្រុមគ្រីស្តទូតបានសង់ព្រះសហគមន៍លើគ្រឹះនោះ (១ករ ៣,១១) ព្រះសហគមន៍ក៏រឹងប៉ឹង និងភ្ជាប់គ្នាយ៉ាងមាំដោយសារគ្រឹះនោះដែរ។ សំណង់នេះមានឈ្មោះផ្សេងៗពីគ្នា គឺជាព្រះដំណាក់របស់ព្រះជាម្ចាស់ (១ធម ៣,១៥) ដែលមានក្រុមគ្រួសាររបស់ព្រះអង្គរស់នៅក្នុងដំណាក់នោះ ជាព្រះដំណាក់របស់ព្រះជាម្ចាស់ក្នុងព្រះវិញ្ញាណ (អភ ២,១៩-២២) ជាព្រះពន្លារបស់ព្រះជាម្ចាស់ដែលស្ថិតនៅជាមួយមនុស្សលោក (វវ ២១,៣) ជាពិសេសជាព្រះវិហារដ៏វិសុទ្ធ ដែលមានកន្លែងគោរពបូជា សាងសង់អំពីថ្មជានិមិត្តរូប។ អស់គ្រូបាធ្យាយតែងតែលើកតម្កើងព្រះវិហារនេះ។ ពិធីគោរពប្រណិប័តន៍នានាក៏តែងប្រៀបផ្ទឹមយ៉ាងត្រឹមត្រូវ អំពីព្រះវិហារនោះទៅនឹងក្រុងដ៏វិសុទ្ធ គឺក្រុងយេរូសាឡឹមថ្មី។ យើងដែលកំពុងតែរស់នៅលើផែនដីនេះ ប្រៀបដូចជាថ្មដែលមានជីវិតផ្គុំគ្នាកសាងសំណង់ (១ សល ២,៥)។ គ្រីស្តទូតយ៉ូហាននឹកសញ្ជឹងគិតអំពីទីក្រុងដ៏វិសុទ្ធដែលចុះពីស្ថានបរមសុខមក ទុកជាភរិយាថ្មោងថ្មីដែលតុបតែងខ្លួនទទួលស្វាមី នៅពេលព្រះជាម្ចាស់ប្រែពិភពលោកជាថ្មី ( វវ ២១,១ត)។

ព្រះសហគមន៍ក៏មានឈ្មោះទៀតថា "ទីក្រុងយេរូសាឡឹមនៅស្ថានលើ" និង "មាតារបស់យើង" (កាឡ ៤,២៦; វវ ១២,១៧)។ គេរៀបរាប់អំពីព្រះសហគមន៍ទុកដូចជាភរិយាដ៏និមលរបស់កូនចៀមដ៏និមល (វវ ១៩,៧; ២១,២ និង ៩;២២,១៧) ជាភរិយាដែលព្រះគ្រីស្ត "បានស្រឡាញ់ និងបូជាព្រះជន្មដើម្បីប្រោសឲ្យបានទៅជាវិសុទ្ធ" (អភ ៥, ២៦) ព្រះអង្គក៏ភ្ជាប់នឹងព្រះសហគមន៍ដោយសន្ធិសញ្ញាដែលស្រាយមិនបាន ព្រះអង្គនៅតែ "ចិញ្ចឹមបីបាច់ថែរក្សាព្រះសហគមន៍ឥតឈប់ឈរ"។ (អភ ៥,២៩) ព្រះអង្គលាងជម្រះព្រះសហគមន៍ឲ្យបានស្អាតបរិសុទ្ធ ហើយទ្រង់សព្វព្រះហឫទ័យឲ្យព្រះសហគមន៍ភ្ជាប់នឹងព្រះអង្គ ហើយគោរពចុះចូលនឹងព្រះអង្គដោយសេចក្តីស្រឡាញ់ និងដោយចិត្តស្មោះត្រង់ភក្តី (អភ ៥,២៤)។ ព្រះអង្គប្រោសប្រទានឲ្យព្រះសហគមន៍នូវសម្បត្តិលោកខាងមុខអស់កល្បជានិច្ច ដើម្បីឲ្យយើងអាចយល់នូវព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ និងរបស់ព្រះគ្រីស្តចំពោះយើង ជាព្រះហឫទ័យស្រឡាញ់ដ៏ប្រសើរហួសពីការយល់ឃើញរបស់មនុស្ស (អភ ៣,១៩)។

ក្នុងរយៈពេលព្រះសហគមន៍ធ្វើដំណើរក្នុងលោកនេះ ឆ្ងាយពីព្រះជាម្ចាស់ (២ករ ៥,៦) ព្រះសហគមន៍ចាត់ទុកខ្លួនជាជនដែលត្រូវគេនិរទេស។ ហេតុនេះហើយបានជាព្រះសហគមន៍ស្វះស្វែងរកសម្បត្តិលោកខាងមុខ ដែលមានកប់ទុកក្នុងជម្រៅចិត្តយើង ប្រៀបដូចជាឱជារសដែលទាក់ទាញខ្លួនទៅស្ថានដែលព្រះគ្រីស្តគង់នៅ គឺព្រះអង្គគង់នៅខាងស្តាំព្រះបិតា។ ជីវិតព្រះសហគមន៍កប់ទុកជាមួយព្រះគ្រីស្តក្នុងព្រះជាម្ចាស់ ទាំងរង់ចាំពេលខ្លួននឹងលេចចេញមករួមជាមួយព្រះស្វាមីប្រកបដោយសិរីរុងរឿង (កូឡ ៣,១-៤)។ (**Lumen Gentium 6**)









# សន្តី ថេរេសាបំភ្លឺយើង

## ព្រះភក្ត្រញញឹមប្រិមប្រិយរបស់ព្រះនាង

ចុងឆ្នាំនោះ ខ្ញុំឈឺក្បាលជាប្រចាំរាល់ថ្ងៃ តែខ្ញុំហាក់ដូចជាមិនដឹងខ្លួន ខ្ញុំនៅតែបន្តការសិក្សា ពេលនោះគ្មាននរណាចាប់អារម្មណ៍នឹងខ្ញុំឡើយ។ ជំងឺនេះបន្តរហូតដល់បុណ្យចម្លងឆ្នាំ១៨៨៣។ (...)

កាលដែលពុក និងបងស្រីរបស់ខ្ញុំត្រឡប់មកពីប៉ារីសវិញ អ្នកបម្រើទៅទទួលពួកគាត់ដោយទឹកមុខក្រៀមក្រំ។ ម៉ារីស្មានថាខ្ញុំស្លាប់... ប៉ុន្តែជំងឺនេះមិនធ្វើឲ្យខ្ញុំស្លាប់ភ្លាមៗទេ ជាជំងឺរបស់ឡាសារ ដើម្បីឲ្យព្រះជាម្ចាស់ទទួលសិរីរុងរឿង... តាមការពិតព្រះអង្គទទួលសិរីរុងរឿងមែន ដោយសារការយល់ព្រមរបស់ពុក។ គាត់គិតថា "កូនស្រីតូចរបស់គាត់ និងក្លាយទៅជាឆ្កួតលីលា ឬនាងមុខជាស្លាប់ពុំខាន"។ (...)

ស្ថិតនៅក្នុងសភាពអស់សង្ឃឹម ថេរេសាក៏បែរមុខទៅរកព្រះមាតានៃស្ថានបរមសុខដែរ នាងទូលអង្វរសូមព្រះនាងមេត្តាដល់ក្មេងស្រីកម្សត់នេះផង... ភ្លាមនោះ ព្រះមាតាហាក់ដូចជាស្រស់ស្អាតឡើងៗ។ ខ្ញុំមិនដែលបានឃើញអ្វីដែលប្រកបដោយសោភណភាពបែបនេះទេ។ ព្រះភក្ត្របង្ហាញនូវមេត្តាធម៌ និងមនោសញ្ចេតនាទន់ភ្លន់ មិនអាចថ្លែងបាន។ "ព្រះភក្ត្រញញឹមប្រិមប្រិយរបស់ព្រះនាង" បានជ្រៀតចូលយ៉ាងជ្រៅក្នុងដួងព្រលឹងខ្ញុំ។ ទុក្ខព្រួយ និងការឈឺចាប់ទាំងប៉ុន្មានក៏រលាយខ្យុលបាត់ស្រមោល ដំណក់ទឹកភ្នែកធំៗបានហូរចេញមកយ៉ាងស្ងៀមស្ងាត់ កាត់ផែនថ្ពាល់ដ៏ស្លេកស្លាំងរបស់ខ្ញុំ ប៉ុន្តែនោះជាទឹកភ្នែកនៃសេចក្ដីរីករាយពិតៗ... ខ្ញុំគិតថា ឱ! ព្រះមាតាព្រះនាងញញឹមដាក់ខ្ញុំៗ ត្រេកអរណាស់...មែនហើយខ្ញុំមិនត្រូវនិយាយប្រាប់គេឡើយ ពុំនោះទេសុភមង្គលរបស់ខ្ញុំនឹងវិនាសបាត់ជាពុំខាន។ ខ្ញុំឱនមុខចុះក្រោម ឃើញម៉ារីកំពុងតែសម្លឹងមើលមុខខ្ញុំដោយសេចក្ដីស្រឡាញ់។ គាត់ហាក់ដូចជារំភើប និងសង្ស័យលើការអនុគ្រោះរបស់ព្រះមាតាចំពោះរូបខ្ញុំ... ម៉ារីជាអ្នកអធិដ្ឋានទទូចសុំសេចក្ដីអនុគ្រោះនេះ ទើបមហាក្សត្រីយ៍នៃស្ថានបរមសុខប្រទានភាពញញឹមប្រកបដោយមេត្តាធម៌នេះមកឲ្យខ្ញុំ។

ដោយឃើញភ្នែកខ្ញុំចេះតែសម្លឹងមើលទៅរូបព្រះមាតា គាត់នឹកថា៖ "ថេរេសាជាហើយ!"។ ពិតមែន បុប្ផាតូចនឹងកើតម្ដងទៀត កាំរស្មីបានបំភ្លឺកម្ដៅរូបរាង មិនបោះបង់នាងចោលទេ ធ្វើឲ្យនាងកក់ក្ដៅបន្តិចម្ដងៗ យឺតៗ គួរឲ្យត្រេកត្រអាលលើកបុប្ផាដែលទោរទន់ដួលដេកឲ្យងើបឈរ ផ្ដល់កម្លាំងរហូតដល់ប្រាំឆ្នាំ ទើបនាងអាចបើកត្របករីកលើដីភ្នំ ប្រកបដោយជីជាតិនៃអារាមកាមែល។

*សន្តី ថេរេសា នៃព្រះកុមារយេស៊ូ និងព្រះភក្ត្រដ៏វិសុទ្ធ*

# បុត្រមនុស្សយាងត្រឡប់មកវិញ

*លក ២១:២៥-២៨, ៣៤-៣៦*

*២៥«គ្រានោះនឹងមានទីសម្គាល់នៅក្នុងព្រះអាទិត្យ ក្នុងព្រះច័ន្ទ និងក្នុងផ្កាយទាំងប៉ុន្មាន។ ប្រជាជាតិ ទាំងអស់នៅលើផែនដី*
*នឹងតឹងទ្រូងព្រួយបារម្ភ ពេលឮសូរសន្ធឹករលកសមុទ្របក់បោក ២៦មនុស្សម្នាភ័យស្លុតបាត់ស្មារតី នៅពេលគិតអំពីហេតុការណ៍*
*ដែលនឹងកើតមាននៅលើផែនដី ដ្បិតឫទ្ធិបារមីនានានៅលើមេឃនឹងកក្រើករំពើក។ ២៧ពេលនោះ គេនឹងឃើញបុត្រមនុស្ស**
*យាងមកក្នុងពពក ប្រកបដោយឫទ្ធានុភាព និងសិរីរុងរឿងពន់ពេកក្រៃ។ ២៨កាលណាព្រឹត្តិការណ៍ទាំងនេះចាប់ផ្ដើមកើតមាន*
*ចូរអ្នករាល់គ្នាងើបមើលទៅលើ ពីព្រោះព្រះជាម្ចាស់ជិតរំដោះអ្នករាល់គ្នាហើយ»។*
*៣៤«ចូរអ្នករាល់គ្នាប្រុងប្រយ័ត្នឲ្យមែនទែន! កុំបណ្ដោយឲ្យចិត្តរបស់អ្នករាល់គ្នារវក់រវីនឹងគ្រឿងសប្បាយ គ្រឿងស្រវឹង ឬក៏ខ្វល់*
*ខ្វាយអំពីរឿងជីវិតនេះឡើយ ក្រែងលោថ្ងៃនោះមកដល់ តែអ្នករាល់គ្នាពុំបានប្រុងប្រៀបខ្លួន ៣៥ដ្បិតថ្ងៃនោះមកដល់ប្រៀបបាន*
*នឹងសំណាញ់ដែលគ្របពីលើមនុស្សទាំងអស់នៅលើផែនដីទាំងមូល។ ៣៦ចូរប្រុងស្មារតី និងទូលអង្វរគ្រប់ពេលវេលា ដើម្បីឲ្យ*
*អ្នករាល់គ្នាមានកម្លាំងឆ្លងផុតពីហេតុការណ៍ទាំងអស់ដែលត្រូវកើតមាន ហើយដើម្បីឲ្យអ្នករាល់គ្នាអាចឈរនៅមុខបុត្រមនុស្ស»។*

-តើសព្វថ្ងៃមានទុក្ខលំបាកណាខ្លះ ដែលមនុស្សយើង ជាពិសេសសង្គមយើងកំពុងជួបប្រទះ?
-តើបងប្អូនមានរបៀបរស់នៅយ៉ាងណាដែរ ដើម្បីរង់ចាំព្រះគ្រីស្ដយាងត្រឡប់មកវិញ?
-តើបងប្អូនមានពាក្យអ្វីទូលទៅព្រះយេស៊ូឬទេ?

*អត្ថបទផ្សេងទៀត៖*
*យរ ៣៣:១៤-១៦,*
*១ថស ៣:១២-៤:២,*
*ទន ២៥*



ព្រះបន្ទូលរបស់ព្រះជាម្ចាស់

*អត្ថបទផ្សេងទៀត៖*
*បារ ៥:១-៩,*
*ភីល ១:៤-៦, ៨-១១,*
*ទន ១២៦*



## *អាទិត្យទី២ ក្នុងរដូវរង់ចាំ ត្រូវនឹងថ្ងៃអាទិត្យទី៩ ខែធ្នូ ឆ្នាំ២០១២*

# លោកយ៉ូហានបាទីស្ដបង្រៀនប្រដៅបណ្ដាជន

*លក ៣:១-៦*

*១នៅឆ្នាំទីដប់ប្រាំនៃរជ្ជកាលព្រះចៅអធិរាជរ៉ូម៉ាំង ព្រះនាមទីបេរ លោកប៉ុនទីឡាតធ្វើជាទេសាភិបាលនៅស្រុកយូដា ព្រះបាទ*
*ហេរ៉ូដជាស្ដេចអនុរាជ *គ្រប់គ្រងស្រុកកាលីឡេ ព្រះបាទភីលីពអនុជរបស់ព្រះបាទហេរ៉ូដ ជាស្ដេចអនុរាជគ្រប់គ្រងតំបន់អ៊ីទូរេ*
*និងតំបន់ត្រាខូនីត ព្រះបាទលីសាញ៉ាស ជាស្ដេចអនុរាជគ្រប់គ្រងស្រុកអាប៊ីឡែន ២លោកហាណ្ណា និងលោកកៃផាសធ្វើជា*
*មហាបូជាចារ្យ *។ ពេលនោះ ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់លោកយ៉ូហានជាកូនរបស់លោកសាការី នៅក្នុងវាលរហោ*
*ស្ថាន *។ ៣លោកយ៉ូហានធ្វើដំណើរគ្រប់ទីកន្លែងក្នុងតំបន់ទន្លេយ័រដាន់ ហើយប្រកាសឲ្យមនុស្សប្រែចិត្តគំនិត ដោយទទួល*
*ពិធីជ្រមុជទឹក * ដើម្បីព្រះជាម្ចាស់លើកលែងទោសឲ្យរួចពីបាប។ ៤លោកប្រកាសដូច្នេះស្របតាមសេចក្ដីដែលមានចែងទុក*
*ក្នុងគម្ពីរព្យាការីអេសាយថា៖ «មានសំឡេងបុរសម្នាក់ស្រែកឡើងនៅវាលរហោស្ថានថា៖ ចូររៀបចំផ្លូវរបស់ព្រះអម្ចាស់ ចូរតម្រង់*
*ផ្លូវថ្វាយព្រះអង្គ។ ៥ត្រូវបំពេញច្រកភ្នំទាំងអស់ឲ្យរាបស្មើ និងពង្រាបភ្នំតូចធំទាំងប៉ុន្មានឲ្យរាប ត្រូវតម្រង់ផ្លូវកោងឲ្យត្រង់ ព្រម*
*ទាំងលុបផ្លូវរដិបរដុបឲ្យរាបស្មើដែរ ៦នោះមនុស្សទាំងអស់នឹងឃើញការសង្គ្រោះរបស់ព្រះជាម្ចាស់»។*

-តើព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់លោកយ៉ូហានឲ្យគាត់ធ្វើអ្វី? នៅកន្លែងណា?
-តើលោកយ៉ូហានធ្វើការនោះស្របតាមសេចក្ដីថ្លែងរបស់ព្យាការីណា? ចែងមកយ៉ាងដូចម្ដេច? តើបងប្អូនប្រែចិត្តយ៉ាងណាខ្លះ ដើម្បីអបអរសាទរនឹងព្រះជាម្ចាស់លើកលែងទោសឲ្យបងប្អូន?
-តើបងប្អូនមានពាក្យអ្វីទូលអង្វរទៅព្រះយេស៊ូឬទេ?

# លោកយ៉ូហានបាទីស្ដបង្រៀនប្រដៅបណ្ដាជន

*លក ៣:១០-១៨*

*១០មហាជនសួរលោកយ៉ូហានថា៖ «បើដូច្នេះ តើយើងត្រូវធ្វើអ្វីខ្លះ?»។ ១១លោកយ៉ូហានតបទៅពួកគេវិញថា៖ «អ្នកណាមាន*
*អាវពីរ ត្រូវចែកឲ្យអ្នកដែលគ្មាន ហើយអ្នកដែលមានចំណីអាហារក៏ត្រូវចែកឲ្យអ្នកគ្មានដែរ»។ ១២មានអ្នកទារពន្ធ *ខ្លះមកទទួល*
*ពិធីជ្រមុជទឹក * ហើយសួរលោកថា៖ «លោកគ្រូអើយ! តើយើងខ្ញុំត្រូវធ្វើអ្វីខ្លះ?»។ ១៣លោកឆ្លើយវិញថា៖ «កុំទារពន្ធហួសពី*
*កម្រិតដែលមានកំណត់ទុកនោះឡើយ»។ ១៤មានទាហានមកសួរលោកថា៖ «ចុះយើងខ្ញុំវិញ តើត្រូវធ្វើអ្វីដែរ?»។ លោកឆ្លើយ*
*ថា៖ «កុំចោទប្រកាន់ កុំសង្កត់សង្កិនយកប្រាក់ពីអ្នកណាឲ្យសោះ ត្រូវស្កប់ចិត្តតែនឹងប្រាក់ខែរបស់អ្នករាល់គ្នាប៉ុណ្ណោះបាន*
*ហើយ»។ ១៥ប្រជាជននៅតែរង់ចាំ ហើយគេរិះគិតក្នុងចិត្តគ្រប់ៗគ្នាថា ប្រហែលលោកនេះទេដឹង ជាព្រះគ្រីស្ដ *!។ ១៦លោក*
*យ៉ូហានមានប្រសាសន៍ប្រាប់គេទាំងអស់គ្នាថា៖ «ខ្ញុំធ្វើពិធីជ្រមុជ *ឲ្យអ្នករាល់គ្នាក្នុងទឹក ប៉ុន្តែលោកដែលមានកម្លាំងខ្លាំងជាងខ្ញុំ*
*ជិតមកដល់ហើយ។ ខ្ញុំមានឋានៈទាបណាស់ សូម្បីតែស្រាយខ្សែស្បែកជើងជូនលោក ក៏មិនសមនឹងឋានៈដ៏ខ្ពង់ខ្ពស់របស់*
*លោកផង លោកនឹងធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នាក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ និងដោយភ្លើងវិញ។ ១៧លោកកាន់ចង្អេរ លោកសម្អាត*
*លានបោកស្រូវ ដើម្បីអុំស្រូវយកគ្រាប់ល្អប្រមូលដាក់ជង្រុក រីឯសំដីវិញលោកនឹងដុតក្នុងភ្លើងដែលឆេះពុំចេះរលត់ឡើយ»។*
*១៨លោកយ៉ូហានប្រកាសដំណឹងល្អ *ដល់ប្រជាជនដោយពាក្យដាស់តឿនជាច្រើនទៀតផង។*

-សន្ដ:យ៉ូហាន បានប្រាប់ទៅបណ្ដាជនអំពីរបៀបដែលគេប្រែចិត្ត។ សូមបងប្អូនអង្វរព្រះ វិញ្ញាណឲ្យបងប្អូនដឹងពីចំណុចដែលបងប្អូនត្រូវប្រែចិត្តដែរ។

-តើសន្ដ:យ៉ូហានមានប្រសាសន៍ថាយ៉ាងដូចម្ដេច ប្រាប់ទៅប្រជាជនអំពីលក្ខណ:របស់ព្រះគ្រីស្ដ? ចំពោះបងប្អូនវិញ តើព្រះគ្រីស្ដមានអត្ថន័យយ៉ាងណាដែរក្នុងការរស់នៅ? ចូរអង្វរព្រះជាម្ចាស់ឲ្យបងប្អូនចេះផ្ញើជីវិតលើព្រះយេស៊ូក្នុងគ្រប់កាលៈទេសៈនៃជីវិតរបស់ខ្លួន។

*អត្ថបទផ្សេងទៀត៖*
*សផ ៣:១៤-១៨ក,*
*ភីល ៤:៤-៧,*
*អស ១២, ២.៤-៦*



## អាទិត្យទី៤ ក្នុងរដូវរង់ចាំ ត្រូវនឹងថ្ងៃអាទិត្យទី២៣ ខែធ្នូ ឆ្នាំ២០១២

អត្ថបទផ្សេងទៀត៖
មីក ៥:១-៤ក,
ហេប ១០:៥-១០,
ទន ៨០



# នាងម៉ារីទៅសួរសុខទុក្ខនាងអេលីសាបិត

*លក ១:៣៩-៤៥*

*៣៩នៅគ្រានោះ នាងម៉ារីប្រញាប់ប្រញាល់ធ្វើដំណើរទៅកាន់ភូមិមួយនៅតំបន់ភ្នំ ក្នុងស្រុកយូដា។ ៤០នាងបានចូលទៅក្នុងផ្ទះ*
*លោកសាការី ហើយជម្រាបសួរនាងអេលីសាបិត។ ៤១ពេលនាងអេលីសាបិតឮនាងម៉ារីជម្រាបសួរ ទារកនៅក្នុងផ្ទៃនាងបម្រះ*
*ឡើង ហើយគាត់ក៏បានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ៤២រួចបន្លឺសំឡេងឡើងថា៖ «ព្រះជាម្ចាស់បានប្រទានពរដល់នាង*
*លើសស្ត្រីនានា ហើយព្រះអង្គក៏ប្រទានពរដល់បុត្រនាងដែរ។ ៤៣តើរូបខ្ញុំនេះមានឋានៈអ្វី បានជាមាតាព្រះអម្ចាស់របស់ខ្ញុំមក*
*សួរសុខទុក្ខខ្ញុំដូច្នេះ?។ ៤៤កាលខ្ញុំបានឮពាក្យជម្រាបសួររបស់នាង ស្រាប់តែកូននៅក្នុងផ្ទៃខ្ញុំបម្រះឡើង ដោយអំណរសប្បាយ*
*៤៥នាងពិតជាមានសុភមង្គលមែន ព្រោះនាងបានជឿ ព្រះបន្ទូលដែលព្រះអម្ចាស់ប្រាប់នាងមុខជាបានសម្រេចមិនខាន»។*

-នៅពេលព្រះនាងម៉ារីជម្រាបសួរ ពេលនោះទារកក្នុងផ្ទៃនាងអេលីសាបែតក៏បម្រះឡើង តើការណ៍នេះមានអត្ថន័យខាងជំនឿលើព្រះយេស៊ូយ៉ាងណាដល់បងប្អូន?

-តើពាក្យស្វាគមន៍របស់នាងអេលីសាបិត ចំពោះនាងម៉ារី ផ្តល់អត្ថន័យខាងជំនឿលើព្រះយេស៊ូ យ៉ាងណាដល់បងប្អូន?

-តើធម៌ "បពិត្រព្រះនាងម៉ារី" ជួយពង្រឹងជំនឿលើព្រះយេស៊ូយ៉ាងណាដល់បងប្អូន?

## *បុណ្យលើកតម្កើងព្រះរាជវង្ស ត្រូវនឹងថ្ងៃអាទិត្យទី៣០ ខែធ្នូ ឆ្នាំ២០១២*

# ព្រះកុមារយេស៊ូនៅក្នុងព្រះវិហារ

*លក ២:៤១-៥២*

*[៤១]ជារៀងរាល់ឆ្នាំ ក្នុងឱកាសបុណ្យចម្លង* មាតាបិតារបស់ព្រះយេស៊ូតែងតែធ្វើដំណើរទៅក្រុងយេរូសាឡឹម។ [៤២]លុះដល់*
*ព្រះយេស៊ូមានព្រះជន្មាយុដប់ពីរព្រះវស្សា មាតាបិតាក៏នាំព្រះអង្គឡើងទៅចូលរួមក្នុងពិធីបុណ្យតាមទំនៀមទម្លាប់។ [៤៣]លុះ*
*ពិធីបុណ្យបានចប់សព្វគ្រប់ហើយ អ្នកទាំងពីរនាំគ្នាវិលត្រឡប់ទៅផ្ទះវិញ។ រីឯព្រះកុមារយេស៊ូគង់នៅក្រុងយេរូសាឡឹមនៅ*
*ឡើយ តែមាតាបិតាពុំបានដឹងទេ។ [៤៤]គាត់នឹកស្មានថា ព្រះកុមារគង់នៅក្នុងចំណោមអស់អ្នកដែលរួមដំណើរជាមួយគ្នា។*
*ក្រោយពីបានធ្វើដំណើរអស់រយៈពេលមួយថ្ងៃ ទើបគាត់នាំគ្នាដើររកព្រះកុមារក្នុងចំណោមញាតិមិត្តទាំងអស់ [៤៥]ប៉ុន្តែរកពុំឃើញ*
*សោះ គាត់ក៏នាំគ្នាត្រឡប់ទៅក្រុងយេរូសាឡឹមវិញ ដើម្បីរកព្រះអង្គនៅទីនោះទៀត។ [៤៦]បីថ្ងៃក្រោយមក មាតាបិតាឃើញ*
*ព្រះយេស៊ូក្នុងព្រះវិហារ* ព្រះអង្គគង់នៅកណ្ដាលចំណោមគ្រូអាចារ្យ *កំពុងតែស្ដាប់គេនិយាយ ព្រមទាំងសួរសំណួរផ្សេងៗ*
*ដល់គេផង។ [៤៧]អស់អ្នកដែលស្ដាប់ព្រះកុមារ នឹកឆ្ងល់ពីព្រះបន្ទូលឆ្លើយឆ្លងរបស់ព្រះអង្គប្រកបដោយព្រះប្រាជ្ញាញាណ។*
*[៤៨]កាលមាតាបិតាបានឃើញព្រះកុមារហើយ គាត់នឹកឆ្ងល់យ៉ាងខ្លាំង។ មាតាសួរថា៖ «កូនអើយ! ហេតុអ្វីបានជាកូនធ្វើដូច្នេះ?*
*ឪពុកម្ដាយព្រួយចិត្តណាស់ ខំដើររកកូន»។ [៤៩]ព្រះកុមារមានព្រះបន្ទូលតបថា៖ «ហេតុអ្វីបានជាលោកឪពុកអ្នកម្ដាយរកកូន*
*យ៉ាងហ្នឹង? តើលោកឪពុកអ្នកម្ដាយមិនជ្រាបថា កូនត្រូវនៅក្នុងដំណាក់ព្រះបិតារបស់កូនទេឬ?»។ [៥០]ប៉ុន្តែមាតាបិតាពុំបាន*
*យល់អត្ថន័យនៃព្រះបន្ទូលរបស់ព្រះកុមារឡើយ។ [៥១]បន្ទាប់មកព្រះកុមារយេស៊ូយាងត្រឡប់ទៅភូមិណាសារ៉ែតជាមួយមាតា*
*បិតាវិញ ហើយធ្វើតាមឱវាទរបស់គាត់ទាំងពីរនាក់។ មាតារបស់ព្រះអង្គចងចាំហេតុការណ៍ទាំងអស់នោះទុកក្នុងចិត្ត។ [៥២]ព្រះយេស៊ូ*
*មានវ័យចម្រើនឡើង ហើយមានប្រាជ្ញាកាន់តែវាងវៃជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់ និងជាទីគាប់ចិត្តមនុស្សផងទាំងពួង។*

-តើព្រះមាតាសួរទៅព្រះកុមារយេស៊ូយ៉ាងដូចម្ដេច នៅពេលរកឃើញនៅក្នុងព្រះវិហារ ? តើការណ៍នេះ ព្រះនាងម៉ារីជាមាតាគំរូដល់មាតាបិតាទាំងឡាយនៅពេលសព្វថ្ងៃយ៉ាងណា?

-សូមបងប្អូនរិះគិតនៅ ខ ៤៩: តើសេចក្ដីនេះបញ្ជាក់ថាព្រះយេស៊ូជានរណា?

-សូមបងប្អូនរិះគិតនៅ ខ ៥១ : តើសេចក្ដីនេះព្រះកុមារយេស៊ូ ជាគំរូដល់កូនៗទាំងឡាយ នៅពេលសព្វថ្ងៃយ៉ាងណា?

*អត្ថបទផ្សេងទៀត៖*
*១សម ១:២០-២២,*
*២៤-២៨,*
*១យហ ៣:១-២,*
*២១-២៤, ទន ៨៤*



អត្ថបទផ្សេងទៀត៖
អស ៦០:១-៦,
អភ ៣:២-៣ក, ៥-៦,
ទន ៧២



# ពួកហោរាចារ្យមកថ្វាយបង្គំព្រះឱរសយេស៊ូ

**មថ ២:១-១២**

១ព្រះយេស៊ូប្រសូតនៅភូមិបេថ្លេហិមក្នុងស្រុកយូដា នារជ្ជកាលព្រះបាទហេរ៉ូដ។ មានពួកហោរាចារ្យនាំគ្នាធ្វើដំណើរពីទិសខាង
កើតមកដល់ក្រុងយេរូសាឡឹម ២សួរថា៖ «ព្រះមហាក្សត្ររបស់ជនជាតិយូដា ដែលទើបនឹងប្រសូតគង់នៅឯណា? យើងខ្ញុំ
បានឃើញផ្កាយរបស់ព្រះអង្គរះនៅទិសខាងកើត ហើយយើងខ្ញុំមកថ្វាយបង្គំព្រះអង្គ»។ ៣កាលព្រះបាទហេរ៉ូដឮដំណឹងនេះ
ទ្រង់រន្ធត់ព្រះហឫទ័យយ៉ាងខ្លាំង ហើយអ្នកក្រុងយេរូសាឡឹមទាំងអស់ក៏រន្ធត់ចិត្តជាមួយព្រះអង្គដែរ។ ៤ព្រះរាជាត្រាស់ហៅ
ពួកនាយកបូជាចារ្យ* និងពួកធម្មាចារ្យ*ទាំងប៉ុន្មានរបស់ប្រជាជនមក ដើម្បីសួរគេពីទីកន្លែងដែលព្រះគ្រីស្ត*ត្រូវប្រសូត។
៥គេទូលស្ដេចថា ព្រះគ្រីស្តត្រូវប្រសូតនៅភូមិបេថ្លេហិម ក្នុងស្រុកយូដា ដ្បិតមានសេចក្ដីចែងទុកមកតាមរយៈព្យាការី*ថា៖
៦«ភូមិបេថ្លេហិមជាដែនដីយូដាអើយ! ក្នុងបណ្ដាក្រុងសំខាន់ៗនៃស្រុកយូដា អ្នកមិនមែនតូចជាងគេទេ ដ្បិតនឹងមានមេដឹកនាំ
មួយរូបកើតចេញពីអ្នក លោកនឹងថែរក្សាជនជាតិអ៊ីស្រាអែលជាប្រជារាស្ត្ររបស់យើង»។ ៧ពេលនោះ ព្រះបាទហេរ៉ូដហៅ
ពួកហោរាចារ្យមកជាសម្ងាត់ សួរបញ្ជាក់អំពីពេលដែលផ្កាយរះឡើង។ ៨បន្ទាប់មក ទ្រង់ចាត់ហោរាចារ្យទាំងនោះឲ្យទៅភូមិ
បេថ្លេហិម ដោយមានរាជឱង្ការថា៖ «សុំអស់លោកនាំគ្នាទៅចុះ ហើយស៊ើបសួរដំណឹងអំពីព្រះឱរសនោះ ឲ្យបានច្បាស់លាស់។
កាលបើបានឃើញហើយ ចូរមកប្រាប់យើងវិញផង ដើម្បីឲ្យយើងបានទៅថ្វាយបង្គំព្រះអង្គដែរ»។ ៩ក្រោយពីបានទទួលរាជ
ឱង្ការហើយ គេក៏នាំគ្នាចេញទៅ។ ពេលនោះ ផ្កាយដែលគេបានឃើញនៅទិសខាងកើតនាំមុខគេរហូតដល់កន្លែងដែលព្រះ
ឱរសគង់ទើបឈប់។ ១០កាលហោរាចារ្យទាំងនោះឃើញផ្កាយ គេសប្បាយចិត្តពន់ប្រមាណ ១១គេចូលទៅក្នុងផ្ទះ ឃើញព្រះឱរស
គង់នៅជាមួយនាងម៉ារីជាមាតា គេក៏នាំគ្នាក្រាបថ្វាយបង្គំព្រះអង្គ រួចបើកហិបយកទ្រព្យរបស់ខ្លួន គឺមាស គ្រឿងក្រអូប និង
ជ័រល្វីងទេសមកថ្វាយព្រះអង្គ។ ១២បន្ទាប់មកគេវិលត្រឡប់ទៅស្រុករបស់ខ្លួនវិញ តាមផ្លូវមួយផ្សេងទៀត ដ្បិតព្រះជាម្ចាស់មាន
ព្រះបន្ទូលប្រាប់គេក្នុងសុបិននិមិត្តមិនឲ្យវិលទៅគាល់ព្រះបាទហេរ៉ូដវិញឡើយ។

-តើពួកហោរាចារ្យដែលមិនមែនជាជនជាតិយូដា មកក្រុងយេរូសាឡឹមសួររកអ្វី? ដើម្បីអ្វី?
-ស្ដេចហេរ៉ូដ ត្រាស់បង្គាប់ទៅនាយកបូជាចារ្យ ធម្មាចារ្យ ដែលជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ឲ្យសួររកអ្វី? ដើម្បីអ្វី?
តើបងប្អូនដូចហោរាចារ្យ ឬ ដូចប្រជារាស្ត្ររបស់ព្រះជាម្ចាស់ក្នុងអត្ថបទនេះយ៉ាងណា?

# ព្រះយេស៊ូទទួលពិធីជ្រមុជទឹក

*លក ៣:១៥-១៦, ២១-២២*

*១៥ប្រជាជននៅតែរង់ចាំ ហើយគេរិះគិតក្នុងចិត្តគ្រប់ៗគ្នាថា ប្រហែលលោកនេះទេដឹង ជាព្រះគ្រីស្ត*!។ ១៦លោកយ៉ូហានមាន*
*ប្រសាសន៍ប្រាប់គេទាំងអស់គ្នាថា៖ «ខ្ញុំធ្វើពិធីជ្រមុជ*ឲ្យអ្នករាល់គ្នាក្នុងទឹក ប៉ុន្តែលោកដែលមានកម្លាំងខ្លាំងជាងខ្ញុំជិតមកដល់ ហើយ។ ខ្ញុំមានឋានៈទាបណាស់ សូម្បីតែស្រាយខ្សែស្បែកជើងជូនលោក ក៏មិនសមនឹងឋានៈដ៏ខ្ពង់ខ្ពស់របស់លោកផង លោកនឹងធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នាក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ និងដោយភ្លើងវិញ។*
*២១ពេលប្រជាជនទាំងអស់ទទួលពិធីជ្រមុជទឹករួចហើយ ព្រះយេស៊ូក៏ទទួលពិធីជ្រមុជទឹកដែរ។ នៅពេលព្រះអង្គកំពុងអធិដ្ឋាន**
*ស្រាប់តែផ្ទៃមេឃបើកចំហ*
*២២ហើយព្រះវិញ្ញាណដ៏វិសុទ្ធ*យាងចុះមក មានរូបរាងដូចសត្វព្រាបសណ្ឋិតលើព្រះអង្គ។ មានឮព្រះសូរសៀងពីលើមេឃមកថា៖ «ព្រះអង្គជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ចិត្តនឹងព្រះអង្គណាស់»។*

-តើសន្តៈយ៉ូហានមានប្រសាសន៍អំពីឋានៈរបស់គាត់ និងរបស់ព្រះគ្រីស្តយ៉ាងណាប្រាប់ទៅ បណ្ដាជន? ចុះបងប្អូនវិញនឹងនិយាយ អំពីព្រះគ្រីស្តយ៉ាងណាប្រាប់ទៅបងប្អូនឯទៀតៗ?

-ពេលព្រះយេស៊ូទទួលពិធីជ្រមុជទឹកហើយ តើមានឮព្រះសូរសៀងយ៉ាងដូចម្ដេចពីលើមេឃមក? តើព្រះសូរសៀងនេះពង្រឹងជំនឿរបស់បងប្អូនលើព្រះយេស៊ូយ៉ាងណា?

*អត្ថបទផ្សេងទៀត៖*
*អស ៤២:១-៤, ៦-៧, ទត ២:១១-១៤, ៣:៤-៧*
*ទន ១០៤*





## ដំណាក់កាលទី ២

# ព្រះសហគមន៍ជាប្រជារាស្ត្រ
# របស់ព្រះជាម្ចាស់

### វគ្គធម្មតា-វគ្គអប់រំពិសេស

## ១.ព្រះសហគមន៍ជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់

### ក-ប្រជារាស្ត្ររបស់ព្រះជាម្ចាស់

ព្រះគ្រីស្តជាសិរសា គឺជាមេដឹកនាំរបស់ប្រជាជននៃពេលចុងក្រោយនោះ...។

ប្រជាជននោះមានលក្ខណៈពិសេស គឺមានកិត្តិយសដ៏ថ្លៃថ្នូរ និងសេរីភាពក្នុងឋានៈជាបុត្រធីតារបស់ព្រះជាម្ចាស់ ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅក្នុងចិត្តគេ ដូចជាគង់នៅក្នុងព្រះវិហារមួយដែរ។ ធម្មវិន័យនៃប្រជាជននោះ ជាវិន័យថ្មីរបស់ព្រះយេស៊ូ ពោលគឺត្រូវស្រឡាញ់គ្នាដូចព្រះគ្រីស្តបានស្រឡាញ់យើងដែរ (យហ ១៣,៣៤)។ ប្រជាជននោះមានទិសដៅតែមួយ គឺឲ្យព្រះជាម្ចាស់គ្រងរាជ្យលើគេ ដូចព្រះអង្គផ្ទាល់ចាប់ផ្តើមគ្រងរាជ្យនៅលើផែនដីនេះ ព្រះរាជ្យនេះត្រូវលាតសន្ធឹងឲ្យបានកាន់តែឆ្ងាយទៅៗ រហូតដល់អវសានកាលនៃពិភពលោក។ (**Lumen Gentium 9**)

### ខ-ព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់ឲ្យចូលព្រះសហគមន៍

ព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់ឲ្យចូលរួមក្នុងប្រជារាស្ត្រថ្មីរបស់ព្រះអង្គ។ ទោះបីប្រជារាស្ត្រនេះរួមគ្នាជាផ្លូងតែមួយ និងមានតែមួយគត់ក្តី ក៏ប្រជារាស្ត្រនេះមានគោលដៅលាតសន្ធឹងក្នុងពិភពលោកទាំងមូល និងនៅគ្រប់សម័យរហូតតរៀងទៅ។ ដូច្នេះព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលប្រតិស្ឋានមនុស្សជាតិកាលពីដើមដំបូងមក នឹងកើតជារូបរាង គឺប្រមែប្រមូលបុត្រធីតារបស់ព្រះអង្គដែលបែកខ្ញែកគ្នា មករួបរួមគ្នាជាប្រជាជនតែមួយ (យហ ១១,៥២)។ (**Lumen Gentium 13**)

ព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់ឲ្យចូលរួមក្នុងប្រជារាស្ត្រសកលរបស់ព្រះអង្គ។ ព្រះសហគមន៍កាតូលិកនេះ គឺជាប្រផ្នូលអំពីសន្តិភាពសកល និងជួយបង្កើតសន្តិភាពសកលនេះថែមទៀតផង។ ព្រះជាម្ចាស់ប្រណីសន្តោសហៅមនុស្សទាំងអស់ឲ្យទទួលការសង្គ្រោះ ទាំងគ្រីស្តបរិស័ទកាតូលិក ទាំងអស់អ្នកឯទៀតៗដែលផ្ញើជីវិតលើព្រះគ្រីស្ត។ សរុបសេចក្តីមក ឥតមានចោលនរណាសោះ គឺព្រះអង្គត្រាស់ហៅមនុស្សទាំងអស់ឲ្យភ្ជាប់នឹងព្រះសហគមន៍សកលតាមបែបផ្សេងៗ ហើយតម្រង់ទៅកាន់ព្រះសហគមន៍សកលនោះ។ (**Lumen Gentium 13**)









### គ-ព្រះសហគមន៍បំពេញបេសកកម្មជាសាសនទូត

«ចាប់ពីទិសខាងកើតរហូតដល់ទិសខាងលិច នាមរបស់យើងប្រសើរឧត្តុង្គឧត្តមក្នុងចំណោមប្រជាជាតិនានា។ នៅគ្រប់ទីកន្លែង គេនាំគ្នាថ្វាយសក្ការបូជា និងយកតង្វាយដ៏បរិសុទ្ធមកថ្វាយយើង» (មគ ១,១១)។ ដូច្នេះ ព្រះសហគមន៍អង្វរព្រះជាម្ចាស់ផង និងធ្វើកិច្ចការនៅពេលជាមួយគ្នាផង ដើម្បីឲ្យមនុស្សលោកទាំងអស់ប្រែទៅជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ទៅជាព្រះកាយរបស់ព្រះអម្ចាស់ និងទៅជាព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះសហគមន៍ក៏នឹងលើកតម្កើងសិរីរុងរឿងព្រះបិតាដែលប្រតិស្ឋានពិភពលោកក្នុងអង្គព្រះគ្រីស្ត ជាព្រះសិរសារបស់មនុស្សទាំងអស់។ ( **Lumen Gentium 17**)

**សំណួរ**

តើខ្ញុំយល់យ៉ាងណាអំពីប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ?
ប្រជារាស្ត្ររបស់ព្រះជាម្ចាស់មានលក្ខណៈអ្វី ?
តើនរណាជាសមាជិកនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ?
តើព្រះសហគមន៍យើងអាចបំពេញបេសកកម្មជាសាសនទូតដូចម្តេច ?

## ២.អស់លោកអភិបាល

ហេតុនេះហើយបានជាក្រុមអភិបាលទទួលបន្ទុកបម្រើព្រះសហគមន៍ ដោយមានបូជាចារ្យ (អាចារ្យ) និងឧបដ្ឋាកជួយជាសហការីផង។ អស់លោកធ្វើជាអធិបតីព្រះសហគមន៍ក្នុងនាមព្រះជាម្ចាស់។ អស់លោកជាគង្វាល គឺមានមុខងារបម្រើព្រះសហគមន៍ ដោយបង្រៀន ដោយធ្វើជាបូជាចារ្យក្នុងពិធីបុណ្យនានា និងដោយគ្រប់គ្រងទៀតផង។ ព្រះអម្ចាស់បានផ្ញើបន្ទុកឲ្យគ្រីស្តទូតសិលាផ្ទាល់ជាគ្រីស្តទូតទីមួយក្នុងចំណោមគ្រីស្តទូតឯទៀតៗ។ បន្ទុកនេះត្រូវតែបញ្ជូនឲ្យអ្នកបន្តមុខងាររបស់លោក ពិតជាបន្ទុកដែលនៅស្ថិតស្ថេររហូតយ៉ាងណា ក៏បន្ទុកព្រះគ្រីស្តធ្វើឲ្យក្រុមគ្រីស្តទូតជាគង្វាលព្រះសហគមន៍ ត្រូវស្ថិតស្ថេររហូតយ៉ាងនោះដែរ ដោយសារអគ្គសញ្ញា

តែងតាំងជាអភិបាល។ ហេតុនេះហើយបានជាមហាសន្និបាតដ៏វិសុទ្ធបង្រៀនថា ព្រះជាម្ចាស់ចាត់ចែងក្រុមអភិបាលឲ្យបន្តមុខងារក្រុមគ្រីស្តទូតក្នុងឋានៈជាគង្វាលព្រះសហគមន៍។ អ្នកណាស្តាប់អស់លោក ក៏ដូចជាស្តាប់ព្រះគ្រីស្តដែរ។ អ្នកណាបដិសេធមិនទទួលអស់លោក ក៏ដូចជាបដិសេធមិនទទួលព្រះគ្រីស្តដែរ ហើយថែមទាំងមិនទទួលព្រះបិតាដែលចាត់ព្រះគ្រីស្តឲ្យមកនោះទៀតផង (លក ១០,១៦)។ ( **Lumen Gentium 20**)



ព្រះបិតានៃក្រុមគ្រួសារទាំងមូល ចាត់លោកអភិបាលឲ្យគ្រប់គ្រងបុត្រធីតារបស់ព្រះអង្គ។ លោកត្រូវនឹកគិតដល់ព្រះយេស៊ូជាគង្វាលដ៏ល្អ គឺយកធ្វើជាគំរូជានិច្ច។ ព្រះអង្គជាគង្វាលដែលមកក្នុងពិភពលោកនេះ មិនមែនដើម្បីឲ្យគេបម្រើលោកទេ តែលោកមកបម្រើគេវិញ (មថ ២០,២៨; មក ១៩,៤៥) និងស៊ូប្តូរជីវិតដើម្បីចៀមរបស់ខ្លួន (យហ ១០,១១)។ ដោយគេជ្រើសរើសលោកពីចំណោមមនុស្ស ហើយដោយលោកផ្ទាល់ក៏ទន់ខ្សោយដែរ លោកអាចអធ្យាស្រ័យដល់មនុស្សល្ងង់ និងមនុស្សវង្វេងបាន (ហប ៥,១-២)។ ហេតុនេះលោកអភិបាលត្រូវយកចិត្តទុកដាក់ស្តាប់ អ្នកដែលស្ថិតនៅក្រោមអំណាចរបស់លោក និងយកចិត្តទុកដាក់ស្រឡាញ់គេទុកជាកូនដ៏ពិតប្រាកដ ទាំងដាស់តឿនគេឲ្យធ្វើការរួមជាមួយលោក ដោយចិត្តឧស្សាហ៍ផង។ ដោយលោកអភិបាលត្រូវទទួលខុសត្រូវលើគេនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ (ហប ១៣,១៧) លោកត្រូវអធិដ្ឋាន បកស្រាយគម្ពីរ និងប្រព្រឹត្តគ្រប់កិច្ចការសម្តែងសេចក្តីស្រឡាញ់ គឺត្រូវយកចិត្តទុកដាក់ដល់កូនចៅរបស់លោក និងដល់អស់អ្នកដែលមិនទាន់ចូលក្នុងហ្វូងចៀមតែមួយ។ លោកត្រូវរាប់គេទុកជាអ្នកដែលព្រះអម្ចាស់បានផ្ញើទុកមកលោកដែរ។ លោកអភិបាលក៏ដូចគ្រីស្តទូតប៉ូលដែរ គឺលោកត្រូវមានបំណងនាំដំណឹងល្អមកជូនមនុស្សទាំងអស់ ព្រោះជាមុខងារដែលលោកត្រូវធ្វើសម្រាប់មនុស្សទាំងអស់ (រម ១,១៤-១៥) ទាំងជំរុញគ្រីស្តបរិស័ទទាំងអស់ឲ្យបំពេញសកម្មភាពជាគ្រីស្តទូត និងជាសាសនទូតដែរ។ រីឯគ្រីស្តបរិស័ទវិញ គេត្រូវភ្ជាប់ចិត្តស្រឡាញ់អភិបាលរបស់ខ្លួន ដូចព្រះសហគមន៍ភ្ជាប់ចិត្តស្រឡាញ់ព្រះគ្រីស្ត និងដូចព្រះគ្រីស្តភ្ជាប់ចិត្តស្រឡាញ់ព្រះបិតា ដើម្បីឲ្យអ្វីៗទាំងអស់រួមគ្នាជាផ្លុងតែមួយ និងបង្កើតផល ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (២ករ ៤,១៥)។ (**Lumen Gentium 27**)



**សំណួរ**

តើលោកអភិបាលមានមុខងារអ្វីខ្លះ?

តើខ្ញុំមានបំណងឲ្យលោកអភិបាលធ្វើអ្វី?

តើខ្ញុំមានសំណូមពរអ្វី ឬសួរអ្វីដល់លោកអភិបាល?





## ៣.អស់លោកគង្វាល ( បូជាចារ្យ )

ដោយអានុភាពនៃអគ្គសញ្ញាតែងតាំងជាអ្នកបម្រើ អស់លោកបានដូចព្រះគ្រីស្តជាមហាបូជាចារ្យដ៏ខ្ពង់ខ្ពស់បំផុត ដែលស្ថិតនៅអស់កល្បជានិច្ច ( ហប ៥,១-១០; ៧,២៤; ៩,១១-២៨ ) ព្រះអង្គបានញែកប្រសិទ្ធិអស់លោកជាបូជាចារ្យនៃសម្ព័ន្ធមេត្រីថ្មីយ៉ាងពិតប្រាកដ ឲ្យប្រកាសដំណឹងល្អ និងឲ្យធ្វើជាគង្វាលរបស់គ្រីស្តបរិស័ទ ហើយឲ្យធ្វើពិធីគោរពប្រណិប័តន៍នានា គោរពបម្រើព្រះជាម្ចាស់។ **(Lumen Gentium 28)**

អស់លោកជាសហការីដ៏ឈ្លាសវៃរបស់ក្រុមអភិបាល ក្នុងឋានៈជាអ្នកជួយ និងជាអ្នកដែលលោកអភិបាលអាចប្រើបាន។ ព្រះជាម្ចាស់បានត្រាស់ហៅអស់លោកគង្វាល ឲ្យបម្រើប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ហើយរួមជាមួយអភិបាលរបស់ខ្លួន ជាក្រុមគង្វាលតែមួយ ដែលមានមុខងារផ្សេងៗពីគ្នា។ នៅគ្រប់កន្លែងដែលមានសហគមន៍គ្រីស្តបរិស័ទ អស់លោកប្រៀបដូចជាវត្តមានរបស់លោកអភិបាល និងរួមសហការជាមួយលោកអភិបាលដោយទុកចិត្ត ដោយមានចិត្តទូលំទូលាយ ទាំងសុខចិត្តទទួលចំណែកនៃបន្ទុក និងកង្វល់របស់លោក។ អស់លោកក៏អនុវត្តតាមបន្ទុក និងកង្វល់នោះ នៅពេលបម្រើគ្រីស្តបរិស័ទជារៀងរាល់ថ្ងៃ។ **(Lumen Gentium 28)**

អស់លោកគង្វាល ត្រូវចាប់អារម្មណ៍នឹងគ្រីស្តបរិស័ទដែលអស់លោកបានបង្កើតដោយអគ្គសញ្ញាជ្រមុជទឹក និងដោយបង្រៀនគេ ( ១ករ ៤,១៥; ១សល១, ២៣ ) ក្នុងឋានៈជាឪពុករបស់គេក្នុងអង្គព្រះគ្រីស្ត។ ត្រូវធ្វើគំរូល្អដល់ហ្វូងចៀម ( ១សល ៥,៣ ) ហើយណែនាំ និងបម្រើសហគមន៍នានាតាមភូមិ ដើម្បីឲ្យសហគមន៍ទាំងនោះ សមនឹងទទួលនាមនៃប្រជារាស្ត្រតែមួយគត់របស់ព្រះជាម្ចាស់ទាំងមូលថា "ព្រះសហគមន៍របស់ព្រះជាម្ចាស់" ( ១ករ ១,២;២ករ ១,១ )។ សូមអស់លោកនឹកចងចាំថា អស់លោកត្រូវបង្ហាញមុខងារបម្រើជាបូជាចារ្យ និងជាគង្វាលដ៏ពិតប្រាកដ ឲ្យអ្នកធ្វើជីវិតលើព្រះគ្រីស្ត និងឲ្យអ្នកគ្មានជំនឿលើព្រះអង្គ ទាំងឲ្យគ្រីស្តបរិស័ទកាតូលិក ទាំងឲ្យគ្រីស្តបរិស័ទនិកាយឯទៀតៗ ឃើញកិរិយាមារយាទប្រចាំថ្ងៃរបស់អស់លោក និងឃើញការយកចិត្តទុកដាក់របស់អស់លោកចំពោះមនុស្សទាំងអស់ទៀតដែរ។ ធ្វើដូច្នេះ អស់លោកមុខជានឹងផ្តល់សក្ខីភាពអំពីសេចក្តីពិត និងអំពីជីវិត។ អស់លោកក៏ត្រូវប្រព្រឹត្តដូចគង្វាលដែលស្វែងរកកូនចៀម ( លក ១៥, ៤-៧ ) គឺស្វែងរកអស់អ្នកដែលឈប់ទទួលអគ្គសញ្ញានានា ឬក៏លះបង់ជំនឿដែរ ទោះបីគេបានទទួលអគ្គសញ្ញាជ្រមុជទឹក រួចហើយក៏ដោយ។ **(Lumen Gentium 28)**

**សំណួរ**

តើអស់លោកគង្វាល (បូជាចារ្យ) ទទួលបេសកម្មអ្វីខ្លះ?

តើខ្ញុំស្រឡាញ់អស់លោកគង្វាល (បូជាចារ្យ) ឬយ៉ាងណា? តើខ្ញុំគាំទ្រអស់លោកគង្វាល(បូជាចារ្យ) ឬយ៉ាងណា?

តើត្រូវជួយយុវជនតាមរបៀបណា ឲ្យគេដឹងថាព្រះជាម្ចាស់ត្រាស់ហៅគេឲ្យទៅជា លោកគង្វាល (បូជាចារ្យ)?



## ៤.អស់លោកឧបដ្ឋាក

អស់លោកឧបដ្ឋាកប្ដេជ្ញាចិត្តបម្រើកិច្ចការសម្ដែងធម៌មេត្តាករុណា និងកិច្ចការរដ្ឋបាលរបស់ព្រះសហគមន៍។ អស់លោកត្រូវនឹកពាក្យទូន្មានរបស់សន្ដៈប៉ូលីក័រប៉ុសថា៖ «ត្រូវមានចិត្តមេត្តាករុណា ចិត្តឧស្សាហ៍ ដើរតាមសេចក្ដីពិតរបស់ព្រះអម្ចាស់ដែលព្រះអង្គដាក់ខ្លួនបម្រើមនុស្សទាំងអស់»។ (Lumen Gentium 29)



**សំណួរ**

តើអស់លោកឧបដ្ឋាកមានមុខងារបម្រើពិសេសយ៉ាងណា?

តើអ្វីទៅមុខងារជាឧបដ្ឋាកអចិន្ត្រៃយ៍?

## ៥.គ្រីស្តបរិស័ទធម្មតា

ឈ្មោះ "គ្រីស្តបរិស័ទធម្មតា" ជាគ្រីស្តបរិស័ទដែលមិនបានទទួលអគ្គសញ្ញាតែងតាំងជាអ្នកបម្រើព្រះសហគមន៍ ហើយក៏មិនមែនជាបព្វជិតបព្វជិតា ដែលព្រះសហគមន៍ទទួលស្គាល់ជាផ្លូវការទេ។ "គ្រីស្តបរិស័ទធម្មតា" គឺជាអ្នករួមក្នុងអង្គព្រះគ្រីស្ត ដោយអគ្គសញ្ញា





ជ្រមុជទឹក ទៅជាគ្រីស្តបរិស័ទដែលចូលក្នុងប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ គេរួមចំណែកក្នុងមុខងាររបស់ព្រះគ្រីស្តជាបូជាចារ្យជាព្យាការី និងជាព្រះមហាក្សត្រតាមរបៀបរបស់គេ។ គេបំពេញបេសកកម្មរបស់ប្រជាជនគ្រីស្តបរិស័ទទាំងមូលនៅក្នុងព្រះសហគមន៍ និងនៅក្នុងពិភពលោកតាមចំណែករៀងៗខ្លួន។ **(Lumen Gentium 31)**

ព្រះជាម្ចាស់តែងតាំងចាត់ចែង ហើយណែនាំព្រះសហគមន៍ដ៏វិសុទ្ធ ឲ្យមានបែបបទប្លែកៗពីគ្នាយ៉ាងអស្ចារ្យ ដូចមានចែងថា «រូបកាយមនុស្សយើងមានសរីរាង្គច្រើន។ សរីរាង្គនីមួយៗមានមុខងារប្លែកៗពីគ្នាយ៉ាងណា យើងក៏ដូច្នោះដែរ គឺយើងដែលមានគ្នាច្រើន ក៏រួមជាព្រះកាយតែមួយក្នុងអង្គព្រះគ្រីស្ត ហើយម្នាក់ៗជាសរីរាង្គរបស់គ្នាទៅវិញទៅមកដែរ។» (រម១២,៤-៥)។

ហេតុនេះហើយបានជាមានប្រជារាស្ត្ររបស់ព្រះជាម្ចាស់តែមួយ ដែលព្រះអង្គបានជ្រើសរើស «ព្រះអម្ចាស់មានតែមួយ ជំនឿមានតែមួយ ពិធីជ្រមុជទឹកមានតែមួយ» (អភ ៤,៥)។ សមាជិកនៃប្រជារាស្ត្រនេះមានកិត្តិយសដ៏ថ្លៃថ្នូររួមគ្នា ព្រោះគេសុទ្ធតែកើតជាថ្មីក្នុងអង្គព្រះគ្រីស្ត។ ព្រះបិតាប្រណីសន្តោសឲ្យគេទៅជាបុត្រធីតាដូចគ្នា ព្រះជាម្ចាស់ត្រាស់ហៅគេទាំងអស់គ្នាឲ្យទៅជាគ្រីស្តបរិស័ទពេញលក្ខណៈដូចគ្នា។ មានការសង្គ្រោះតែមួយ មានសេចក្តីសង្ឃឹមតែមួយ មានសេចក្តីស្រឡាញ់តែមួយ ដែលមិនចេះបែកចេញពីគ្នា។ ហេតុនេះហើយបានជានៅក្នុងអង្គព្រះគ្រីស្ត និងក្នុងព្រះសហគមន៍គ្រីស្តបរិស័ទមានកិត្តិយសដ៏ថ្លៃថ្នូរ ស្មើគ្នាទាំងអស់ គ្មានប្រកាន់ជាតិសាសន៍ ឋានៈ វណ្ណៈ ឬភេទឡើយ ដ្បិត «គ្មានសាសន៍យូដា គ្មានសាសន៍ក្រិកទៀតទេ គ្មានទាសករ គ្មានអ្នកជា ហើយក៏គ្មានបុរសគ្មានស្ត្រីទៀតដែរ គឺបងប្អូនទាំងអស់រួមគ្នាមកជាអង្គតែមួយក្នុងព្រះគ្រីស្តយេស៊ូ។» (កឡ ៣,២៨; កូឡ ៣,១១)។ **(Lumen Gentium 32)**

**សំណួរ**

តើអ្វីទៅគ្រីស្តបរិស័ទធម្មតា?

តើគ្រីស្តបរិស័ទធម្មតាមានបេសកកម្មធ្វើអ្វី?

គ្មានបុរស គ្មានស្ត្រី គឺបងប្អូនទាំងអស់រួមគ្នាជាអង្គតែមួយក្នុងព្រះគ្រីស្តយេស៊ូ (កឡ ៣,២៨)។

ក្នុងព្រះសហគមន៍ គ្រីស្តបរិស័ទមានកិត្តិយសដ៏ថ្លៃថ្នូរស្មើគ្នាទាំងអស់ គ្មានប្រកាន់ជាតិសាសន៍ ឋានៈវណ្ណៈ ឬភេទឡើយ។

តើខ្ញុំរស់នៅតាមសកម្មភាពដែលព្រះជាម្ចាស់ សព្វព្រះហឫទ័យយ៉ាងណា?

## ក-គ្រីស្តបរិស័ទធម្មតាជា "បូជាចារ្យ"

ដោយគ្រីស្តបរិស័ទធម្មតាថ្វាយខ្លួនទៅព្រះគ្រីស្ត និងដោយព្រះវិញ្ញាណដ៏វិសុទ្ធចាក់ប្រេងអភិសេកគេ ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទធម្មតាឲ្យមានបេសកកម្មដ៏ល្អប្រសើរ និងមានគ្រប់មធ្យោបាយ បណ្តោយឲ្យព្រះវិញ្ញាណបង្កើតផលកាន់តែច្រើនឡើងៗ នៅក្នុងខ្លួនគេជានិច្ច។ កិច្ចការដែលគេប្រព្រឹត្តប្រចាំថ្ងៃ ការអធិដ្ឋាន សកម្មភាពរបស់គេក្នុងឋានៈជាគ្រីស្តទូត ការរស់នៅក្នុងឋានៈជាគូស្វាមីភរិយា ការរស់នៅក្នុងក្រុមគ្រួសារ ការនឿយហត់សម្រាប់ចិញ្ចឹមជីវិត ការសម្រាកទាំងរូបកាយក្តី ទាំងចិត្តគំនិតក្តី (លុះត្រាតែគេប្រព្រឹត្តការទាំងនោះរួមក្នុងព្រះវិញ្ញាណ) សូម្បីតែទុក្ខលំបាកប្រចាំជីវិត (លុះត្រាតែគេស៊ូទ្រាំដោយអត់ធ្មត់ខន្តី) គឺសុទ្ធតែត្រឡប់ទៅជា «យញ្ញបូជាតាមព្រះវិញ្ញាណជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់ ដោយសារព្រះយេស៊ូគ្រីស្ត» (១សល ២,៥)។ ពេលគេថ្វាយអភិបូជា គេថ្វាយតង្វាយទាំងនោះទៅព្រះបិតារួមជាមួយព្រះកាយព្រះអម្ចាស់ ដោយគោរពប្រណិប័តន៍។ ធ្វើដូច្នេះ គ្រីស្តបរិស័ទធម្មតាដែលរស់នៅបែបវិសុទ្ធ ប្រសិទ្ធិពិភពលោកទាំងមូលឲ្យបានវិសុទ្ធ ថ្វាយទៅព្រះបិតា និងគោរពក្រាបថ្វាយបង្គំព្រះបិតានៅគ្រប់ទីកន្លែង។ **(Lumen Gentium 34)**





**សំណួរ**

ក្នុងការរស់នៅប្រចាំថ្ងៃធម្មតារបស់ខ្ញុំ តើខ្ញុំជាបូជាចារ្យ (អាចារ្យ) យ៉ាងដូចម្តេច?
តើខ្ញុំយកតង្វាយអ្វីមកថ្វាយព្រះបិតា?

## ខ-គ្រីស្តបរិស័ទធម្មតាជា "ព្យាការី"

ព្រះគ្រីស្តជាព្យាការីដ៏ប្រសើរឧត្តម ព្រះអង្គបានប្រកាសព្រះរាជ្យរបស់ព្រះបិតា ដោយយកការរស់នៅរបស់ព្រះអង្គធ្វើជាសក្ខីភាព និងមានព្រះបន្ទូលប្រកបដោយអំណាច។ ព្រះអង្គបំពេញបន្ទុកជាព្យាការីរហូតដល់ពេលព្រះអង្គសម្តែងសិរីរុងរឿងរបស់ព្រះអង្គយ៉ាងពេញលេញនៅគ្រាចុងក្រោយបំផុត។ ព្រះអង្គបន្តបំពេញបន្ទុកនោះ មិនគ្រាន់តែតាមរយៈអស់លោកអភិបាល ដែលបង្រៀនក្នុង



ព្រះនាមព្រះអង្គ និងដែលប្រកបដោយអំណាចរបស់ព្រះអង្គប៉ុណ្ណោះទេ តែព្រះអង្គក៏បន្តបំពេញការងារនេះតាមរយៈគ្រីស្តបរិស័ទធម្មតាដែរ គឺព្រះអង្គតែងតាំងឲ្យគ្រីស្តបរិស័ទទាំងនោះទៅជាសាក្សីរបស់ព្រះអង្គ។ ព្រះអង្គប្រោសឲ្យគេមានជំនឿស្របគ្នាយ៉ាងជ្រៅក្នុងចិត្ត និងអាចថ្លែងព្រះបន្ទូលបានផង (កក ២,១៧-១៨; វវ ១៩,១០) ដើម្បីឲ្យអានុភាពនៃដំណឹងល្អភ្លឺនៅក្នុងការរស់នៅប្រចាំថ្ងៃរបស់មនុស្ស និងក្នុងការរស់នៅជាក្រុមគ្រួសារ និងក្នុងសង្គមទៀតផង។ គ្រីស្តបរិស័ទធម្មតាបង្ហាញខ្លួនទុកជាបុត្រធីតាដែលកើតតាមព្រះបន្ទូលសន្យា ដោយមានជំនឿ និងសេចក្តីសង្ឃឹមរឹងប៉ឹង គេចេះប្រើប្រាស់ពេលវេលានៅសម័យឥឡូវ (អភ ៥,១៦; កូឡ ៤,៥) ហើយព្យាយាមខន្តីទន្ទឹងរង់ចាំសិរីរុងរឿងដែលត្រូវលេចមកនៅពេលខាងមុខ (រម ៨,២៥)។ **(Lumen Gentium 35)**



**សំណួរ**

ក្នុងការរស់នៅធម្មតាប្រចាំថ្ងៃរបស់ខ្ញុំ តើខ្ញុំជា "ព្យាការី" ដូចម្តេច?

តើយើងផ្តល់មធ្យោបាយអ្វី ឲ្យសហគមន៍ទាំងប៉ុន្មាន និងឲ្យម្នាក់ៗអាចស្គាល់ព្រះបន្ទូលរបស់ ព្រះជាម្ចាស់បាន?

ក្នុងការរស់នៅធម្មតាប្រចាំថ្ងៃរបស់ខ្ញុំ ក្នុងក្រុមគ្រួសារ ក្នុងសង្គម តើឫទ្ធានុភាពនៃដំណឹងល្អ អាចលេចភ្លឺឡើង ដូចម្តេចបាន?

## គ-គ្រីស្តបរិស័ទធម្មតាជា "ព្រះមហាក្សត្រ"

...លើសពីនេះទៅទៀត ដោយបម្រើព្រះគ្រីស្តក្នុងការបម្រើអ្នកដទៃ គេអាចណែនាំបងប្អូនរបស់ខ្លួន ទាំងមានចិត្តសុភាពរាបសា និងចិត្តអត់ធ្មត់ខន្តី ទៅគាល់ព្រះមហាក្សត្រ។ អ្នកបម្រើព្រះមហាក្សត្រនេះ ក៏ជាព្រះមហាក្សត្រដែរ។ ព្រះអម្ចាស់សព្វព្រះហឫទ័យលាតសន្ធឹងព្រះរាជ្យរបស់ព្រះអង្គ តាមរយៈគ្រីស្តបរិស័ទធម្មតា គឺក្រោមព្រះរាជ្យនេះ សេចក្តីពិត និងជីវិត ភាពវិសុទ្ធ និងព្រះហឫទ័យប្រណីសន្តោស យុត្តិធម៌ សេចក្តីស្រឡាញ់ និងសន្តិភាពគ្រងរាជ្យហើយ។ **(Lumen Gentium 36)**

ហេតុនេះហើយបានជាគ្រីស្តបរិស័ទត្រូវទទួលស្គាល់លក្ខណៈដ៏ជ្រៅបំផុតនៃសត្វលោកទាំងអស់។ តម្លៃដ៏ថ្លៃថ្នូរ និងទិសដៅនៃសត្វលោកទាំងនោះ គឺលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ គ្រីស្តបរិស័ទក៏ត្រូវជួយគ្នាទៅវិញទៅមកតាមកិច្ចការនៃលោកនេះ

ដើម្បីឲ្យបានរស់នៅតាមរបៀបកាន់តែវិសុទ្ធឡើងៗ។ ព្រះវិញ្ញាណរបស់ព្រះគ្រីស្តនឹងជ្រាបចូលក្នុងពិភពលោក ហើយពិភពលោកឈានទៅកាន់ទិសដៅរបស់ខ្លួនយ៉ាងជោគជ័យ ដោយមានយុត្តិធម៌ សេចក្ដីស្រឡាញ់ និងសន្តិភាព។ **(Lumen Gentium 36)**



**សំណួរ**

ក្នុងការរស់នៅធម្មតាប្រចាំថ្ងៃរបស់ខ្ញុំ តើខ្ញុំជា "ព្រះមហាក្សត្រ" ដូចម្ដេច ?

តើព្រះគ្រីស្តអញ្ជើញយើងឲ្យគ្រងរាជ្យបែបណា ?

តើព្រះសហគមន៍អាចផ្តល់សក្ខីភាពថា ខ្លួនបម្រើនិងស្រឡាញ់អ្នកដទៃ ដោយរកយុត្តិធម៌ សន្តិភាព និងសេចក្ដីពិតបានយ៉ាងណា ?

## ៦.បព្វជិតបព្វជិតា



ព្រះបន្ទូល និងការរស់នៅរបស់ព្រះអម្ចាស់យេស៊ូ ពិតជាគំរូ និងជាគ្រឹះនៃដំបូន្មានដែលមានចែងក្នុងគម្ពីរដំណឹងល្អ គឺឲ្យរស់នៅជាព្រហ្មចារីថ្វាយព្រះជាម្ចាស់ ឲ្យរស់នៅរបៀបអ្នកក្រីក្រ និងឲ្យស្ដាប់តាមបង្គាប់អ្នកដឹកនាំ។ ក្រុមគ្រីស្តទូត ទាំងគ្រូបាធ្យាយ ទាំងបណ្ឌិត និងទាំងគង្វាលព្រះសហគមន៍ ក៏តែងតែផ្ដាំឲ្យរស់នៅតាមបែបនេះដែរ។ ដំបូន្មានដែលចែងក្នុងគម្ពីរដំណឹងល្អ ពិតជាព្រះអំណោយទានដែលព្រះសហគមន៍បានទទួលពីព្រះអម្ចាស់របស់ខ្លួន។ ព្រះសហគមន៍ក៏នៅតែថែរក្សាដំបូន្មានទាំងនោះយ៉ាងស្មោះដោយព្រះអង្គប្រណីសន្ដោស។ **( Lumen Gentium 43)**

គ្រីស្តបរិស័ទណាដែលផ្ញើជីវិតលើព្រះគ្រីស្ត ហើយដែលធ្វើពិធីសច្ចាប្រណិធាន ឬដែលធ្វើពាក្យសន្យាឯទៀតៗ តាមបែបរៀងៗខ្លួន ដែលប្រហាក់ប្រហែលនឹងពាក្យសច្ចាប្រណិធាន គឺគ្រីស្តបរិស័ទនោះបង្ខំចិត្តឲ្យប្រតិបត្តិតាមដំបូន្មានទាំងបីដែលមានចែងក្នុងគម្ពីរដំណឹងល្អ ដូចមានរៀបរាប់នៅខាងលើ។ អ្នកនោះថ្វាយខ្លួនទាំងស្រុងទៅព្រះជាម្ចាស់ដែលខ្លួនស្រឡាញ់លើសអ្វីៗទាំងអស់ ដើម្បីតម្រង់ខ្លួនទៅបម្រើព្រះអម្ចាស់ និងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ក្នុងឋានៈពិសេសថ្មីម៉្យាង។ (...)

ដំបូន្មានដែលចែងក្នុងគម្ពីរដំណឹងល្អ ណែនាំឲ្យគ្រីស្តបរិស័ទមានចិត្តស្រឡាញ់ និងនាំឲ្យអស់អ្នកដែលកាន់តាមបាន រួបរួមយ៉ាង





ពិសេសជាមួយព្រះសហគមន៍ និងជាមួយគម្រោងការដ៏អស្ចារ្យរបស់ព្រះសហគមន៍។ ហេតុនេះហើយការរស់នៅតាមព្រះវិញ្ញាណរបស់គេ ត្រូវតម្រង់ទៅរកប្រយោជន៍ដល់ព្រះសហគមន៍ទាំងមូល។ ដូច្នេះម្នាក់ៗមានភារកិច្ចខិតខំចាក់គ្រឹះ និងពង្រឹងព្រះរាជ្យរបស់ព្រះគ្រីស្តក្នុងចិត្តមនុស្សដោយអស់ពីកម្លាំង តាមសមត្ថភាពរៀងៗខ្លួន និងស្របតាមព្រះជាម្ចាស់ត្រាស់ហៅ ដោយអធិដ្ឋាន និងបំពេញសកម្មភាពផ្សេងៗ។ គេក៏មានភារកិច្ចលាតសន្ធឹងព្រះរាជ្យនោះក្នុងពិភពលោកទាំងមូលដែរ។ ហេតុនេះហើយបានជាព្រះសហគមន៍ការពារ និងគាំទ្រលក្ខណៈពិសេសនៃគ្រឹះស្ថានបព្វជិតបព្វជិតានានា។ **(Lumen Gentium 44)**

**សំណួរ**

តើមានដំបូន្មានអ្វីខ្លះចែងក្នុងគម្ពីរដំណឹងល្អ?
ហេតុអ្វីដំបូន្មានទាំងនោះ ជាសក្ខីភាពយ៉ាងខ្លាំងសម្រាប់មនុស្សលោកនាបច្ចុប្បន្នកាល និងសម្រាប់ព្រះសហគមន៍ផ្ទាល់?
តើខ្ញុំស្គាល់របៀបថ្វាយខ្លួនចំពោះព្រះជាម្ចាស់បែបណាខ្លះ?
ហេតុអ្វីបព្វជិតបព្វជិតាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ព្រះសហគមន៍?
តើត្រូវជួយយុវជនតាមរបៀបណា ឲ្យគេដឹងថាព្រះជាម្ចាស់ត្រាស់ហៅគេឲ្យទៅជាបព្វជិត បព្វជិតា?

# សន្តី ថេរេសាបំភ្លឺយើង

## ខ្ញុំនៅតែមានជំនឿជានិច្ចលើធម៌មេត្តាករុណាជាអនេករបស់ព្រះយេស៊ូ



សម្រេកព្រះយេស៊ូនៅលើឈើឆ្កាង លាន់ឮជានិច្ចក្នុងបេះដូងខ្ញុំ "ខ្ញុំស្រេកទឹក!" ព្រះបន្ទូលនេះបានដុតរោលចិត្តខ្ញុំ ឲ្យខ្លោចផ្សាយ៉ាងខ្លាំង។ ហើយខ្ញុំមានអារម្មណ៍ថា ខ្លួនខ្ញុំស្រេកព្រលឹងជាខ្លាំង...ជាព្រលឹងរបស់អ្នកបាប ខ្ញុំចង់នាំគេចេញពីភ្លើងនរកខ្លាំងណាស់...។

ដើម្បីជំរុញការប្រឹងប្រែងរបស់ខ្ញុំ ព្រះជាម្ចាស់បង្ហាញថា ព្រះអង្គសព្វព្រះហឫទ័យនឹងបំណងនេះ... ខ្ញុំឮគេនិយាយអំពីឧក្រិដ្ឋជនម្នាក់ ត្រូវបានកាត់ទោសប្រហារជីវិត។ គ្រប់គ្នាយល់ថា ឧក្រិដ្ឋជននោះ និងស្លាប់ដោយគ្មានស្ដាយកំហុស។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមិនចង់ឲ្យគាត់ធ្លាក់ទៅស្ថាននរកទេ។ ដើម្បីសម្រេចកិច្ចការនេះ ខ្ញុំបានប្រើគ្រប់មធ្យោបាយ៖ ខ្ញុំបានថ្វាយបុណ្យកុសលច្រើនឥតគណនារបស់ព្រះយេស៊ូ ទ្រព្យសម្បត្តិព្រះសហគមន៍ដ៏វិសុទ្ធ ចំពោះព្រះជាម្ចាស់ ទីបំផុតខ្ញុំអង្វរសេលីនឲ្យថ្វាយអភិបូជាដើម្បីខ្ញុំផង។ ខ្ញុំមិនហ៊ាននិយាយត្រង់ៗប្រាប់សេលីនទេ ខ្ញុំខ្លាចគាត់បន្ទោស ព្រោះតែដើម្បីឧក្រិដ្ឋជនដ៏ល្បីឈ្មោះប្រង់ស៊ីនីនោះទេ។ សេលីនជជីកសួរដោយទន់ភ្លន់ ខ្ញុំមិនអាចលាក់ការអាថ៌កំបាំងនេះបានទៀតទេ ក៏សារភាពប្រាប់គាត់។ ក្រោយពីស្ដាប់សេចក្ដីសារភាពរបស់ខ្ញុំ សេលីនបានសុំខ្លួនចូលរួមជួយកែប្រែចិត្តបាបជននោះថែមទៀតផង។ ខ្ញុំយល់ព្រមដោយរីករាយ ព្រោះខ្ញុំចង់ឲ្យសត្វលោកទាំងអស់រួបរួមគ្នាជាមួយខ្ញុំ ដើម្បីទូលអង្វរសុំការប្រោសប្រណីដល់អ្នកទោស។ ខ្ញុំជឿជាក់ក្នុងចិត្តថា បំណងយើងមុខជាបានសម្រេច។ ព្រះអង្គច្បាស់ជាលើកលែងទោសឲ្យបុរសទុរគតប្រង់ស៊ីនីនេះពុំខានឡើយ។ ទោះជាប្រង់ស៊ីនីមិនព្រមលន់តួ ឬព្រមទទួលកំហុសលើបាបកម្មរបស់ខ្លួនក៏ដោយ ខ្ញុំនៅតែមានជំនឿលើសេចក្ដីមេត្តាករុណាជាអនេករបស់ព្រះយេស៊ូជានិច្ច។ ខ្ញុំសុំតែម៉្យាងគត់ សូមព្រះអង្គបណ្ដាលឲ្យប្រង់ស៊ីនីធ្វើ "សញ្ញាមួយ" ក្នុងការលន់តួអំពើបាបរបស់ខ្លួន ដើម្បីឲ្យខ្ញុំអស់ចិត្ត...។ ការអធិដ្ឋានបន់ស្រន់របស់ខ្ញុំសម្រេចដូចបំណង! ទោះជាពុកហាមអានកាសែតក៏ដោយ ក៏ខ្ញុំមិនបានប្រឆាំងនឹងគាត់ទេ ដោយគ្រាន់តែអានអត្ថបទខ្លះៗនិយាយពីប្រង់ស៊ីនីនោះ។ មួយថ្ងៃក្រោយការពិឃាដ សារពត៌មាននិយាយថា ប្រង់ស៊ីនីមិនព្រមសារភាពកំហុសខ្លួនទេ។ ពេលហៀបនឹងបញ្ចូលក្បាលទៅក្នុងរង្វង់ខ្សែព្យួរទៅហើយ ស្រាប់តែមានអ្វីមួយមកបណ្ដាលចិត្តឲ្យអ្នកទោសងាកក្រោយស្រវាយកឈើឆ្កាងដែលបូជាចារ្យហុចមកឲ្យ ហើយថើបបីដងលើរបួសដ៏ពិសិដ្ឋរបស់ព្រះអង្គ!... បន្ទាប់មកព្រលឹងរបស់គេទៅទទួលសេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់ដែលប្រកាសទៅស្ថានបរមសុខថា ព្រះអង្គត្រេកអរនឹងទទួលព្រលឹងបាបជនតែម្នាក់ ដែលចេះស្ដាយកំហុសរបស់ខ្លួន ជាជាងព្រលឹងជនសុចរិត ៩៩នាក់ ដែលមិនត្រូវការការសូមខមាទោស!...។

*សន្តី ថេរេសា នៃព្រះកុមារយេស៊ូ និងព្រះភក្ត្រដ៏វិសុទ្ធ*



*ថ្ងៃអាទិត្យទី២ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃអាទិត្យទី២០ ខែមករា ឆ្នាំ២០១៣*

# ពិធីមង្គលការនៅភូមិកាណា

*អត្ថបទផ្សេងទៀត៖*
*អស ៦២:១-៥,*
*១ករ ១២:៤-១១,*
*ទន ៩៦*



*យហ ២:១-១១*

*១បីថ្ងៃក្រោយមក មានគេរៀបពិធីមង្គលការនៅភូមិកាណា ក្នុងស្រុកកាលីឡេ។ មាតាព្រះយេស៊ូនៅទីនោះ ២ហើយគេក៏បាន*
*យាងព្រះយេស៊ូ និងអញ្ជើញពួកសាវ័ក *របស់ព្រះអង្គទៅចូលរួមក្នុងពិធីមង្គលការនោះដែរ។ ៣ពេលនោះ គេខ្វះស្រាទំពាំង*
*បាយជូរ។ មាតាព្រះយេស៊ូទូលព្រះអង្គថា៖ «គេអស់ស្រាទំពាំងបាយជូរហើយ!»។ ៤ព្រះយេស៊ូមានព្រះបន្ទូលទៅមាតាថា៖*
*«អ្នកម្ដាយអើយ! កុំរវល់នឹងរឿងនេះអី ពេលកំណត់របស់ខ្ញុំពុំទាន់មកដល់នៅឡើយទេ»។ ៥មាតារបស់ព្រះអង្គប្រាប់ទៅពួក*
*អ្នកបម្រើថា៖ «បើលោកប្រាប់ឲ្យធ្វើអ្វី ចូរធ្វើតាមទៅ»។ ៦នៅទីនោះមានពាងប្រាំមួយ ដែលជនជាតិយូដាដាក់ទឹកសម្រាប់*
*ធ្វើពិធីជម្រះកាយ។ ពាងនីមួយៗមានចំណុះប្រមាណជាពីរបីអំរែក។ ៧ព្រះយេស៊ូមានព្រះបន្ទូលទៅអ្នកបម្រើថា៖ «សុំដងទឹក*
*មកចាក់ឲ្យពេញពាងទាំងនេះទៅ»។ គេក៏ដងទឹកចាក់ពេញពាង។ ៨ព្រះអង្គមានព្រះបន្ទូលថា៖ «ឥឡូវនេះសុំដងយកទៅជូន*
*លោកថៅមហាទៅ» គេក៏ដងយកទៅជូន។ ៩លោកថៅមហាភ្លក់ទឹកដែលបានប្រែមកជាស្រាទំពាំងបាយជូរ។ គាត់មិនដឹងថា*
*គេបានស្រានេះមកពីណាឡើយ មានតែពួកអ្នកបម្រើ ដែលបានដងទឹកមកចាក់ពាងទើបដឹង។ ១០គាត់ហៅកូនកំលោះមក*
*និយាយថា៖ «អ្នកផងទាំងពួង តែងយកស្រាទំពាំងបាយជូរឆ្ងាញ់ មកជូនភ្ញៀវជាមុន លុះភ្ញៀវពិសាច្រើនហើយ ទើបគេយក*
*ស្រាមិនសូវឆ្ងាញ់មកជូនតាមក្រោយ។ រីឯអ្នកវិញ ម្ដេចក៏ទុកស្រាឆ្ងាញ់មកទល់ឥឡូវដូច្នេះ!»។*
*១១នេះជាទីសម្គាល់ដំបូងបង្អស់ ដែលព្រះយេស៊ូបានធ្វើនៅភូមិកាណា ក្នុងស្រុកកាលីឡេ។ ព្រះអង្គបានសម្ដែងសិរីរុងរឿងរបស់*
*ព្រះអង្គ ហើយពួកសាវ័កក៏បានជឿលើព្រះអង្គ។*

-តើពិធីរៀបការនៅភូមិកាណា ជានិមិត្តរូបអំពីអ្វី? តើទឹក និងស្រាជានិមិត្តរូបអំពីអ្វី?
-ដោយសារព្រះនាងម៉ារីគិតគូរដល់កូនកំលោះក្រមុំដែលរៀបការ។ តើសព្វថ្ងៃបងប្អូនគោរពព្រះនាងម៉ារីទុកដូចជានរណា?
-តាមជំនឿរបស់យើង តើអត្ថសញ្ញាអាពាហ៍ពិពាហ៍ជានិមិត្តរូបអំពីអ្វី?

*ថ្ងៃអាទិត្យទី៣ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃអាទិត្យទី២៧ ខែមករា ឆ្នាំ២០១៣*

## ព្រះយេស៊ូចាប់ផ្ដើមផ្សាយដំណឹងល្អនៅស្រុកកាលីឡេ

*អត្ថបទផ្សេងទៀត៖*
*នហ ៨:២-៤ក,*
*៥-៦, ៨-១០*
*១ករ ១២:១២-៣០,*
*ទន ១៩*



***លក ១:១-៤, ៤:១៤-២១***

*[១]សូមជម្រាបមកឯកឧត្ដមថេអូភីល សូមជ្រាប! មនុស្សជាច្រើនខិតខំយកចិត្តទុកដាក់កត់ត្រាទុកនូវហេតុការណ៍ទាំងអំបាល*
*ម៉ាន ដែលកើតមានក្នុងចំណោមយើងខ្ញុំ។ [២]អស់អ្នកដែលបានឃើញផ្ទាល់នឹងភ្នែកតាំងពីដំបូងរៀងមក ហើយទទួលមុខងារ*
*បម្រើព្រះបន្ទូល បានរៀបរាប់ហេតុការណ៍ទាំងនោះបន្តមកយើងខ្ញុំ។ [៣]ខ្ញុំបានពិនិត្យហេតុការណ៍ទាំងនោះ តាំងពីដើមរៀងមក*
*យ៉ាងហ្មត់ចត់ ហើយខ្ញុំក៏យល់ឃើញថា គួរតែកត់ត្រាទុកតាមលំដាប់លំដោយផ្ញើមកជូនលោក។ [៤]ខ្ញុំធ្វើដូច្នេះ ក្នុងគោលបំណង*
*ចង់ឲ្យលោកជ្រាបថា សេចក្ដីប្រៀនប្រដៅទាំងប៉ុន្មាន ដែលលោកបានទទួលពិតជាត្រឹមត្រូវមែន។ [១៤]ព្រះយេស៊ូយាងត្រឡប់ទៅ*
*ស្រុកកាលីឡេវិញ ប្រកបដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណ ព្រះនាមព្រះអង្គឮល្បីល្បាញពាសពេញតំបន់នោះ។ [១៥]ព្រះអង្គបង្រៀន*
*អ្នកស្រុកក្នុងធម្មសាលា * គេសរសើរតម្កើងសិរីរុងរឿងព្រះអង្គគ្រប់ៗគ្នា។ [១៦]ព្រះយេស៊ូយាងទៅភូមិណាសារ៉ែត ជាភូមិដែលព្រះអង្គ*
*គង់នៅកាលពីកុមារ។ នៅថ្ងៃសប្ប័ទ *ព្រះអង្គយាងទៅធម្មសាលា *តាមទម្លាប់របស់ព្រះអង្គ។ ព្រះអង្គក្រោកឈរឡើងដើម្បីអានគម្ពីរ។*
*[១៧]គេបានយកគម្ពីររបស់ព្យាការី*អេសាយមកថ្វាយព្រះអង្គ ព្រះអង្គបើកគម្ពីរត្រង់អត្ថបទមួយដែលមានចែងថា៖ [១៨]«ព្រះវិញ្ញាណ*
*របស់ព្រះអម្ចាស់សណ្ឋិតលើខ្ញុំ។ ព្រះអង្គបានចាក់ប្រេងអភិសេកខ្ញុំ ឲ្យនាំដំណឹងល្អ *ទៅប្រាប់ជនក្រីក្រ។ ព្រះអង្គបានចាត់ខ្ញុំ*
*ឲ្យមកប្រកាសប្រាប់ជនជាប់ជាឈ្លើយថា គេនឹងមានសេរីភាព ហើយប្រាប់មនុស្សខ្វាក់ថា គេនឹងមើលឃើញវិញ។ ព្រះអង្គបាន*
*ចាត់ខ្ញុំឲ្យមករំដោះអស់អ្នកដែលត្រូវគេសង្កត់សង្កិន [១៩]ព្រមទាំងប្រកាសអំពីឆ្នាំដែលព្រះអម្ចាស់សម្ដែងព្រះហឫទ័យមេត្តាករុណា»។*
*[២០]លុះអានចប់ហើយ ព្រះយេស៊ូបិទគម្ពីរប្រគល់ទៅអ្នកថែរក្សា រួចទ្រង់គង់ចុះវិញ។ មនុស្សគ្រប់ៗរូបនៅ ក្នុងធម្មសាលាសម្លឹងមើល*
*ព្រះអង្គ។ [២១]ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ហេតុការណ៍ដែលមានចែងទុកក្នុងគម្ពីរ៖ ដូចអ្នករាល់គ្នាទើបនឹងស្ដាប់អំបាញមិញ*
*បានសម្រេចជារូបរាងនៅថ្ងៃនេះហើយ»។*

-១, ១-៤: តើសេចក្ដីទាំងនោះ ជួយពង្រឹងជំនឿរបស់បងប្អូនលើព្រះយេស៊ូយ៉ាងណា?
-តើពាក្យជនក្រីក្រ ជនជាប់ជាឈ្លើយ មនុស្សខ្វាក់ អ្នកដែលត្រូវគេសង្កត់សង្កិន សំដៅលើអ្វី? លើនរណានាពេលសព្វថ្ងៃ?
-៤, ២១ : តើមានអត្ថន័យយ៉ាងណា? និងពង្រឹងជំនឿរបស់បងប្អូនលើព្រះយេស៊ូយ៉ាងណា?

## ថ្ងៃអាទិត្យទី៤ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃអាទិត្យទី៣ ខែកុម្ភៈ ឆ្នាំ២០១៣

# អ្នកភូមិណាសារ៉ែតបដិសេធមិនព្រមទទួលព្រះអង្គ

អត្ថបទផ្សេងទៀត៖
យរ ១:៤-៥,
១៧-១៩ ១ករ
១២:៣១-១៣:១៣,
ទន ៧១



**លក ៤:២១-៣០**

២១ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ហេតុការណ៍ដែលមានចែងទុកក្នុងគម្ពីរ ដូចអ្នករាល់គ្នាទើបនឹងស្ដាប់អំបាញមិញ បានសម្រេច
ជារូបរាងនៅថ្ងៃនេះហើយ»។ ២២ឮដូច្នេះ គេស្ងើចសរសើរ ព្រះយេស៊ូគ្រប់ៗគ្នា ទាំងនឹកឆ្ងល់អំពីព្រះបន្ទូលប្រកបដោយព្រះហឫទ័យ
ប្រណីសន្ដោស ដែលហូរចេញពីព្រះឱស្ឋរបស់ព្រះអង្គ។ គេពោលថា៖ «អ្នកនេះមិនមែនជាកូនរបស់ជាងយ៉ូសែបទេឬ?»។
២៣ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ប្រហែលជាអ្នករាល់គ្នាចង់យកសុភាសិត ដែលចែងថា "គ្រូពេទ្យអើយ ចូរមើលជំងឺ
របស់ខ្លួនឲ្យជាសិនទៅ" មកផ្ចាញ់ផ្ចាលខ្ញុំទេដឹង! ឬមួយអ្នករាល់គ្នាចង់និយាយមកខ្ញុំទៀតថា "យើងឮគេនិយាយអំពីកិច្ចការទាំង
អស់ដែលអ្នកធ្វើនៅក្រុងកាផានុម ចូរធ្វើការដដែលនៅទីនេះជាស្រុកកំណើតរបស់អ្នកឲ្យយើងឃើញផង!"»។ ២៤ព្រះអង្គមាន
ព្រះបន្ទូលទៀតថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា មិនដែលមានព្យាការី*ណាម្នាក់ ត្រូវគេគោរពនៅក្នុងស្រុកកំណើត
របស់ខ្លួនឡើយ។ ២៥ខ្ញុំសុំបញ្ជាក់ថា នៅជំនាន់លោកអេលី មេឃរាំងអស់រយៈពេលបីឆ្នាំកន្លះ បណ្ដាលឲ្យមានទុរ្ភិក្សយ៉ាងខ្លាំងពេញ
ទាំងស្រុក។ នៅស្រុកអ៊ីស្រាអែល មានស្ត្រីម៉េមាយជាច្រើន។ ២៦ក៏ប៉ុន្តែព្រះជាម្ចាស់ពុំបានចាត់ព្យាការីអេលីឲ្យទៅជួយស្ត្រី
មេម៉ាយណាម្នាក់នៅស្រុកអ៊ីស្រាអែលឡើយ គឺព្រះអង្គបានចាត់លោកឲ្យទៅជួយស្ត្រីមេម៉ាយម្នាក់ ដែលរស់នៅភូមិសារិបតា
ក្នុងក្រុងស៊ីដូនវិញ។ ២៧នៅជំនាន់ព្យាការីអេលីសេ មានមនុស្សឃ្លង់ជាច្រើន ក្នុងស្រុកអ៊ីស្រាអែល ប៉ុន្តែគ្មានអ្នកណាម្នាក់បាន
ជាសះឡើយ គឺមានតែលោកណាម៉ាន់ជាជនជាតិស៊ីរីម្នាក់ប៉ុណ្ណោះ»។ ២៨កាលបានឮព្រះបន្ទូលទាំងនេះ អ្នកនៅក្នុងធម្មសាលា
*ទាំងប៉ុន្មាន ខឹងព្រះយេស៊ូគ្រប់ៗគ្នា។ ២៩គេក្រោកឡើងចាប់ប្រអូសប្រទាញព្រះយេស៊ូចេញពីភូមិដែលសង់លើកំពូលភ្នំ នាំឆ្ពោះ
ទៅមាត់ជ្រោះ បម្រុងនឹងច្រានព្រះអង្គទម្លាក់ទៅក្រោម។ ៣០ប៉ុន្តែ ព្រះអង្គយាងចេញពីកណ្ដាលចំណោមគេបាត់ទៅ។

-តើសព្វថ្ងៃបងប្អូនមានបទពិសោធន៍នឹងពាក្យគេជំទាស់ជាមួយគ្រីស្តសាសនាយើងយ៉ាងណា?

-សូមបងប្អូនរកមើលសញ្ញាសម្គាល់ផ្សេងៗ ដែលបញ្ជាក់ថា ព្រះជាម្ចាស់ស្រឡាញ់មនុស្សគ្រប់ជាតិសាសន៍ពិតមែន ហើយ
អរព្រះគុណព្រះអង្គផង។ -តើអត្ថបទនេះបង្រៀនអ្វីដល់បងប្អូនអំពីព្រះយេស៊ូ? និងអំពីព្រះជាម្ចាស់?

*ថ្ងៃអាទិត្យទី៥ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃអាទិត្យទី១០ ខែកុម្ភៈ ឆ្នាំ២០១៣*

# ព្រះយេស៊ូត្រាស់ហៅសាវ័កបីរូប

*លក ៥:១-១១*

*១ថ្ងៃមួយ ព្រះយេស៊ូគង់នៅមាត់បឹងកេនេសារ៉ែត មានបណ្ដាជនជាច្រើនប្រជ្រៀតគ្នានៅជុំវិញព្រះអង្គ ដើម្បីស្ដាប់ព្រះបន្ទូល*
*របស់ព្រះជាម្ចាស់។ ២ព្រះអង្គទតឃើញទូកពីរចតនៅមាត់ច្រាំង រីឯអ្នកនេសាទនាំគ្នាចុះទៅលាងអួនរបស់គេ។ ៣ព្រះយេស៊ូ*
*យាងចុះទៅក្នុងទូករបស់លោកស៊ីម៉ូន រួចទ្រង់សុំឲ្យគាត់ចេញទូកទៅឆ្ងាយពីច្រាំងបន្តិច។ ព្រះអង្គគង់បង្រៀនបណ្ដាជនពីក្នុង*
*ទូកនោះ។ ៤លុះព្រះអង្គបង្រៀនគេចប់ហើយ ទ្រង់មានព្រះបន្ទូលទៅកាន់លោកស៊ីម៉ូនថា៖ «ចូរបង្ហូសទូកទៅទឹកជ្រៅ រួចនាំ*
*គ្នាទម្លាក់អួនចុះ»។ ៥លោកស៊ីម៉ូនតបទៅព្រះយេស៊ូវិញថា៖ «លោកគ្រូ! យើងខ្ញុំបានអូសអួនពេញមួយយប់ហើយ អត់បានត្រី*
*សោះ ប៉ុន្ដែបើលោកគ្រូមានប្រសាសន៍ដូច្នេះ ខ្ញុំនឹងទម្លាក់អួនតាមពាក្យរបស់លោកគ្រូ»។ ៦គេក៏ទម្លាក់អួនទៅក្នុងទឹកជាប់ត្រី*
*យ៉ាងច្រើន ស្ទើរតែធ្លាយអួន។ ៧គេបក់ដៃហៅមិត្តភក្ដិដែលនៅក្នុងទូកមួយទៀតឲ្យមកជួយ។ ពួកនោះមកដល់ ជួយចាប់ត្រីដាក់*
*ពេញទូកទាំងពីរស្ទើរតែនឹងលិច។ ៨ពេលលោកសិលាឃើញដូច្នោះ គាត់ក្រាបទៀប ព្រះបាទាព្រះយេស៊ូ ទូលព្រះអង្គថា៖*
*«ព្រះអម្ចាស់អើយ សូមយាងឲ្យឆ្ងាយពីទូលបង្គំទៅ ព្រោះទូលបង្គំជាមនុស្សបាប»។ ៩លោកស៊ីម៉ូននិយាយដូច្នេះ ព្រោះគាត់*
*និងអស់អ្នកដែលនៅជាមួយ ភ័យស្ញប់ស្ញែងជាខ្លាំង នៅពេលបានឃើញត្រីច្រើនយ៉ាងនេះ។ ១០រីឯលោកយ៉ាកុប និងលោក*
*យ៉ូហានជាកូនលោកសេបេដេ ដែលនេសាទរួមជាមួយលោកស៊ីម៉ូន ក៏មានចិត្តដូច្នោះដែរ។ ប៉ុន្ដែ ព្រះយេស៊ូមានព្រះបន្ទូលទៅ*
*លោកស៊ីម៉ូនថា៖ «កុំខ្លាចអី! ពីពេលនេះទៅមុខ អ្នកនឹងនេសាទមនុស្សវិញ»។ ១១ពេលទូកទៅដល់មាត់ច្រាំងវិញ គេបោះបង់*
*របស់របរទាំងអស់ចោល រួចនាំគ្នាដើរតាមព្រះយេស៊ូទៅ។*

-តើទូករបស់សន្ដៈសិលា និងសមុទ្រជានិមិត្តរូបអំពីអ្វី?

-ពេលសន្ដៈសិលាសុខចិត្តទម្លាក់អួនចុះទឹកតាមព្រះបញ្ជារបស់ព្រះយេស៊ូ ពេលនោះបានត្រីជាច្រើន។ តើសេចក្ដីនេះបង្រៀនអ្វីដល់បងប្អូន?

-តើបងប្អូនធ្លាប់មានបទពិសោធន៍ដូចសន្ដៈសិលាដែរទេ ដោយដឹងថាទោះបីខ្លួនជាអ្នកបាប តែព្រះយេស៊ូនៅតែទុកចិត្តលើបងប្អូន និងត្រាស់ហៅឲ្យបងប្អូនបំពេញបេសកម្មមួយ? ចូរអរព្រះគុណព្រះយេស៊ូដោយអស់ពីចិត្ត។

*អត្ថបទផ្សេងទៀត៖*
*អស ៦:១-២ក, ៣-៨*
*១ករ ១៥:១-១១,*
*ទន ១៣៨*



## ថ្ងៃអាទិត្យទី១ ក្នុងរដូវសែសិបថ្ងៃ ត្រូវនឹងថ្ងៃអាទិត្យទី១៧ ខែកុម្ភៈ ឆ្នាំ២០១៣

# ព្រះយេស៊ូឈ្នះការល្បួង

*អត្ថបទផ្សេងទៀត៖*
*ទក ២៦:៤-១០,*
*រម ១០:៨-១៣,*
*ទន ៩១*



*លក ៤:១-១៣*

១ព្រះយេស៊ូបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ * ព្រះអង្គយាងត្រឡប់ពីទន្លេយ័រដាន់មកវិញ ហើយព្រះវិញ្ញាណនាំព្រះអង្គ
ទៅវាលរហោស្ថាន។ ២នៅទីនោះ ព្រះអង្គត្រូវមារ *សាតាំងល្បួង អស់រយៈពេលសែសិបថ្ងៃ។ ក្នុងអំឡុងពេលនោះ ព្រះអង្គ
ពុំសោយអ្វីឡើយ។ លុះផុតពីពេល នោះទៅ ទើបទ្រង់ឃ្លាន។ ៣មារ *ទូលព្រះអង្គថា៖ «ប្រសិនបើលោកពិតជាព្រះបុត្រារបស់
ព្រះជាម្ចាស់មែន សូមធ្វើឲ្យដុំថ្មនេះទៅជានំប៉័ងមើល៍»។ ៤ព្រះយេស៊ូមានព្រះបន្ទូលតបទៅវិញថា៖ «ក្នុងគម្ពីរមានចែងថា
មនុស្សមិនមែនរស់ដោយសារតែអាហារប៉ុណ្ណោះទេ»។ ៥មារនាំព្រះអង្គទៅកន្លែងមួយដ៏ខ្ពស់ ហើយចង្អុលបង្ហាញនគរទាំង
ប៉ុន្មាននៅលើផែនដី ឲ្យព្រះអង្គឃើញក្នុងមួយរយៈពេលដ៏ខ្លី។ ៦មារសាតាំងទូលព្រះអង្គថា៖ «ខ្ញុំនឹងប្រគល់អំណាច ព្រមទាំង
ភោគទ្រព្យរបស់ នគរទាំងនោះឲ្យលោក ដ្បិតអ្វីៗទាំងអស់ជាសម្បត្តិរបស់ខ្ញុំ ខ្ញុំអាចប្រគល់ឲ្យអ្នកណាក៏បាន ស្រេច តែនឹងចិត្តខ្ញុំ។
៧ដូច្នេះប្រសិនបើលោកក្រាបថ្វាយបង្គំខ្ញុំ សម្បត្តិទាំងនោះនឹងបានជារបស់លោកហើយ»។ ៨ព្រះយេស៊ូមានព្រះបន្ទូលតប
ទៅវិញថា៖ «ក្នុងគម្ពីរមានចែងថា "អ្នកត្រូវតែថ្វាយបង្គំព្រះអម្ចាស់ *ជាព្រះរបស់អ្នក និងគោរពបម្រើតែព្រះអង្គមួយប៉ុណ្ណោះ"»។
៩បន្ទាប់មក មារនាំព្រះអង្គទៅក្រុងយេរូសាឡឹមដាក់ព្រះអង្គលើកំពូលព្រះវិហារ * ហើយទូលថា៖ «ប្រសិនបើលោកពិតជាព្រះបុត្រា
របស់ព្រះជាម្ចាស់មែន សូមលោតទម្លាក់ខ្លួនចុះទៅក្រោមមើល៍ ១០ដ្បិតក្នុងគម្ពីរមានចែងថា "ព្រះជាម្ចាស់នឹងបញ្ជាឲ្យទេវទូត *
ថែរក្សាលោក ១១ហើយទេវទូតទាំងនោះ នឹងចាំទ្រលោកមិនឲ្យជើងលោកប៉ះទង្គិចនឹងថ្មឡើយ"»។ ១២ព្រះយេស៊ូមានព្រះបន្ទូល
តបទៅមារវិញថា៖ «ក្នុងគម្ពីរមានចែងថា កុំល្បងលព្រះអម្ចាស់ជាព្រះរបស់អ្នកឡើយ»។ ១៣លុះមារល្បួង ព្រះយេស៊ូសព្វ
បែបយ៉ាង ហើយវាក៏ថយចេញឆ្ងាយពីព្រះអង្គទៅ រហូតដល់ពេលកំណត់។

-ក្នុងព្រះគម្ពីរ តើលេខ៤០មានអត្ថន័យយ៉ាងណា?
-តើមារល្បួងព្រះយេស៊ូអំពីអ្វីខ្លះ? តើព្រះអង្គឈ្នះមារតាមរបៀបយ៉ាងណា? ចុះបងប្អូនវិញ ធ្លាប់មារល្បួងយ៉ាងណាខ្លះ?
តើបងប្អូនជំទាស់នឹងការល្បួងរបស់មារតាមរបៀបយ៉ាងណាដែរ?

# សិរីរុងរឿងរបស់ព្រះយេស៊ូ

*លូក ៩:២៨ខ-៣៦*

*[២៨]ព្រះអង្គនាំលោកសិលា លោកយ៉ូហាន និងលោកយ៉ាកុបឡើងទៅលើភ្នំ ដើម្បីអធិដ្ឋាន *។ [២៩]ពេលកំពុងអធិដ្ឋាន ស្រាប់តែព្រះភ័ក្ត្ររបស់ព្រះអង្គប្រែជាមានរស្មី ហើយព្រះពស្ត្ររបស់ព្រះអង្គ ត្រឡប់ជាមានពណ៌សត្រចះត្រចង់។ [៣០]ពេលនោះ មានបុរសពីរនាក់ គឺលោកម៉ូសេ និងព្យាការីអេលីសន្ទនាជាមួយព្រះយេស៊ូ។ [៣១]លោកទាំងពីរលេចមក ប្រកបដោយសិរីរុងរឿង ហើយមានប្រសាសន៍អំពីដំណើរដែលព្រះអង្គត្រូវសោយទិវង្គតនៅក្រុងយេរូសាឡឹម។ [៣២]លោកសិលា និងមិត្តភក្តិរបស់លោកសម្រាន្តលង់លក់។ លុះភ្ញាក់ឡើង គេឃើញសិរីរុងរឿងរបស់ព្រះយេស៊ូ និងឃើញលោកទាំងពីរឈរជាមួយព្រះអង្គ។ [៣៣]កាលលោកម៉ូសេ និងព្យាការីអេលីកំពុងតែចាកចេញពីព្រះយេស៊ូទៅ លោកសិលាទូលព្រះអង្គថា៖ «ព្រះគ្រូ! យើងខ្ញុំបាននៅទីនេះប្រសើរណាស់ យើងខ្ញុំនឹងសង់ជម្រកបី គឺមួយសម្រាប់ព្រះគ្រូ មួយសម្រាប់លោកម៉ូសេ និងមួយទៀតសម្រាប់ព្យាការីអេលី»។ លោកសិលាមានប្រសាសន៍ទាំងពុំដឹងថា ខ្លួននិយាយអ្វីឡើយ។ [៣៤]កាលលោក សិលាកំពុងតែមានប្រសាសន៍ ស្រាប់តែមានពពក *មកគ្របបាំងគេទាំងអស់គ្នា ធ្វើឲ្យសាវ័កភ័យខ្លាចក្រៃលែង ដោយមានពពកមកគ្របបាំងដូច្នេះ។ [៣៥]មានព្រះសូរសៀងបន្លឺពីក្នុងពពកមកថា៖ «ព្រះអង្គនេះជាបុត្រដែលយើងបានជ្រើសរើស ចូរស្ដាប់ព្រះអង្គចុះ!»។ [៣៦]បន្ទាប់ពីបាន ឮព្រះសូរសៀងនេះហើយ គេឃើញតែព្រះយេស៊ូមួយព្រះអង្គប៉ុណ្ណោះ។ នៅគ្រានោះ សាវ័កឥតបាននិយាយអំពីហេតុការណ៍ដែលគេបានឃើញ ប្រាប់អ្នកណាសោះឡើយ។*

-តើភ្នំជានិមិត្តរូបអំពីអ្វី?

-តើលោកម៉ូសេ និងព្យាការីអេលីមានប្រសាសន៍អ្វីអំពីព្រះយេស៊ូ?

-តើព្រះសូរសៀងបន្លឺពីក្នុងពពកមកថាយ៉ាងដូចម្ដេច? តើអត្ថបទនេះពង្រឹងជំនឿរបស់បងប្អូនលើព្រះយេស៊ូយ៉ាងណា?

*អត្ថបទផ្សេងទៀត៖*
*កណ ១៥:៥-១២, ១៧-១៨,*
*ភីល ៣:១៧-៤:១,*
*ទន ២៧*



## ថ្ងៃអាទិត្យទី៣ ក្នុងរដូវសែសិបថ្ងៃ ត្រូវនឹងថ្ងៃអាទិត្យទី៣ ខែមីនា ឆ្នាំ២០១៣

# ត្រូវកែប្រែចិត្តគំនិត

*អត្ថបទផ្សេងទៀត៖*
*សរ ៣:១-៨ក,*
*១៣-១៥, ១ករ*
*១០:១-៦, ១០-១២,*
*ទន ១០៣*



*លក ១៣:១-៩*

*១ពេលនោះ មានអ្នកខ្លះមកទូលព្រះយេស៊ូអំពីអ្នកស្រុកកាលីឡេ ដែលលោកពីឡាតបានសម្លាប់ នៅពេលគេកំពុងតែថ្វាយ*
*យញ្ញបូជា។ ២ព្រះយេស៊ូមានព្រះបន្ទូលទៅគេវិញថា៖ «តើអ្នករាល់គ្នាស្មានថា អ្នកស្រុកកាលីឡេទាំងនោះ ជាមនុស្សបាប*
*ច្រើនជាងអ្នកស្រុកកាលីឡេឯទៀតៗ ឬបានជាគេស្លាប់របៀបនេះ? ៣ទេ មិនមែនទេ! ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា បើអ្នករាល់គ្នា*
*មិនកែប្រែ ចិត្តគំនិតទេ អ្នករាល់គ្នានឹងត្រូវវិនាសអន្តរាយដូចគេមិនខាន។ ៤ចុះមនុស្សដប់ប្រាំបីនាក់ដែលបានស្លាប់ ដោយ*
*ប៉មស៊ីឡោមរលំសង្កត់លើ តើអ្នករាល់គ្នាស្មានថា អ្នកទាំងនោះមានទោសធ្ងន់ ជាងអ្នកក្រុងយេរូសាឡឹមឯទៀតៗឬ? ៥ទេ*
*មិនមែនទេ! ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា បើអ្នករាល់គ្នាមិនកែប្រែចិត្តគំនិតទេ អ្នករាល់គ្នានឹងត្រូវវិនាសអន្តរាយដូច្នោះដែរ»។*
*៦បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលជាប្រស្នានេះទៅគេថា៖ «មានឧទុម្ពរ*មួយដើមដុះក្នុងចម្ការបុរសម្នាក់។ ម្ចាស់ចម្ការ*
*មករកបេះផ្លែពីដើមឧទុម្ពរនោះ តែគ្មានផ្លែសោះ ៧គាត់ក៏ប្រាប់អ្នកថែចម្ការថា៖ «មើល៍ ខ្ញុំមករកបេះផ្លែឧទុម្ពរនេះបីឆ្នាំហើយ*
*តែមិនឃើញមានផ្លែសោះ។ ចូរកាប់វាចោលទៅ ទុកនាំតែខាតដីទេ!»។ ៨អ្នកថែចម្ការឆ្លើយតបថា៖ «សូមលោកទុកវាមួយឆ្នាំ*
*ទៀតសិន ចាំខ្ញុំជួយដីជុំវិញ ហើយដាក់ជី។ ៩ប្រហែលជាឆ្នាំក្រោយនឹងមានផ្លែ បើមិនផ្លែទេ សឹមកាប់វាចោលទៅចុះ!»។*

-តាមបងប្អូនយល់ តើព្រះយេស៊ូចង់ពន្យល់យ៉ាងណាអំពីទុក្ខលំបាក អំពីគ្រោះកាចផ្សេងៗ និងសេចក្តីស្លាប់របស់មនុស្ស យើង? តើទុក្ខលំបាក គ្រោះថ្នាក់ផ្សេងៗក្នុងការរស់នៅ ពង្រឹង ជំនឿរបស់បងប្អូនលើព្រះយេស៊ូយ៉ាងណា?

-តើខ្ញុំគិតយ៉ាងណាអំពីលោកនេះ និងលោកខាងមុខ?

## ថ្ងៃអាទិត្យទី៤ ក្នុងរដូវសែសិបថ្ងៃ ត្រូវនឹងថ្ងៃអាទិត្យទី១០ ខែមីនា ឆ្នាំ២០១៣

# ប្រស្នាអំពីចៀមដែលបាត់ហើយរកឃើញវិញ

*លក ១៥:១-៣, ១១-៣២*

*¹មានអ្នកទារពន្ធ* និងមនុស្សបាបទាំងអស់នាំគ្នាចូលមកជិតព្រះយេស៊ូ ស្ដាប់ព្រះបន្ទូលរបស់ព្រះអង្គ។ ²ពួកខាងគណៈ
ផារីស៊ី* និងពួកធម្មាចារ្យ*រអ៊ូរទាំថា៖ «មើល៍! អ្នកនេះរាក់ទាក់នឹងមនុស្សបាប ព្រមទាំងបរិភោគជាមួយគេផង!»។ ³ព្រះ
យេស៊ូមានព្រះបន្ទូលទៅគេជាប្រស្នានេះថា៖ ¹¹«មានបុរសមួយរូបមានកូនប្រុសពីរនាក់។ ¹²កូនពៅនិយាយទៅឪពុកថា
"លោកឪពុក! សូមចែកកេរមត៌កឲ្យកូនមក"។ ឪពុកក៏ចែកមត៌កឲ្យកូន។ ¹³ប៉ុន្មានថ្ងៃក្រោយមក កូនពៅប្រមូល ទ្រព្យសម្បត្តិ
រួចចាកចេញទៅស្រុកឆ្ងាយ។ នៅស្រុកនោះកូនពៅបានខ្ជះខ្ជាយ បង្ហិនទ្រព្យសម្បត្តិ របស់ខ្លួនអស់ទៅ។ ¹⁴ពេលចាយវាយទ្រព្យ
សម្បត្តិអស់ហើយ ជួនជាកើតទុរ្ភិក្សយ៉ាងខ្លាំងនៅក្នុងស្រុក កូនពៅនោះចាប់ផ្ដើមខ្វះខាត។ ¹⁵គាត់ក៏ទៅស៊ីឈ្នួលអ្នកស្រុក
ម្នាក់ គេប្រើគាត់ឲ្យមើលជ្រូកតាមស្រែចម្ការ។ ¹⁶គាត់ចង់ចម្អែតក្រពះនឹងចំណីដែលគេដាក់ឲ្យជ្រូកស៊ីនោះណាស់ តែគ្មាន
អ្នកណាឲ្យបរិភោគឡើយ។ ¹⁷ពេលនោះកូនពៅភ្ញាក់ខ្លួន ហើយរិះគិតក្នុងចិត្តថា "អ្នកបម្រើ របស់ឪពុកអញ សុទ្ធតែមានម្ហូប
អាហារបរិភោគហូរហៀរទាំងអស់គ្នា រីឯនៅទីនេះវិញ អញសឹង តែដាច់ពោះស្លាប់។ ¹⁸អញត្រូវតែវិលត្រឡប់ទៅរកឪពុកអញ
វិញ ហើយជម្រាបគាត់ថា លោកឪពុកកូនបានប្រព្រឹត្តអំពើបាប ខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ កូនក៏បានប្រព្រឹត្ត
អំពើបាបខុសនឹងលោកឪពុកដែរ។ ¹⁹មិនគួរឲ្យលោកឪពុករាប់ខ្ញុំនេះជាកូនទៀតទេ សូមលោកឪពុក ចាត់ទុកកូនជាអ្នកបម្រើ
ចុះ"។ ²⁰លុះគិតដូច្នោះហើយ កូនពៅក៏វិលត្រឡប់ទៅរកឪពុកវិញ។ កាលឪពុកឃើញកូនពីចម្ងាយ គាត់មានចិត្តអាណិត
អាសូរក្រៃលែង ក៏រត់ទៅទទួលកូន ហើយឱបថើបទៀតផង។ ²¹កូនពៅជម្រាបឪពុកថា៖ "លោកឪពុក កូនបានប្រព្រឹត្តអំពើ
បាបខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ កូនក៏បានប្រព្រឹត្តអំពើបាបខុសនឹងលោកឪពុកដែរ មិនគួរឲ្យលោកឪពុករាប់ខ្ញុំ
នេះជាកូនទៀតទេ"។ ²²ឪពុកប្រាប់ពួកអ្នកបម្រើថា "ចូរទៅយកសម្លៀកបំពាក់ ល្អៗបំផុត មកពាក់ឲ្យកូនខ្ញុំជាប្រញាប់ ហើយ
យកចិញ្ចៀន និងស្បែកជើងមកពាក់ឲ្យផង។ ²³ចូរយកកូនគោដែលយើងបានបំប៉នទុក មកកាប់ជប់លៀងឲ្យសប្បាយចុះ
²⁴ដ្បិតកូនខ្ញុំនេះបានស្លាប់ទៅហើយ តែឥឡូវរស់ឡើងវិញ វារវង្វេងបាត់ តែឥឡូវនេះ ខ្ញុំរកឃើញវិញហើយ"។ គេនាំគ្នាជប់
លៀងយ៉ាងសប្បាយ។ ²⁵ពេលនោះ កូនច្បងនៅឯចម្ការ។ កាលគាត់ត្រឡប់មកជិតដល់ផ្ទះវិញ ឮស្នូរតូរ្យតន្ត្រី និងចម្រៀង*

*អត្ថបទផ្សេងទៀត៖*
*យស ៥:៩ក,*
*១០-១២,*
*២ករ ៥:១៧-២១,*
*ទន ៣៤*



អត្ថបទផ្សេងទៀត៖
យស ៥:៩ក,
១០-១២,
២ករ ៥:១៧-២១,
ទន ៣៤



## ថ្ងៃអាទិត្យទី៤ ក្នុងរដូវសែសិបថ្ងៃ ត្រូវនឹងថ្ងៃអាទិត្យទី១០ ខែមីនា ឆ្នាំ២០១៣

របាំ ២៦គាត់ហៅអ្នកបម្រើម្នាក់មកសួរថាមានការអ្វីកើតឡើង។ ២៧អ្នកបម្រើឆ្លើយថា "ប្អូនលោកត្រឡប់មកវិញហើយ។ ឪពុក
របស់លោកឲ្យគេកាប់ កូនគោដែលយើងបំប៉ននោះ ព្រោះកូនពៅរបស់លោកបានត្រឡប់មកវិញដោយសុខសាន្ត"។ ២៨កូន
ច្បងខឹងណាស់ មិនព្រមចូលផ្ទះទេ ឪពុកចេញមកអង្វរឲ្យចូល។ ២៩កូនច្បងនិយាយទៅឪពុកថា "ខ្ញុំបាននៅបម្រើលោកជា
ច្រើនឆ្នាំមកហើយ ខ្ញុំមិនដែលធ្វើខុសនឹងបង្គាប់របស់លោកត្រង់ណាឡើយ តែលោកមិនដែលឲ្យកូនពពែ ដើម្បីឲ្យខ្ញុំកាប់ជប់
លៀងជាមួយមិត្តភក្តិទាល់តែសោះ សូម្បីតែមួយក៏មិនដែលផង។ ៣០ពេលកូនលោកត្រឡប់មកវិញ លោកបានកាប់កូនគោ
បំប៉នទទួលវា មើល៍វានេះ បានបំផ្លាញទ្រព្យសម្បត្តិលោកទាំងអស់ជាមួយស្រីញី"។ ៣១ឪពុកនិយាយទៅកូនថា "កូនអើយ
ឯងនៅជាមួយឪពុកជានិច្ចរហូតណាកូន អ្វីៗទាំងអស់ដែលជារបស់ឪពុក ក៏ជារបស់កូនដែរ។ ៣២យើងត្រូវតែសប្បាយរីករាយ
ដ្បិតប្អូនរបស់ឯងដែលបានស្លាប់ទៅនោះ ឥឡូវនេះរស់ឡើងវិញហើយ។ វាបានវង្វេងបាត់ តែឥឡូវនេះយើងរកឃើញវិញ
ហើយ"»។

-ក្នុងអត្ថបទនេះតើតួសំខាន់ជាងគេគឺនរណា ?
-តើកូនពៅគិតអ្វីអំពីឪពុក និងអំពីបងរបស់ខ្លួន ? តើកូនច្បងគិតអ្វីអំពីឪពុក និងអំពីប្អូនរបស់ខ្លួន ?
-តើឪពុកមានឥរិយាបថយ៉ាងណាចំពោះកូនទាំងពីរ ? តើបងប្អូនជានរណាក្នុងអត្ថបទនេះ ?
-តើអត្ថបទនេះនាំឲ្យបងប្អូនយល់អ្វីអំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ ?

## ថ្ងៃអាទិត្យទី៥ ក្នុងរដូវសែសិបថ្ងៃ ត្រូវនឹងថ្ងៃអាទិត្យទី១៧ ខែមីនា ឆ្នាំ២០១៣

# ស្ត្រីម្នាក់ប្រព្រឹត្តសហាយស្មន់

*យហ ៨:១-១១*

*១ព្រះយេស៊ូយាងទៅភ្នំដើមអូលីវ ២លុះព្រលឹមឡើង ព្រះអង្គវិលត្រឡប់ទៅព្រះវិហារជាថ្មីម្ដងទៀត ប្រជាជនទាំងមូលនាំគ្នាមក*
*គាល់ព្រះអង្គ ព្រះអង្គក៏គង់បង្រៀនពួកគេ។ ៣ពេលនោះ ពួកធម្មាចារ្យ * និងពួកខាងគណៈផារីស៊ី *នាំស្ត្រីម្នាក់ដែលគេទាន់កំពុង*
*តែរួមសហាយស្មន់។ គេយកនាងនោះមកដាក់កណ្ដាលចំណោមប្រជុំជន ៤ហើយទូលព្រះយេស៊ូថា៖ «លោកគ្រូយើងចាប់*
*ស្ត្រីនេះបាន ក្នុងពេលកំពុងរួមសហាយស្មន់។ ៥ក្នុងគម្ពីរលោកម៉ូសេបានបង្គាប់ឲ្យយើងយកដុំថ្មគប់ស្ត្រីប្រភេទ នេះសម្លាប់*
*ចោល។ ចុះលោកគ្រូវិញ តើលោកគ្រូគិតយ៉ាងណា?»។ ៦ពួកគេទូលដូច្នេះដោយមានបំណងរកលេសចោទប្រកាន់ព្រះអង្គ។*
*ប៉ុន្តែ ព្រះយេស៊ូឱនព្រះកាយចុះ ហើយយកព្រះអង្គុលី គូសវាសលើដី។ ៧ដោយពួកគេចេះតែសួរព្រះអង្គខ្លាំងពេក ព្រះអង្គងើប*
*ព្រះភ័ក្ត្រឡើងមានព្រះបន្ទូលទៅគេថា៖ «ក្នុងចំណោមអ្នករាល់គ្នា សុំឲ្យអ្នកដែលគ្មានបាបសោះ យកដុំថ្មគប់នាងមុនគេ*
*ទៅ!»។ ៨បន្ទាប់មកព្រះអង្គឈ្ងោកព្រះភ័ក្ត្រចុះ ហើយគូសវាសលើដីសាជាថ្មី។ ៩ពួកគេបាន ឮព្រះបន្ទូលរបស់ព្រះអង្គដូច្នេះ*
*ក៏នាំគ្នាដកខ្លួនថយម្នាក់ម្ដងៗ ចាប់ផ្ដើមពីអ្នកមានវ័យចាស់ជាង គេទៅ នៅសល់តែព្រះយេស៊ូ និងស្ត្រីនោះប៉ុណ្ណោះ។ ១០ពេល*
*នោះព្រះយេស៊ូងើបព្រះភ័ក្ត្រឡើង មានព្រះបន្ទូលទៅនាងថា៖ «នាងអើយ ពួកគេទៅណាអស់ហើយ គ្មាននរណាដាក់ទោស*
*នាងទេឬ?»។ ១១នាងទូលព្រះអង្គថា៖ «គ្មានទេលោកម្ចាស់!»។ ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ខ្ញុំក៏មិនដាក់ទោសនាង*
*ដែរ សុំអញ្ជើញទៅចុះ តែពីពេលនេះតទៅ កុំប្រព្រឹត្តអំពើបាបទៀតឡើយ»។*

-ហេតុអ្វីព្រះយេស៊ូសម្រេចឲ្យគេដាក់ទោសនាងតាមវិន័យរបស់លោកម៉ូសេ?
តើព្រះបន្ទូលរបស់ព្រះយេស៊ូត្រង់ណាដែលនាំឲ្យប្រជាជនមិនគប់ដុំថ្មសម្លាប់នាងវិញ?
តើព្រះយេស៊ូមានព្រះបន្ទូលផ្ដែផ្ដាំនាងនោះយ៉ាងណា?
-តើអត្ថបទនេះបង្រៀនបងប្អូនយ៉ាងណាអំពីព្រះយេស៊ូ? អំពីព្រះជាម្ចាស់?

*អត្ថបទផ្សេងទៀត៖*
*អស ៤៣:១៦-២១,*
*ភីល ៣:៨-១៤,*
*ទន ១២៦*



## បុណ្យលើកតម្កើងទុក្ខលំបាកព្រះយេស៊ូ (ហៃស្លឹក) ត្រូវនឹងថ្ងៃអាទិត្យទី២៤ ខែមីនា ឆ្នាំ២០១៣

អត្ថបទផ្សេងទៀត៖
អស ៥០:៤-៧,
ភីល ២:៦-១១,
ទន ២២



# ព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម

*លក ១៩:២៨-៤០*

*[២៨]កាលព្រះយេស៊ូមានព្រះបន្ទូលដូច្នោះហើយ ព្រះអង្គក៏យាងនាំមុខបណ្ដាជនឡើងទៅក្រុងយេរូសាឡឹម។ [២៩]លុះព្រះអង្គ*
*យាងជិតដល់ភូមិបេតផាសេ និងភូមិបេតថានី ដែលនៅចង្កេះភ្នំដើមអូលីវ ព្រះអង្គចាត់សាវ័ក*ពីររូបឲ្យទៅមុន [៣០]ដោយ*
*មានព្រះបន្ទូលថា៖ «ចូរទៅភូមិខាងមុខនោះ ពេលអ្នកទៅដល់ អ្នកនឹងឃើញកូនលាមួយដែលគេចងនៅទីនោះ ពុំទាន់មាន*
*នរណាជិះនៅឡើយទេ ចូរស្រាយវាដឹកមក។ [៣១]ប្រសិនបើមានគេសួរថា "ហេតុអ្វីបានជាអ្នកស្រាយវា?" ចូរឆ្លើយទៅគេថា*
*"ព្រះអម្ចាស់ត្រូវការវា"»។ [៣២]សាវ័កទាំងពីរក៏ចេញទៅ ហើយឃើញដូចព្រះយេស៊ូមានព្រះបន្ទូលប្រាប់គេមែន។ [៣៣]ពេលគេ*
*កំពុងស្រាយកូនលា ម្ចាស់វាសួរថា៖ "ហេតុអ្វីបានជាអ្នកស្រាយលានេះ?" [៣៤]សាវ័កឆ្លើយថា៖ "ព្រះអម្ចាស់ត្រូវការវា"។*
*[៣៥]បន្ទាប់មក អ្នកទាំង ពីរដឹកកូនលាយកមកថ្វាយព្រះយេស៊ូ ហើយក្រាលអាវធំរបស់ខ្លួនលើខ្នងវាថ្វាយព្រះអង្គគង់។ [៣៦]នៅ*
*ពេលព្រះអង្គយាងទៅមុខ មនុស្សម្នាយកអាវធំរបស់ខ្លួនមកក្រាលតាមផ្លូវ។ [៣៧]កាលព្រះយេស៊ូយាងតាមផ្លូវដែលចុះពីភ្នំ*
*ដើមអូលីវ មកជិតដល់ក្រុងយេរូសាឡឹម មានសាវ័កច្រើនកុះករ អរសប្បាយនាំគ្នាបន្លឺសំឡេងសរសើរតម្កើងព្រះជាម្ចាស់អំពី*
*ការអស្ចារ្យទាំងប៉ុន្មាន ដែលគេបាន ឃើញ។ [៣៨]គេពោលថា៖ «សូមព្រះជាម្ចាស់ប្រទានពរដល់ព្រះមហាក្សត្រ ដែលយាងមក*
*ក្នុងព្រះនាមព្រះអម្ចាស់! សូមសន្តិភាពកើតពីស្ថានបរមសុខ*មកសូមលើកតម្កើងសិរីរុងរឿងរបស់ ព្រះអង្គនៅស្ថានដ៏*
*ខ្ពង់ខ្ពស់បំផុត!»។ [៣៩]មានអ្នកខាងគណៈផារីស៊ី*ខ្លះដែលនៅក្នុងចំណោមបណ្ដា ជនទូលព្រះយេស៊ូថា៖ «លោកគ្រូសូមឃាត់*
*សិស្សរបស់លោកឲ្យនៅស្ងៀមផង!»។ [៤០]ព្រះយេស៊ូ មានព្រះបន្ទូលតបថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងថា ប្រសិនបើអ្នក*
*ទាំងនេះនៅស្ងៀម ដុំថ្មមុខជាស្រែកជំនួសគេវិញមិនខាន»។*

-តើអត្ថបទនេះបង្ហាញថាព្រះយេស៊ូមានឋានៈជាអ្វី? តើបងប្អូនសុខចិត្តរួមជាមួយព្រះយេស៊ូ យាងចូលក្រុងយេរូសាឡឹម ដើម្បីរងទុក្ខលំបាកតាមរបៀបយ៉ាងណាក្នុងពេលសព្វថ្ងៃ?

-ចូរបងប្អូនអង្វរព្រះយេស៊ូជួយឲ្យបងប្អូនអាចរួមក្នុងទុក្ខលំបាករបស់ព្រះអង្គក្នុងពេលសព្វថ្ងៃនេះផង។



ដំណាក់កាលទី ៣

# ព្រះសហគមន៍ត្រាស់ហៅ
# យើងឲ្យបានវិសុទ្ធ

រដូវបុណ្យចម្លង

## ១.ព្រះបិតាត្រាស់ហៅមនុស្សទាំងអស់ឲ្យបានវិសុទ្ធ



ព្រះអម្ចាស់យេស៊ូជាព្រះបរមគ្រូ និងជាគំរូអំពីសេចក្ដីពេញលក្ខណៈគ្រប់យ៉ាង ព្រះអង្គបានបង្រៀនក្រុមសាវ័កទាំងមូល និងសាវ័កម្នាក់ៗ ទោះជាគេមានឋានៈ វណ្ណៈណាក្ដី ឲ្យរស់នៅតាមរបៀបដ៏វិសុទ្ធដូចព្រះអង្គបង្កើតរបៀបរស់នៅដែរ។ ព្រះអង្គក៏អាចប្រោសឲ្យរបៀបរស់នៅបែបនោះបានគ្រប់លក្ខណៈ ដូចព្រះអង្គមានព្រះបន្ទូលថា «ព្រះបិតារបស់អ្នករាល់គ្នាដ៏ខ្ពង់ខ្ពស់បំផុតគ្រប់លក្ខណ៍យ៉ាងណា សូមឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍យ៉ាងនោះដែរ» (មថ ៥,៤៨)។ (...)

គ្រីស្តបរិស័ទទាំងអស់ត្រូវដឹងច្បាស់ថា អស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្ត ទោះជាគេរស់នៅតាមរបៀបណាក្ដី ឬមានឋានៈណាក្ដី ក៏ព្រះជាម្ចាស់ត្រាស់ហៅគេឲ្យរស់យ៉ាងពេញលក្ខណៈជាគ្រីស្តបរិស័ទ និងឲ្យមានសេចក្ដីស្រឡាញ់យ៉ាងពេញលក្ខណៈដែរ។ សូម្បីតែក្នុងសង្គមមនុស្សនៅលើផែនដីនេះ ក៏លក្ខណៈវិសុទ្ធរបស់គ្រីស្តបរិស័ទនេះ ពិតជាជួយឲ្យសភាពការណ៍មនុស្សរស់នៅកាន់តែប្រសើរឡើងៗ។ គ្រីស្តបរិស័ទត្រូវយកកម្លាំងដែលខ្លួនបានទទួលតាមកម្រិតនៃព្រះអំណោយទានរបស់ព្រះគ្រីស្ត មកប្រើដើម្បីឲ្យបានវិសុទ្ធគ្រប់លក្ខណៈ។ គេត្រូវដើរតាមព្រះអង្គជាគំរូ និងបានដូចព្រះអង្គ ដោយបំពេញព្រះហឫទ័យព្រះបិតាក្នុងគ្រប់ប្រការ ហើយបូជាកម្លាំងចិត្តកម្លាំងកាយលើកតម្កើងសិរីរុងរឿងរបស់ព្រះបិតា និងបម្រើអ្នកដទៃផង។ ធ្វើដូច្នេះ ទើបលក្ខណៈវិសុទ្ធនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់នឹងបង្កើតផលផ្លែជាច្រើន ដូចរបៀបរស់នៅរបស់សន្តបុគ្គលជាច្រើនអនេក ជាសាក្សីស្រាប់ក្នុងប្រវត្តិសាស្ត្រ ព្រះសហគមន៍។ **(Lumen Gentium 40)**



ដូច្នេះហើយ អស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្តនឹងកាន់តែវិសុទ្ធឡើងៗ ស្របតាមសភាពការណ៍នៃការរស់នៅរបស់គេ តាមការងាររបស់គេ តាមកាលៈទេសៈនៃជីវិតរបស់គេ ហើយគេបានវិសុទ្ធតាមរយៈការណ៍ទាំងនោះថែមទៀតផង។ ប៉ុន្តែ គេត្រូវទទួលអ្វីៗទាំងអស់ដោយផ្ញើជីវិតលើព្រះបិតាដ៏ខ្ពង់ខ្ពស់បំផុត ហើយក៏ត្រូវរួមសហការជាមួយព្រះបិតា សូមធ្វើឲ្យព្រះហឫទ័យរបស់ព្រះអង្គកើតជារូបរាងពោលគឺដោយគេបម្រើពិភពលោកនេះ គេសម្ដែងឲ្យមនុស្សទាំងអស់អាចមើលឃើញព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះពិភពលោក។ **(Lumen Gentium 41)**

## ២.ផ្លូវ និងមធ្យោបាយឲ្យបានវិសុទ្ធ

«ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់ អ្នកណាស្ថិតនៅជាប់នឹងសេចក្ដីស្រឡាញ់ អ្នកនោះស្ថិតនៅជាប់នឹងព្រះជាម្ចាស់ ហើយព្រះជាម្ចាស់





ក៏ស្ថិតនៅជាប់នឹងអ្នកនោះដែរ» (១យហ៤,១៦)។ «ព្រះជាម្ចាស់បានចាក់បង្ហូរព្រះហឫទ័យស្រឡាញ់របស់ ព្រះអង្គមកក្នុងចិត្តយើង ដោយប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកយើង» (រម ៥,៥)។ គឺព្រះហឫទ័យស្រឡាញ់នេះហើយ ដែលជំរុញយើងឲ្យស្រឡាញ់ព្រះជាម្ចាស់លើសអ្វីៗទាំងអស់ និងឲ្យស្រឡាញ់អ្នកដទៃ ដោយនឹកដល់ព្រះអង្គ។ ដូច្នេះ ព្រះហឫទ័យស្រឡាញ់នេះ ពិតជាព្រះអំណោយទានដំបូង និងដ៏ចាំបាច់ជាងគេ។ ប៉ុន្តែ ព្រះហឫទ័យស្រឡាញ់នេះអាចដុះឡើង និងបង្កើតផលក្នុងចិត្តមនុស្សបាន ដូចពូជមួយដ៏ល្អ លុះត្រាតែគ្រីស្តបរិស័ទម្នាក់ៗស្ម័គ្រចិត្តទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងប្រតិបត្តិតាមព្រះហឫទ័យព្រះអង្គ ដោយព្រះអង្គជួយប្រណីសន្តោសទៀតផង។ គេក៏ត្រូវទទួលអគ្គសញ្ញាជាញឹកញាប់ ជាពិសេសរួមក្នុងអគ្គសញ្ញាអរព្រះគុណ និងពិធីគោរពប្រណិប័តន៍នានា ដើម្បីគោរពបម្រើព្រះអង្គ គេត្រូវយកចិត្តទុកដាក់ និងព្យាយាមអធិដ្ឋាន សុខចិត្តលះបង់ខ្លួនឯង បម្រើបងប្អូនយ៉ាងសកម្ម ព្រមទាំងប្រព្រឹត្តតាមព្រហ្មវិហារធម៌ទាំងប៉ុន្មានផង។ សេចក្តីស្រឡាញ់ធ្វើឲ្យមនុស្សបានពេញលក្ខណៈ និងនាំឲ្យប្រតិបត្តិតាមធម្មវិន័យបានគ្រប់លក្ខណៈដែរ (កូឡ ៣,១៤; រម១៣,១០)។ សេចក្តីស្រឡាញ់តម្រង់គ្រប់មធ្យោបាយដែលនាំឲ្យបានវិសុទ្ធ និងផ្តល់ឲ្យមធ្យោបាយទាំងនេះបានស័ក្តិសិទ្ធិ និងនាំទៅដល់ទិសដៅ។ ហេតុនេះហើយបានជាសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ និងចំពោះអ្នកដទៃ ជាលក្ខណៈរបស់សាវ័កដ៏ពិតប្រាកដរបស់ព្រះគ្រីស្ត។ **(Lumen Gentium 42)**

**សំណួរ**

តើអ្វីទៅជាជនដ៏វិសុទ្ធ (សន្ត: សន្តី)?

ហេតុអ្វីព្រះបិតាសព្វព្រះហឫទ័យឲ្យខ្ញុំបានវិសុទ្ធ (សន្ត: សន្តី)?

តើព្រះសហគមន៍ផ្តល់មធ្យោបាយណាជួយខ្ញុំឲ្យបានវិសុទ្ធ (សន្ត: សន្តី)?

តើខ្ញុំអាចទៅជាជនដ៏វិសុទ្ធ (សន្ត: សន្តី) យ៉ាងណាបាន?

តើខ្ញុំចូលចិត្តសន្តបុគ្គលណាខ្លះខ្លាំងជាងគេ?

ហេតុអ្វីព្រះសហគមន៍បានប្រកាសថាបងស្រីថេរេសានៅក្រុងលីស៊ីយឺ ជាសន្តី?

តើខ្ញុំត្រូវផ្លាស់ប្តូរអ្វីខ្លះក្នុងការរស់នៅរបស់ខ្ញុំដើម្បីទៅជាជនដ៏វិសុទ្ធ (សន្ត: សន្តី) បាន ?

# សន្តី ថេរេសាបំភ្លឺយើង

## ខ្ញុំចង់រកមធ្យោបាយឲ្យបានទៅដល់ស្ថានបរមសុខ
## តាមមាគ៌ាដ៏ត្រង់តូចមួយ មាគ៌ាតូចដែលខ្លី ហើយថ្មីខុសប្លែកពីគេ

អ្នកម៉ែជ្រាបទេ ខ្ញុំតែងតែចង់ក្លាយជាសន្តីមួយរូប ប៉ុន្តែគួរឲ្យស្តាយ កាលបើខ្ញុំប្រៀបធៀបខ្លួនឯងទៅនឹងសន្តបុគ្គលនីមួយៗ ខ្ញុំយល់ថា ខុសគ្នាដូចភ្នំ និងគ្រាប់ខ្សាច់ តែខ្ញុំមិនអស់សង្ឃឹមទេ ហើយប្រាប់ខ្លួនឯងថា៖ ព្រះជាម្ចាស់មិនណែនាំនូវចំណង់ដែលមិនអាចធ្វើកើតទេ ទោះជាខ្ញុំតូចទន់ខ្សោយក៏ដោយ ខ្ញុំនឹងអាចទៅជាសន្តីដ៏វិសុទ្ធបាន បើចង់ក្លាយជាធំទៅមិនរួចទេ ខ្ញុំត្រូវតែទ្រាំទ្រទៅតាមលក្ខណៈខ្វះខាតរបស់ខ្លួន គឺខ្ញុំចង់រកមធ្យោបាយឲ្យបានទៅដល់ស្ថានបរមសុខតាមមាគ៌ាដ៏ត្រង់តូចមួយ មាគ៌ាតូចដែលខ្លី ហើយថ្មីខុសប្លែកពីគេ។ យើងរស់ក្នុងសម័យកាលបង្កើតឆ្នៃប្រឌិត ឥឡូវនេះនៅតាមផ្ទះអ្នកមានទ្រព្យច្រើន គេប្រើជណ្តើរយន្ត មិនចាំបាច់លំបាកឡើងជណ្តើរដូចមុនឡើយ។ ខ្ញុំក៏ចង់រកជណ្តើរយន្តជិះឡើងទៅព្រះយេស៊ូដែរ ព្រោះខ្ញុំតូចមិនអាចឡើងជណ្តើរចោតនៃភាពគ្រប់លក្ខណ៍បានឡើយ។ ដូច្នោះហើយ ខ្ញុំស្វែងរកសៀវភៅរបស់សន្តបុគ្គលដែលអាចចង្អុលបង្ហាញជណ្តើរយន្តដែលខ្ញុំប្រាថ្នា ហើយខ្ញុំក៏បានរកឃើញសម្តី ទាំងនេះ ដែលចេញពីព្រះឧស្ទដ៏អស់កល្បជានិច្ចថា៖ "បើអ្នកណាទន់ខ្សោយ សូមមករកខ្ញុំ"។ ឱព្រះជាម្ចាស់អើយ! ដោយគិតថា ទូលព្រះបង្គំជាខ្ញុំបានរកឃើញវត្ថុជាទីប្រាថ្នាហើយ នោះខ្ញុំម្ចាស់ក៏មករកព្រះអង្គ រួចខ្ញុំម្ចាស់ក៏បន្តការស្រាវជ្រាវតទៅទៀត ហើយរកឃើញថា៖ "ខ្ញុំនឹងលួងលោមអ្នក ដូចម្តាយបបោសអង្អែលកូន ខ្ញុំនឹងឱបអ្នកជាប់ដើមទ្រូង នឹងយោលអ្នកលើជង្គង់របស់ខ្ញុំ!"។ គ្មានសម្តីណាស្រទន់ពិរោះរណ្តំ ធ្វើឲ្យខ្ញុំម្ចាស់ពេញចិត្តជាងនេះទៀតទេ។ ជណ្តើរយន្តដែលត្រូវនាំខ្ញុំម្ចាស់ទៅស្ថានបរមសុខគឺព្រះហស្តទាំងទ្វេរបស់ព្រះអង្គ។ ឱព្រះយេស៊ូអើយ! ខ្ញុំម្ចាស់មិនចង់ធំទេ ខ្ញុំម្ចាស់ចង់នៅតូចជានិច្ច។ ឱព្រះជាម្ចាស់អើយ! ព្រះអង្គបានជួយខ្ញុំម្ចាស់ច្រើនហួសពីសេចក្តីប្រាថ្នារបស់ខ្ញុំម្ចាស់ទៅទៀត ខ្ញុំម្ចាស់ចង់ច្រៀងលើកតម្កើងធម៌មេត្តាករុណាដ៏លើសលប់របស់ព្រះអង្គ។

*សន្តី ថេរេសា នៃព្រះកុមារយេស៊ូ និងព្រះភក្រ្តដ៏វិសុទ្ធ*





*បុណ្យព្រះយេស៊ូទទួលព្រះជន្មថ្មីដ៏រុងរឿង (បុណ្យចម្លង) ត្រូវនឹងថ្ងៃអាទិត្យទី៣១ ខែមីនា ឆ្នាំ២០១៣*

*អត្ថបទផ្សេងទៀត៖*
*កក១០:៣៤ក,*
*៣៧-៤៣,*
*កូឡ ៣:១-៤,*
*ទន ១១៨*



## ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ

*យហ ២០:១-៩*

*១នៅព្រឹកថ្ងៃអាទិត្យ កាលនៅងងឹតនៅឡើយ នាងម៉ារីជាអ្នកស្រុកម៉ាដាឡាចេញដំណើរឆ្ពោះ ទៅផ្នូរ ហើយឃើញថាមានគេ*
*យកថ្មចេញពីមាត់ផ្នូរផុតទៅហើយ។ ២នាងក៏រត់មកជម្រាបលោក សិលា និងសាវ័ក *ម្នាក់ទៀតដែលព្រះយេស៊ូស្រឡាញ់ថា៖*
*«គេយកព្រះអម្ចាស់ចេញពីផ្នូរបាត់ហើយ យើងមិនដឹងជាគេយកទៅដាក់នៅឯណាទេ!»។ ៣លោកសិលា និងសាវ័កម្នាក់ទៀត*
*នោះក៏ចេញទៅផ្នូរ។ ៤សាវ័កទាំងពីររត់ទៅជាមួយគ្នា តែសាវ័កម្នាក់នោះរត់លឿនជាងលោកសិលាទៅដល់ផ្នូរមុន។ ៥គាត់*
*ឈ្ងោកមើលទៅឃើញសំពត់ស្នប តែគាត់មិនចូលទៅក្នុងផ្នូរឡើយ។ ៦លោកសិលារត់តាមក្រោយមកដល់ គាត់ចូលទៅក្នុងផ្នូរ*
*ហើយសម្លឹងមើលសំពត់ស្នបនៅទីនោះ ៧ព្រមទាំងក្រណាត់ដែលគេគ្របព្រះសិរសាព្រះអង្គមូរទុកដោយឡែក គឺមិននៅជា*
*មួយសំពត់ ស្នបទេ។ ៨ពេលនោះ សាវ័កដែលទៅដល់ផ្នូរមុន ក៏ចូលទៅខាងក្នុងដែរ គាត់បានឃើញ ហើយ ជឿ។ ៩កាលណោះ*
*ពួកសាវ័កពុំទាន់យល់អត្ថន័យគម្ពីរដែលចែងទុកមកថា ព្រះយេស៊ូត្រូវមានព្រះជន្មរស់ឡើងវិញនៅឡើយទេ។*

-តើនាងម៉ារីម៉ាដាឡា រត់ទៅជម្រាបសាវ័កណាខ្លះអំពីព្រឹត្តិការណ៍ដែលបានកើតឡើង?

-តាមបងប្អូនស្មានសាវ័កម្នាក់ដែលព្រះយេស៊ូស្រឡាញ់ជានរណា? គាត់រត់ទៅដល់ផ្នូរមុនលោកសិលា តែគាត់ចូលក្រោយវិញ ហើយពេលគាត់ឃើញ គាត់ក៏ជឿ។ តើសេចក្តីនេះ បង្រៀនអ្វីខ្លះដល់បងប្អូនអំពីជំនឿ និងអំពីតួនាទីក្នុងព្រះសហគមន៍?

-តាម ខ ៩ តើបងប្អូនយល់ឃើញយ៉ាងណាអំពីសារៈសំខាន់នៃការអានព្រះគម្ពីរ?

*ថ្ងៃអាទិត្យទី២ ក្នុងរដូវបុណ្យចម្លង ត្រូវនឹងថ្ងៃអាទិត្យទី៧ ខែមេសា ឆ្នាំ២០១៣*

## ពួកសាវ័កបានឃើញព្រះយេស៊ូ

**យហ ២០:១៩-៣១**

១៩នៅល្ងាចថ្ងៃអាទិត្យនោះ ពួកសាវ័ក *នៅក្នុងផ្ទះខ្ទាស់ទ្វារយ៉ាងជាប់ ព្រោះខ្លាចជនជាតិយូដា។ ស្រាប់តែព្រះយេស៊ូយាងមក
ឈរនៅកណ្តាលចំណោមពួកគេមានព្រះបន្ទូលថា៖ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត!»។ ២០ព្រះអង្គ
មានព្រះបន្ទូលដូច្នេះទាំងបង្ហាញស្នាមរបួសនៅព្រះហស្ត និងនៅត្រង់ឆ្អឹងជំនីរឲ្យគេឃើញផង។ ពួកសាវ័កសប្បាយចិត្តជា
ខ្លាំងដោយបានឃើញព្រះអម្ចាស់។ ២១ព្រះយេស៊ូមានព្រះបន្ទូលទៅគេសាជាថ្មីថា៖ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយ
សេចក្តីសុខសាន្ត! ដូចព្រះបិតាបានចាត់ខ្ញុំឲ្យមកយ៉ាងណា ខ្ញុំចាត់អ្នករាល់គ្នា ឲ្យទៅយ៉ាងនោះដែរ»។ ២២បន្ទាប់ពីមានព្រះបន្ទូល
ហើយព្រះអង្គផ្លុំលើពួកគេទាំងមានព្រះបន្ទូលថា៖ «ចូរទទួលព្រះវិញ្ញាណ!។ ២៣បើអ្នករាល់គ្នាលើកលែងទោសអ្នកណាឲ្យរួចពីបាប *
ព្រះជាម្ចាស់ក៏នឹងលើកលែងទោសអ្នកនោះឲ្យរួចពីបាបដែរ។ ផ្ទុយទៅវិញ បើអ្នករាល់គ្នាប្រកាន់ទោសអ្នកណា អ្នកនោះមុខ
ជាត្រូវជាប់ទោសមិនខាន»។ ២៤កាលព្រះយេស៊ូយាងមកនោះ លោកថូម៉ាសហៅឌីឌីមជាសាវ័ក *ម្នាក់ក្នុងចំណោមសាវ័ក
ទាំងដប់ពីរមិនបាននៅជាមួយពួកគេទេ។ ២៥សាវ័កឯទៀតៗប្រាប់គាត់ថា៖ «យើងបានឃើញព្រះអម្ចាស់»។ ប៉ុន្តែគាត់និយាយ
ទៅពួកគេវិញថា៖ «បើខ្ញុំមិនឃើញស្នាមដែកគោលនៅបាតដៃ មិនបានដាក់ម្រាមដៃក្នុងស្នាមដែកគោល ហើយបើខ្ញុំមិនបាន
ដាក់ដៃត្រង់ឆ្អឹងជំនីររបស់លោកទេ ខ្ញុំមិនជឿជាដាច់ខាត»។ ២៦ប្រាំបីថ្ងៃក្រោយមក ពួកសាវ័កជួបជុំគ្នានៅក្នុងផ្ទះសាជាថ្មី
លោកថូម៉ាសក៏នៅជាមួយដែរ។ ពេលនោះទ្វារផ្ទះនៅខ្ទាស់ជាប់ ព្រះយេស៊ូយាងមកឈរនៅកណ្តាលចំណោមពួកគេទាំងមាន
ព្រះបន្ទូលថា៖ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត!»។ ២៧បន្ទាប់មក ព្រះអង្គមានព្រះបន្ទូលទៅលោកថូម៉ាស
ថា៖ «មើលដៃខ្ញុំនេះ ចូរដាក់ម្រាមដៃអ្នកមក ហើយដាក់ដៃអ្នកត្រង់ឆ្អឹងជំនីរខ្ញុំ។ ចូរជឿទៅ! កុំរឹងរូសមិនព្រមជឿដូច្នេះ!»។
២៨លោកថូម៉ាសទូលព្រះអង្គថា៖ «ព្រះអង្គពិតជាព្រះអម្ចាស់ និងជាព្រះរបស់ទូលបង្គំមែន!»។ ២៩ព្រះយេស៊ូមានព្រះបន្ទូលទៅ
គាត់ថា៖ «អ្នកជឿមកពីអ្នកបានឃើញខ្ញុំ អ្នកណាជឿដោយឥតបានឃើញសោះ អ្នកនោះមានសុភមង្គល *ហើយ!»។ ៣០ព្រះយេស៊ូ
បានធ្វើទីសម្គាល់ជាច្រើនទៀតឲ្យពួកសាវ័កឃើញ តែគ្មានកត់ត្រាទុកក្នុងសៀវភៅនេះទេ។ ៣១រីឯសេចក្តីដែលមានកត់ត្រាមក
នេះ គឺក្នុងគោលបំណងឲ្យអ្នករាល់គ្នាជឿថា ព្រះយេស៊ូពិតជាព្រះគ្រីស្ត និងពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយឲ្យអ្នក
រាល់គ្នាដែលជឿមានជីវិត ដោយរួមជាមួយព្រះអង្គ។

-ព្រះយេស៊ូប្រទានសេចក្តីសុខសាន្តដល់សាវ័កដែលគេភ័យខ្លាច។ តើបងប្អូនមានបទពិសោធន៍នេះដូចពួកសាវ័កដែរទេ?
-តើបងប្អូនមានបទពិសោធន៍អំពីព្រះវិញ្ញាណដែលនាំឲ្យបងប្អូនបាត់ភ័យខ្លាច និងឲ្យលើកលែងទោសយ៉ាងណា?
-តាមលោកថូម៉ាស តើជំនឿជាអ្វី? ហើយតាមព្រះយេស៊ូ តើជំនឿជាអ្វី? តើបងប្អូនដូចលោកថូម៉ាសយ៉ាងណាដែរ?

*អត្ថបទផ្សេងទៀត៖*
*កក ៥:១២-១៦,*
*វវ ១:៩-១១ក,*
*១២-១៣, ១៧-១៩,*
*ទន ១១៨*



## *ថ្ងៃអាទិត្យទី៣ ក្នុងរដូវបុណ្យចម្លង ត្រូវនឹងថ្ងៃអាទិត្យទី១៤ ខែមេសា ឆ្នាំ២០១៣*

*អត្ថបទផ្សេងទៀត៖*
*កក ៥:២៧-៣២,*
*៤០ខ-៤១,*
*វវ ៥:១១-១៤,*
*ទន ៣០*



# ព្រះយេស៊ូបង្ហាញព្រះអង្គឲ្យពួកសាវ័កឃើញនៅជិតមាត់សមុទ្រទីបេរីយ៉ាដ

*យហ ២១:១-១៤*

*១ក្រោយមក ព្រះយេស៊ូបង្ហាញខ្លួនឲ្យពួកសាវ័កឃើញម្ដងទៀតនៅមាត់សមុទ្រទីបេរីយ៉ាដ គឺព្រះអង្គបង្ហាញឲ្យគេឃើញដូចត*
*ទៅ៖ ២លោកសិលា លោកថូម៉ាសហៅឌីឌីម លោកណាថាណាអែល ពីភូមិកាណាក្នុងស្រុកកាលីឡេ កូនទាំងពីររបស់លោក*
*សេបេដេ និងសាវ័ករបស់ព្រះយេស៊ូពីរ នាក់ទៀតនៅជុំគ្នា។ ៣លោកសិលានិយាយទៅកាន់សាវ័កឯទៀតៗថា៖ «ខ្ញុំទៅរកត្រី»។*
*គេពោលតបមកគាត់វិញថា៖ «យើងទៅជាមួយដែរ»។ គេក៏នាំគ្នាចេញទៅ ហើយចុះទូកទាំងអស់គ្នា ប៉ុន្តែ នៅយប់នោះគេឥត*
*បានត្រីសោះ។ ៤ព្រលឹមឡើងព្រះយេស៊ូឈរនៅមាត់ច្រាំង ប៉ុន្តែពួកសាវ័ក មិនដឹងថាជាព្រះអង្គទេ។ ៥ព្រះយេស៊ូមាន*
*ព្រះបន្ទូលទៅគេថា៖ «កូនចៅអើយ! មានអ្វីបរិភោគ ឬទេ?»។ គេទូលព្រះអង្គថា៖ «គ្មានទេ»។ ៦ព្រះអង្គមានព្រះបន្ទូលទៅ*
*គេថា៖ «ចូរទម្លាក់អួន ខាងស្ដាំទូកទៅ មុខជាបានត្រីមិនខាន»។ គេក៏ទម្លាក់អួន ហើយពុំអាចលើកអួនឡើងវិញបានឡើយ*
*ព្រោះមានត្រីច្រើនពេក។ ៧ពេលនោះសាវ័កដែលព្រះយេស៊ូស្រឡាញ់និយាយទៅលោកសិលាថា៖ «ព្រះអម្ចាស់ទេតើ!»។*
*កាលលោកសិលាឮថាព្រះអម្ចាស់ដូច្នេះ គាត់ក៏ស្លៀកពាក់ដ្បិតគាត់នៅខ្លួនទទេរួចលោតទៅក្នុងទឹក។ ៨សាវ័កឯទៀតៗនាំគ្នា*
*ចូលទូកទៅមាត់ច្រាំង ទាំងទាញអួនដែលមានត្រីពេញទៅជាមួយផង ព្រោះគេមិននៅឆ្ងាយពីច្រាំងប៉ុន្មានទេ គឺប្រមាណជា*
*ពីររយហត្ថប៉ុណ្ណោះ។ ៩គេឡើងទៅលើគោកឃើញរងើកភ្លើងមានដាក់ត្រី និងនំបុ័ងអាំងពីលើផង។ ១០ព្រះយេស៊ូមានព្រះបន្ទូល*
*ទៅគេថា៖ «សុំយកត្រីដែលអ្នករាល់គ្នាទើបនឹងចាប់បានមកណោះ!»។ ១១លោកសិលាចុះទៅក្នុងទូកទាញអួនដែលមានត្រី*
*ពេញមកដាក់លើគោក គឺមានត្រីធំៗចំនួនមួយរយហាសិបបី។ ទោះបីមានត្រីច្រើនយ៉ាងនេះក៏ដោយ ក៏អួនមិនធ្លាយដែរ។ ១២ព្រះ*
*យេស៊ូ មានព្រះបន្ទូលទៅគេថា៖ «នាំគ្នាមកបរិភោគទៅ»។ គ្មានសាវ័កណាម្នាក់ហ៊ានសួរព្រះអង្គថា "លោកជានរណា"*
*ឡើយ ដ្បិតគេដឹងថា ជាព្រះអម្ចាស់ទាំងអស់គ្នា។ ១៣ព្រះយេស៊ូយាងទៅជិត ពួកគេទ្រង់យកនំបុ័ងមកប្រទានឲ្យគេ ហើយយក*
*ត្រីមកប្រទានឲ្យគេដែរ។ ១៤តាំងពីព្រះអង្គមាន ព្រះជន្មរស់ឡើងវិញមក នេះជាលើកទីបីហើយដែលព្រះយេស៊ូសម្ដែងព្រះអង្គ*
*ឲ្យពួកសាវ័កឃើញ។*

-តើហេតុអ្វីបានជាសាវ័ករបស់ព្រះយេស៊ូមិនស្គាល់ព្រះអង្គ?
-តើហេតុអ្វីគេរកត្រីមិនបាន និង ហេតុអ្វីគេរកត្រីបាន?
-តើពាក្យ "ព្រះអម្ចាស់" ដែលសាវ័កហៅព្រះយេស៊ូ មានអត្ថន័យយ៉ាងណា?
-តើអត្ថបទថ្ងៃនេះបង្រៀនអ្វីខ្លះដល់បងប្អូន?

*ថ្ងៃអាទិត្យទី៤ ក្នុងរដូវបុណ្យចម្លង ត្រូវនឹងថ្ងៃអាទិត្យទី២១ ខែមេសា ឆ្នាំ២០១៣*

## គង្វាល និងចៀម

*យហ ១០:២៧-៣០*

*២៧ចៀមរបស់ខ្ញុំតែងស្តាប់សំឡេងខ្ញុំ ខ្ញុំស្គាល់ចៀមទាំងនោះ ហើយចៀមទាំងនោះមកតាមខ្ញុំ។
២៨ខ្ញុំឲ្យគេមានជីវិតអស់កល្ប ជានិច្ច គេមិនវិនាសអន្តរាយឡើយ ហើយគ្មាននរណាអាចឆក់យក គេពីដៃខ្ញុំជាដាច់ខាត។
២៩ព្រះបិតាដែលបានប្រទានចៀម ទាំងនោះមកឲ្យខ្ញុំ ទ្រង់មានអំណាចធំលើសអ្វីៗទាំងអស់ គ្មាននរណាអាចឆក់យកគេពីព្រះហស្តព្រះបិតាបានឡើយ។
៣០ខ្ញុំ និងព្រះ បិតាជាអង្គតែមួយ។*

-ក្នុងឋានៈជាគង្វាល តើព្រះយេស៊ូមានទំនាក់ទំនងយ៉ាងណាជាមួយចៀមរបស់ព្រះអង្គ? តើព្រះអង្គប្រទានអ្វីដល់ចៀមរបស់ព្រះអង្គ? តើព្រះអង្គបានចៀមនោះមកពីណា?

-តើអត្ថបទនេះពង្រឹងជំនឿរបស់បងប្អូនយ៉ាងណាលើព្រះយេស៊ូ? លើព្រះបិតា?

*អត្ថបទផ្សេងទៀត៖*
*កក ១៣:១៤, ៤៣-៥២, វវ ៧:៩, ១៤ខ-១៧, ទន ១០០*



## ថ្ងៃអាទិត្យទី៥ ក្នុងរដូវបុណ្យចម្លង ត្រូវនឹងថ្ងៃអាទិត្យទី២៨ ខែមេសា ឆ្នាំ២០១៣

អត្ថបទផ្សេងទៀត៖
កក ១៤:២១-២៧,
វវ ២១:១-៥ក,
ទន ១៤៥



# វិន័យថ្មី

*យហ ១៣:៣១-៣៣ក, ៣៤-៣៥*

*៣១ លុះយូដាសចេញផុតទៅព្រះយេស៊ូមានព្រះបន្ទូលថា៖ «ឥឡូវនេះបុត្រមនុស្សបានសម្តែង សិរីរុងរឿងហើយ ហើយព្រះ*
*ជាម្ចាស់ក៏បានសម្តែងសិរីរុងរឿងក្នុងបុត្រមនុស្សដែរ។ ៣២ បើព្រះជាម្ចាស់បានសម្តែងសិរីរុងរឿងក្នុងបុត្រមនុស្ស ព្រះអង្គក៏នឹង*
*សម្តែងសិរីរុងរឿងរបស់បុត្រមនុស្សក្នុងព្រះអង្គផ្ទាល់ដែរ! ហើយព្រះអង្គនឹងសម្តែងសិរីរុងរឿងរបស់បុត្រមនុស្សក្នុងពេល*
*ឆាប់ៗខាងមុខនេះ។ ៣៣ ម្នាលកូនចៅអើយ ខ្ញុំនៅជាមួយអ្នករាល់គ្នាតែមួយរយៈពេលដ៏ខ្លីទៀត។ ៣៤ ខ្ញុំឲ្យវិន័យថ្មីដល់អ្នក*
*រាល់គ្នា គឺត្រូវស្រឡាញ់គ្នាទៅវិញទៅមក។ អ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។*
*៣៥ បើអ្នកស្រឡាញ់គ្នាទៅវិញទៅមក មនុស្សទាំងអស់មុខជាដឹងថាអ្នករាល់គ្នាពិតជាសាវ័ក *របស់ខ្ញុំមែន»។*

-តើពាក្យថា "សម្តែងសិរីរុងរឿងមានអត្ថន័យយ៉ាងណា"?

-តើវិន័យថ្មីដែលព្រះយេស៊ូប្រទានឲ្យគឺអ្វី? តើបងប្អូនរស់នៅតាម វិន័យថ្មីនោះបានកម្រិតណា? តើបងប្អូនមានពាក្យអ្វីចង់ទូលអង្វរទៅព្រះយេស៊ូដែរឬទេ?

*ថ្ងៃអាទិត្យទី៦ ក្នុងរដូវបុណ្យចម្លង ត្រូវនឹងថ្ងៃអាទិត្យទី៥ ខែឧសភា ឆ្នាំ២០១៣*

## ព្រះបន្ទូលសន្យាអំពីព្រះវិញ្ញាណ

*យហ ១៤:២៣-២៩*

*[២៣]ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «អ្នកណាស្រឡាញ់ខ្ញុំ អ្នកនោះនឹងប្រតិបត្តិតាមពាក្យខ្ញុំ។ ព្រះបិតាខ្ញុំនឹងស្រឡាញ់*
*អ្នកនោះ ហើយព្រះបិតា និងខ្ញុំក៏នឹងមកតាំងលំនៅនៅក្នុងអ្នកនោះ ដែរ។ [២៤]អ្នកណាមិនស្រឡាញ់ខ្ញុំ អ្នកនោះមិនប្រតិបត្តិតាម*
*ពាក្យខ្ញុំឡើយ។ ពាក្យដែលអ្នករាល់ គ្នាឮខ្ញុំនិយាយមិនមែនជាពាក្យរបស់ខ្ញុំទេ គឺជាព្រះបន្ទូលរបស់ព្រះបិតា ដែលបានចាត់ខ្ញុំ*
*ឲ្យមក។ [២៥]ខ្ញុំបានប្រាប់សេចក្ដីទាំងនេះឲ្យអ្នករាល់គ្នាដឹង ក្នុងពេលដែលខ្ញុំស្ថិតនៅជាមួយអ្នករាល់គ្នានៅឡើយ [២៦]ប៉ុន្តែ ព្រះ*
*ដ៏ជួយការពារ គឺព្រះវិញ្ញាណដ៏វិសុទ្ធ *ដែលព្រះបិតាចាត់ឲ្យមកក្នុងនាមខ្ញុំ នឹងបង្រៀនសេចក្ដីទាំងអស់ដល់អ្នករាល់គ្នាព្រមទាំង*
*រំឭកអ្វីៗដែលខ្ញុំបានប្រាប់អ្នករាល់គ្នាផង។ [២៧]ខ្ញុំទុកសេចក្ដីសុខសាន្តឲ្យអ្នករាល់គ្នា ខ្ញុំផ្ដល់សេចក្ដីសុខសាន្តរបស់ខ្ញុំឲ្យអ្នករាល់*
*គ្នា។សេចក្ដីសុខសាន្តដែលខ្ញុំផ្ដល់ឲ្យនេះមិនដូចសេចក្ដីសុខសាន្តដែលមនុស្សលោកឲ្យទេ។ចូរកុំរន្ធត់ចិត្តកុំភ័យខ្លាចឲ្យសោះ។*
*[២៨]អ្នករាល់គ្នាបានឮខ្ញុំនិយាយរួចមកហើយថា ខ្ញុំនឹងចាកចេញទៅ រួចខ្ញុំមករកអ្នករាល់គ្នាវិញ។ ប្រសិនបើអ្នករាល់គ្នាស្រឡាញ់*
*ខ្ញុំ អ្នករាល់គ្នាមុខតែសប្បាយចិត្តដោយខ្ញុំទៅឯព្រះបិតា ដ្បិតព្រះបិតាមានឋានៈធំជាងខ្ញុំ។ [២៩]ខ្ញុំប្រាប់ឲ្យអ្នករាល់គ្នាដឹង ឥឡូវ*
*នេះ មុនហេតុការណ៍ទាំងនោះកើតឡើង។ លុះដល់ហេតុការណ៍ទាំងនោះកើតឡើង អ្នករាល់គ្នានឹងជឿ។*

-ខ ២៣: តើបងប្អូនបានប្រព្រឹត្តតាមព្រះបន្ទូលប្រៀនប្រដៅរបស់ព្រះយេស៊ូយ៉ាងណាខ្លះក្នុងការរស់នៅ?

-តើបងប្អូនធ្លាប់មានបទពិសោធន៍អំពីព្រះដ៏ជួយការពារ ដែលជាឈ្មោះមួយទៀតរបស់ព្រះវិញ្ញាណដ៏វិសុទ្ធយ៉ាងណា?

-តើព្រះយេស៊ូទុកអ្វីខ្លះឲ្យពួកសាវ័ករបស់ព្រះអង្គ? តើព្រះបន្ទូលនេះមានឥទ្ធិពលពិតប្រាកដយ៉ាងណា ក្នុងការរស់នៅប្រចាំថ្ងៃរបស់បងប្អូន?

*អត្ថបទផ្សេងទៀត៖*
*កក ១៥:១-២,*
*២២-២៩,*
*វវ ២១:១០-១៤,*
*២២-២៣, ទន ៦៧*



*ថ្ងៃអាទិត្យទី៧ ក្នុងរដូវបុណ្យចម្លង ត្រូវនឹងថ្ងៃអាទិត្យទី១២ ខែឧសភា ឆ្នាំ២០១៣*

*អត្ថបទផ្សេងទៀត៖*
*កក ៧:៥៥-៦០,*
*វវ ២២:១២-១៤,*
*១៦-១៧, ២០,*
*ទន ៩៧*



## ព្រះយេស៊ូទូលអង្វរឲ្យពួកសាវ័ក

*យហ ១៧:២០-២៦*

*[២០]ទូលបង្គំមិនអង្វរព្រះអង្គឲ្យតែអ្នកទាំងនេះប៉ុណ្ណោះទេ គឺអង្វរឲ្យអស់អ្នកជឿលើទូលបង្គំតាមរយៈពាក្យដែលអ្នកទាំងនេះ*
*ថ្លែងប្រាប់ផងដែរ [២១]សូមឲ្យគេទាំងអស់គ្នារួមជាអង្គតែមួយ។ ឱព្រះបិតាអើយ! ព្រះអង្គស្ថិតនៅជាប់នឹងទូលបង្គំ ហើយទូលបង្គំ*
*ស្ថិតនៅជាប់នឹងព្រះអង្គយ៉ាងណា សូមឲ្យគេរួមគ្នាជាអង្គតែមួយនៅក្នុងយើងយ៉ាងនោះដែរ ដើម្បីឲ្យមនុស្សលោកជឿថា*
*ព្រះអង្គបានចាត់ទូលបង្គំឲ្យមកមែន។ [២២]រីឯសិរីរុងរឿងដែលព្រះអង្គប្រទានមកទូលបង្គំ ទូលបង្គំបានប្រគល់ទៅឲ្យគេហើយ*
*ដើម្បីឲ្យគេរួមគ្នាជាអង្គតែមួយដូចយើងជាអង្គតែមួយដែរ [២៣]គឺឲ្យទូលបង្គំនៅក្នុងគេព្រះអង្គនៅក្នុងទូលបង្គំ ដើម្បីឲ្យគេរួមគ្នា*
*ជាអង្គតែមួយពិតប្រាកដមែន ហើយមនុស្សលោកទទួលស្គាល់ថា ព្រះអង្គបានចាត់ទូលបង្គំឲ្យមក ព្រមទាំងទទួលស្គាល់ថា*
*ព្រះអង្គស្រឡាញ់គេដូចព្រះអង្គស្រឡាញ់ទូលបង្គំដែរ។ [២៤]ឱព្រះបិតាអើយ! ទូលបង្គំចង់ឲ្យអស់អ្នកដែលព្រះអង្គប្រទានមក*
*ទូលបង្គំបាននៅជាមួយទូលបង្គំឯកន្លែងដែលទូលបង្គំនៅនោះដែរ ដើម្បីឲ្យគេឃើញសិរីរុងរឿងដែលព្រះអង្គប្រទានមកទូលបង្គំ*
*ព្រោះព្រះអង្គបានស្រឡាញ់ទូលបង្គំតាំងពីមុនកំណើតពិភពលោកមកម្ល៉េះ។ [២៥]ឱព្រះបិតាដ៏សុចរិតអើយ! មនុស្សលោកពុំបាន*
*ស្គាល់ព្រះអង្គទេ រីឯទូលបង្គំវិញទូលបង្គំស្គាល់ព្រះអង្គ ហើយអ្នកទាំងនេះក៏ទទួលស្គាល់ថាព្រះអង្គបានចាត់ទូលបង្គំ ឲ្យមក*
*មែន។ [២៦]ទូលបង្គំបានសម្តែងព្រះនាមព្រះអង្គឲ្យគេស្គាល់ ហើយទូលបង្គំនឹងសម្តែងឲ្យគេរឹតតែស្គាល់ថែមទៀត ដើម្បីឲ្យ*
*សេចក្តីស្រឡាញ់របស់ព្រះអង្គចំពោះទូលបង្គំស្ថិតនៅក្នុងគេ ហើយទូលបង្គំក៏ស្ថិតនៅក្នុងគេដែរ»។*

-តើព្រះយេស៊ូអង្វរព្រះបិតាឲ្យនរណា?

-តើបងប្អូនមានទំនាក់ទំនងមិនល្អណាមួយ ជាបងប្អូនឯទៀតក្នុងព្រះសហគមន៍ដែរឬទេ? តើមូលហេតុអ្វីដែលនាំឲ្យមានទំនាក់ទំនងមិនល្អនេះកើតឡើង? សូមបងប្អូនទូលអង្វរព្រះយេស៊ូឲ្យយើងមានកម្លាំងអាចបំបាត់មូលហេតុទាំងឡាយបាន។

ដំណាក់កាលទី ៤

# ព្រះនាមថ្មីជាគំរូ
# សម្រាប់ព្រះសហគមន៍

បុណ្យព្រះវិញ្ញាណយាងមក

## ១. ព្រះនាងម៉ារីជាមាតារបស់ព្រះសហគមន៍

ពេលទេវទូតនាំដំណឹងមក ព្រះនាងព្រហ្មចារិនីម៉ារីទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ទុកទាំងក្នុងចិត្តផង ទាំងក្នុងរូបកាយផង ហើយព្រះនាងបង្ហាញជីវិតនោះដល់មនុស្សលោក។ គេទទួលស្គាល់ និងគោរពព្រះនាងទុកជាព្រះមាតាដ៏ពិតប្រាកដរបស់ព្រះអម្ចាស់ជាព្រះសង្គ្រោះផង។ (...) ព្រះនាងពិតជា "មាតានៃសរីរាង្គរបស់ព្រះគ្រីស្ត ព្រោះព្រះនាងរួមសហការដោយចិត្តស្រឡាញ់ បង្កើតព្រះសហគមន៍របស់គ្រីស្តបរិស័ទដែលជាសរីរាង្គនៃព្រះអម្ចាស់ ជាមេដឹកនាំនោះ"។ ( **Lumen Gentium 53**)

## ២. ព្រះនាងម៉ារីជាមាតារបស់ព្រះអម្ចាស់គំរូសម្រាប់ព្រះសហគមន៍

ដោយព្រះជាម្ចាស់ប្រទានអំណោយទាន និងបន្ទុកឲ្យព្រះនាងម៉ារីប្រសូតព្រះបុត្រា ព្រះនាងភ្ជាប់ជាមួយបុត្រជាព្រះសង្គ្រោះយ៉ាងអស្ចារ្យ។ ដោយព្រះជាម្ចាស់ប្រណីសន្ដោសព្រះនាង និងផ្ញើបន្ទុកពិសេសទាំងនោះមក ព្រះនាងក៏ភ្ជាប់យ៉ាងជិតស្និទ្ធជាមួយព្រះសហគមន៍ដែរ។ សន្ដ: អំប្រ័សតែងបង្រៀនថា ព្រះមាតារបស់ព្រះអម្ចាស់ពិតជាគំរូរបស់ព្រះសហគមន៍ ត្រង់ជំនឿ ត្រង់សេចក្ដីស្រឡាញ់ និងត្រង់ការរួបរួមយ៉ាងពេញលក្ខណៈជាមួយព្រះគ្រីស្ត។ (**Lumen Gentium 63**)

## ៣. ព្រះសហគមន៍ជាមាតាដូចព្រះនាងម៉ារី

ពេលព្រះសហគមន៍នឹកសញ្ជឹងស្ញើងស្ញប់ អំពីព្រះនាងព្រហ្មចារិនីម៉ារីដ៏វិសុទ្ធយ៉ាងអស្ចារ្យ ពេលព្រះសហគមន៍យកតម្រាប់តាមសេចក្ដីស្រឡាញ់របស់ព្រះនាង ព្រមទាំងយកចិត្តទុកដាក់ធ្វើតាមព្រះហឫទ័យរបស់ព្រះបិតាដោយចិត្តស្មោះ ពេលនោះព្រះសហគមន៍ក៏ត្រឡប់ទៅជាមាតាដែរ ព្រោះព្រះសហគមន៍បានទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ ទាំងផ្ញើជីវិតលើព្រះអង្គ។ ពេលព្រះសហគមន៍ប្រកាសដំណឹងល្អ និងធ្វើអគ្គសញ្ញាជ្រមុជទឹកជូនគេ ព្រះសហគមន៍ក៏បង្កើតកូនដែលចាប់ផ្ទៃដោយព្រះវិញ្ញាណដ៏វិសុទ្ធ ហើយដែលកើតពីព្រះជាម្ចាស់ ដើម្បីឲ្យមានជីវិតថ្មីជាជីវិតអមតៈ។ ដូច្នេះព្រះសហគមន៍ក៏ជាព្រហ្មចារិនីដែរ ដោយព្រះសហគមន៍ផ្ញើជីវិតលើព្រះគ្រីស្តជាព្រះស្វាមី ហើយក៏កាន់ជំនឿនេះ ដោយចិត្តស្មោះត្រង់បរិសុទ្ធដែរ។ ព្រះសហគមន៍យកតម្រាប់តាមព្រះមាតាព្រះអម្ចាស់









របស់ខ្លួន ហើយរក្សាទុកជំនឿពិតប្រាកដ រក្សាទុកសេចក្តីសង្ឃឹមយ៉ាងមាំមួន និងសេចក្តីស្រឡាញ់យ៉ាងស្មោះ តាមរបៀបបរិសុទ្ធ ដូចស្ត្រីព្រហ្មចារិនីម្នាក់ដោយអានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធជួយឧបត្ថម្ភផង។ **(Lumen Gentium 64)**

## ៤. ព្រះនាងម៉ារីជាសញ្ញាសម្គាល់ផ្តល់សេចក្តីសង្ឃឹម

ព្រះមាតារបស់ព្រះយេស៊ូទទួលសិរីរុងរឿងទាំងរូបកាយ ទាំងវិញ្ញាណនៅស្ថានបរមសុខរួចហើយយ៉ាងណា ព្រះនាងក៏ជាតំណាងរបស់ព្រះសហគមន៍នៅលើផែដីនេះ និងធ្វើឲ្យព្រះសហគមន៍នៃលោកខាងមុខចាប់ផ្តើមកើតជារូបរាងហើយយ៉ាងនោះដែរ។ ទម្រាំដល់ថ្ងៃព្រះអម្ចាស់យាងមក (២សល ៣,១០) ទុកនាងបញ្ចាំងសញ្ញាសម្គាល់អំពីសេចក្តីសង្ឃឹមយ៉ាងនឹងន និងជាសញ្ញាលួងលោមនៅមុខប្រជារាស្ត្ររបស់ព្រះជាម្ចាស់កំពុងធ្វើបូជនីយេសក៍នៅលើផែនដី។ **(Lumen Gentium 68)**

**សំណួរ**

ហេតុអ្វីព្រះនាងម៉ារីជាមាតារបស់ព្រះសហគមន៍ និងជាគំរូសម្រាប់ព្រះសហគមន៍?

ក្នុងគម្ពីរដំណឹងល្អ តើមានអត្ថបទណាស្តីអំពីព្រះនាងម៉ារី? តើក្នុងអត្ថបទនីមួយៗ អ្នកនិពន្ធចង់ពន្យល់អ្វីអំពីព្រះនាងម៉ារី?

តើព្រះសហគមន៍ (គឺក្នុងភូមិខ្ញុំ ក្នុងភូមិភាគ) អាចទៅជាព្រះមាតាដូចព្រះនាងម៉ារីបានទេ?

តើខ្ញុំមានទំនាក់ទំនងជាមួយព្រះនាងម៉ារីយ៉ាងណា?

តើខ្ញុំស្គាល់ព្រឹត្តិការណ៍នៃមាលាឬទេ? តើខ្ញុំធ្លាប់សូត្រផ្កាំឬទេ? សូត្រយ៉ាងដូចម្តេច?

ហេតុអ្វីព្រះនាងម៉ារីជាសញ្ញាសម្គាល់ផ្តល់សេចក្តីសង្ឃឹម?

តើយើង គឺភូមិភាគ ព្រះសហគមន៍ក្នុងភូមិខ្ញុំផ្ទាល់ អាចទៅជាសញ្ញាសម្គាល់ ផ្តល់សេចក្តីសង្ឃឹមយ៉ាងណា?

# សន្ដី ថេរេសាបំភ្លឺយើង

## នៅក្នុងបេះដូងព្រះសហគមន៍ ជាមាតាខ្ញុំ... ខ្ញុំនឹងហើយជាសេចក្ដីស្រឡាញ់...

ចំណង់ធ្វើឲ្យខ្ញុំចង់រងទុក្ខដូចជាមរណសាក្សី។ ខ្ញុំចាប់អារម្មណ៍នៅជំពូកទី១២ និង១៣ ក្នុងលិខិតទី១ ផ្ញើជូនគ្រីស្ដបរិស័ទនៅកូរិនថូស ដែលរៀបរាប់ថា៖ ទាំងអស់គ្នាមិនអាចជាគ្រីស្ដទូត ព្យាការី បណ្ឌិត...ទេ ព្រះសហគមន៍កើតចេញពីការរួមផ្សំនៃសរីរាង្គខុសៗគ្នា។

ចម្លើយហាក់ដូចជាច្បាស់លាស់ហើយ ប៉ុន្តែមិនអាចបំពេញបំណងខ្ញុំទេ ខ្ញុំនៅតែមិនស្ងប់... ដូចម៉ារីម៉ាដាឡាឈ្ងោកមើលផ្នូរទទេរាល់ថ្ងៃ ទីបញ្ចប់គាត់បានរកឃើញដូចបំណង។ ខ្ញុំក៏ដូច្នោះដែរ ខ្ញុំឱនសម្លឹងទៅក្នុងទីជម្រៅនៃភាពទទេស្អាតរបស់ខ្ញុំ ដើយខ្ពស់រហូតរកមិនឃើញទិសដៅ... ខ្ញុំអានលិខិតបន្តទៅទៀតដោយឥតធុញទ្រាន់ ហើយមានល្បះមួយនេះធ្វើឲ្យខ្ញុំធូរចិត្ត... "ចូរប៉ងប្រាថ្នាចង់បានព្រះអំណោយទានណាដែលសំខាន់ជាងគេ"។ គ្រីស្ដទូតពន្យល់ថា ព្រះអំណោយទានសុក្រិត្យជាងគេ នឹងឥតមានប្រយោជន៍ បើគ្មានសេចក្ដីស្រឡាញ់... សេចក្ដីស្រឡាញ់ជាមាគ៌ាល្អបំផុត ដែលពិតជាអាចនាំទៅដល់ព្រះជាម្ចាស់។ ទីបំផុតខ្ញុំបានស្ងប់ចិត្តហើយ។ សេចក្ដីស្រឡាញ់ផ្ដល់កូនសោមកឲ្យខ្ញុំបើកទ្វារទៅរកការត្រាស់ហៅ។ ព្រះសហគមន៍មានបេះដូង ហើយបេះដូងនេះកំពុងតែដុតរោលដោយសេចក្ដីស្រឡាញ់។ ខ្ញុំយល់ថា មានតែសេចក្ដីស្រឡាញ់ទេ ដែលធ្វើឲ្យសរីរាង្គព្រះសហគមន៍មានសកម្មភាព បើសេចក្ដីស្រឡាញ់រលត់ គ្រីស្ដទូតលែងប្រកាសដំណឹងល្អ មរណសាក្សីមិនព្រមបូជាជីវិតទៀតទេ... ខ្ញុំយល់ថា សេចក្ដីស្រឡាញ់ជាអ្វីៗទាំងអស់ដែលគ្របដណ្ដប់គ្រប់ពេល និងគ្រប់ទីកន្លែង និយាយដោយខ្លីទៅសេចក្ដីស្រឡាញ់ស្ថិតនៅអស់កល្បជានិច្ច...។

ឱព្រះយេស៊ូជាទីស្រឡាញ់អើយ ទីបំផុតខ្ញុំម្ចាស់រកឃើញការត្រាស់ហៅហើយ ការត្រាស់ហៅរបស់ខ្ញុំម្ចាស់ គឺសេចក្ដីស្រឡាញ់!...។

មែនហើយ ខ្ញុំរកកន្លែងបានហើយនៅក្នុងព្រះសហគមន៍ ឱព្រះជាម្ចាស់អើយ! ព្រះអង្គជាអ្នកប្រទានកន្លែងនោះ...នៅក្នុងបេះដូងព្រះសហគមន៍ជាមាតាខ្ញុំ...ខ្ញុំនឹងជាសេចក្ដីស្រឡាញ់...ដូច្នេះខ្ញុំនឹងជាអ្វីៗទាំងអស់...ក្ដីស្រមៃរបស់ខ្ញុំនឹងមានរូបរាងហើយ! (...)

*សន្ដី ថេរេសា នៃព្រះកុមារយេស៊ូ និងព្រះភក្ត្រដ៏វិសុទ្ធ*





*អត្ថបទផ្សេងទៀត៖*
*កក ២:១-១១,*
*១ករ ១២:៣ខ-៧,*
*១២-១៣,*
*ទន ១០៤*



*បុណ្យលើកតម្កើងព្រះវិញ្ញាណយាងមក ត្រូវនឹងថ្ងៃអាទិត្យទី១៩ ខែឧសភា ឆ្នាំ២០១៣*

## ព្រះបន្ទូលសន្យាអំពីព្រះវិញ្ញាណ

**យហ ១៤:១៥-១៦, ២៣ខ-២៦**

*១៥«ប្រសិនបើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ អ្នករាល់គ្នាពិតជាកាន់តាមវិន័យរបស់ខ្ញុំ ១៦ខ្ញុំនឹងទូលអង្វរព្រះបិតា ហើយទ្រង់ប្រទាន*
*ព្រះដ៏ជួយការពារមួយអង្គទៀតឲ្យគង់នៅជាមួយអ្នករាល់គ្នាជាដរាបតរៀងទៅ។ ២៣អ្នកណាស្រឡាញ់ខ្ញុំ អ្នកនោះនឹងប្រតិបត្តិ*
*តាមពាក្យខ្ញុំ។ ព្រះបិតាខ្ញុំនឹងស្រឡាញ់អ្នកនោះ ហើយព្រះបិតា និងខ្ញុំក៏នឹងមកតាំងលំនៅនៅក្នុងអ្នកនោះដែរ។ ២៤អ្នកណាមិន*
*ស្រឡាញ់ខ្ញុំ អ្នកនោះមិនប្រតិបត្តិតាមពាក្យខ្ញុំឡើយ។ ពាក្យដែលអ្នករាល់គ្នាឮខ្ញុំនិយាយមិនមែនជាពាក្យរបស់ខ្ញុំទេ គឺជាព្រះ*
*បន្ទូលរបស់ព្រះបិតាដែលបានចាត់ខ្ញុំឲ្យមក។ ២៥ខ្ញុំបានប្រាប់សេចក្ដីទាំងនេះ ឲ្យអ្នករាល់គ្នាដឹងក្នុងពេលដែលខ្ញុំស្ថិតនៅជាមួយ*
*អ្នករាល់គ្នានៅឡើយ ២៦ប៉ុន្ដែព្រះដ៏ជួយការពារ គឺព្រះវិញ្ញាណដ៏វិសុទ្ធ *ដែលព្រះបិតាចាត់ឲ្យមកក្នុងនាមខ្ញុំ នឹងបង្រៀនសេចក្ដី*
*ទាំងអស់ដល់អ្នករាល់គ្នាព្រមទាំងរំឭកអ្វីៗដែលខ្ញុំបានប្រាប់អ្នករាល់គ្នាផង។*

-តើព្រះយេស៊ូអង្វរព្រះបិតាឲ្យប្រទានអ្វីមកគង់នៅជាមួយសាវ័កព្រះអង្គតរៀងទៅ?

-ព្រះបន្ទូលមិនគ្រាន់តែមានចែងក្នុងព្រះគម្ពីរប៉ុណ្ណោះទេ ប៉ុន្ដែព្រះវិញ្ញាណក៏បំភ្លឺឲ្យយើងស្ដាប់ឮព្រះបន្ទូលដែរ។ តើបងប្អូនមានបទពិសោធន៍យ៉ាងណាអំពីព្រះវិញ្ញាណ ដែលបំភ្លឺឲ្យបងប្អូនស្ដាប់ឮព្រះបន្ទូលរបស់ព្រះជាម្ចាស់? តើបងប្អូនស្រឡាញ់ព្រះយេស៊ូដោយប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះអង្គយ៉ាងណាក្នុងការរស់នៅ?

*បុណ្យលើកតម្កើងព្រះត្រៃឯក ត្រូវនឹងថ្ងៃអាទិត្យទី២៦ ខែឧសភា ឆ្នាំ២០១៣*

# ព្រះបរមកិច្ចរបស់ព្រះវិញ្ញាណ

*អត្ថបទផ្សេងទៀត៖*
*សុភ ៨:២២-៣១,*
*រម ៥:១-៥,*
*ទន ៨*

***យហ ១៦:១២-១៥***

*[១២]ខ្ញុំមានសេចក្តីឯទៀតៗជាច្រើនដែលត្រូវនិយាយប្រាប់អ្នករាល់គ្នា តែអ្នករាល់គ្នាពុំអាចទទួលនៅពេលនេះបានទេ។ [១៣]កាល*
*ណាព្រះវិញ្ញាណនៃសេចក្តីពិតយាងមកដល់ព្រះអង្គនឹងណែនាំអ្នករាល់គ្នាឲ្យស្គាល់សេចក្តីពិតគ្រប់ជំពូកដ្បិតសេចក្តីផ្សេងៗ*
*ដែលព្រះអង្គថ្លែងមិនចេញមកពីព្រះអង្គផ្ទាល់ទេ គឺព្រះអង្គថ្លែងតែសេចក្តីណាដែលទ្រង់ព្រះសណ្តាប់ឮព្រមទាំងមានព្រះ*
*បន្ទូលប្រាប់ឲ្យអ្នករាល់គ្នាដឹងអំពីហេតុការណ៍ដែលត្រូវកើតមាននៅថ្ងៃមុខផង។ [១៤]ព្រះអង្គនឹងសម្តែងសិរីរុងរឿងរបស់ខ្ញុំ ព្រោះ*
*ព្រះអង្គទទួលសេចក្តីទាំងអស់ពីខ្ញុំយកមកប្រាប់អ្នករាល់គ្នា។ [១៥]អ្វីៗដែលព្រះបិតាមានទាំងប៉ុន្មាន សុទ្ធតែជារបស់ខ្ញុំទាំងអស់។*
*ហេតុនេះហើយបានជាខ្ញុំពោលថា ព្រះអង្គទទួលសេចក្តីទាំងអស់ពីខ្ញុំយកមកប្រាប់អ្នករាល់គ្នា»។*

-នៅពេលព្រះវិញ្ញាណយាងមកដល់ តើព្រះអង្គនឹងធ្វើអ្វីខ្លះ ?
-តាមបងប្អូនយល់ តើព្រះជាម្ចាស់ជានរណា ? តើព្រះត្រៃឯក ឬ ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធជានរណា ?
-តើអាថ៌កំបាំងរបស់ព្រះត្រៃឯកជួយពង្រឹងជំនឿរបស់បងប្អូនលើព្រះយេស៊ូយ៉ាងណា ?



*អត្ថបទផ្សេងទៀត៖*
*កណ ១៤:១៨-២០,*
*១ករ ១១:២៣-២៦,*
*ទន ១១០*



## ព្រះយេស៊ូប្រទាននំប៉័ងឲ្យមនុស្សប្រាំពាន់នាក់

*លក ៩:១១ខ-១៧*

*១១ព្រះយេស៊ូទទួលពួកគេ ហើយមានព្រះបន្ទូលអំពីព្រះរាជ្យ *របស់ព្រះជាម្ចាស់ ឲ្យគេស្ដាប់ព្រមទាំងប្រោសអ្នកជំងឺឲ្យបានជា*
*ផង។ ១២ដល់ថ្ងៃជិតលិច សាវ័កទាំងដប់ពីររូបចូលទៅទូលព្រះអង្គថា៖ «សូមព្រះអង្គប្រាប់ឲ្យបណ្ដាជនចេញទៅរកម្ហូបអាហារ*
*រកកន្លែងស្នាក់តាមផ្ទះ តាមភូមិជិតៗនេះទៅព្រោះទីនេះស្ងាត់ណាស់»។ ១៣ព្រះយេស៊ូមានព្រះបន្ទូលតបវិញថា៖ «ចូរអ្នករាល់*
*គ្នាយកម្ហូបអាហារឲ្យគេបរិភោគទៅ»។ ពួកសាវ័កទូលព្រះអង្គថា៖ «យើងខ្ញុំមាននំប៉័ងតែប្រាំដុំ និងត្រីងៀតពីរកន្ទុយប៉ុណ្ណោះ*
*ធ្វើម្ដេចនឹងគ្រាន់ មានតែទៅទិញអាហារសម្រាប់ប្រជាជនទាំងនេះ!»។ ១៤នៅទីនោះមានមនុស្សប្រុសប្រមាណប្រាំពាន់*
*នាក់។ ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់សាវ័កថា៖ «ចូរអ្នករាល់គ្នាប្រាប់គេឲ្យអង្គុយចុះជាក្រុមៗ ក្នុងមួយក្រុមហាសិបនាក់»។*
*១៥ពួកសាវ័កក៏ធ្វើតាម គឺប្រាប់គេឲ្យអង្គុយចុះទាំងអស់គ្នា។ ១៦ព្រះយេស៊ូយកនំប៉័ងទាំងប្រាំដុំ និងត្រីពីរកន្ទុយនោះ មកកាន់*
*ទ្រង់ងើបព្រះភ័ក្ត្រឡើងលើសរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់ប្រទានឲ្យសាវ័ក ដើម្បីឲ្យគេចែកបណ្ដាជនបរិភោគ។ ១៧គេ*
*បានបរិភោគឆ្អែតគ្រប់ៗគ្នា រួចប្រមូលនំប៉័ង ដែលនៅសល់បានពេញដប់ពីរល្អី។*

-ព្រះយេស៊ូមានព្រះបន្ទូលអំពីព្រះរាជ្យឲ្យបណ្ដាជនស្ដាប់ រួចហើយព្រះអង្គប្រទានអាហារដល់គេ តើការណ៍នេះបង្ហាញអ្វីអំពីព្រះយេស៊ូ អំពីព្រះជាម្ចាស់? តើការណ៍នេះជាគំរូយ៉ាងណាក្នុងការប្រកាសដំណឹងល្អរបស់ព្រះសហគមន៍នៅពេលសព្វថ្ងៃនេះ?

-តើនំប៉័ងជានិមិត្តរូបអំពីអ្វី? រំឭកអំពីអគ្គសញ្ញាអ្វី?

-បណ្ដាជនបរិភោគឆ្អែត តើមានអត្ថន័យយ៉ាងណាចំពោះបងប្អូននៅពេលសព្វថ្ងៃ?

### ថ្ងៃអាទិត្យទី១០ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃអាទិត្យទី៩ ខែមិថុនា ឆ្នាំ២០១៣

# ព្រះយេស៊ូប្រោសកូនប្រុសរបស់ស្ត្រីមេម៉ាយម្នាក់ឲ្យរស់ឡើងវិញ

*លូក ៧:១១-១៧*

*១១ក្រោយមកទៀត ព្រះយេស៊ូយាងឆ្ពោះទៅភូមិមួយឈ្មោះណាអ៊ីន។ សាវ័ករបស់ព្រះអង្គ និងបណ្ដាជនជាច្រើន ក៏ធ្វើដំណើរទៅ*
*ជាមួយព្រះអង្គដែរ។ ១២ពេលព្រះអង្គយាងមកជិតដល់ទ្វារកំពែងក្រុង មានគេដង្ហែសពយកទៅបញ្ចុះ។ បុគ្គលដែលស្លាប់នោះ*
*ជាកូនប្រុសតែមួយរបស់ស្ត្រីមេម៉ាយម្នាក់។ អ្នកស្រុកជាច្រើនបានមកជួយដង្ហែសពជាមួយគាត់។ ១៣កាលព្រះអម្ចាស់ឃើញស្ត្រី*
*មេម៉ាយនោះ ព្រះអង្គមានព្រះហឫទ័យអាណិតអាសូរគាត់យ៉ាងខ្លាំង។ ព្រះអង្គមានព្រះបន្ទូលទៅគាត់ថា៖ «សូមកុំយំអី!»។*
*១៤ព្រះអង្គយាងចូលទៅជិត ទ្រង់ពាល់មឈូស ពួកអ្នកសែងក៏នាំគ្នាឈប់។ ព្រះអង្គមានព្រះបន្ទូលថា៖ «អ្នកកំលោះអើយ! ចូរ*
*ក្រោកឡើង»។ ១៥រំពេចនោះបុគ្គលដែលស្លាប់ ក៏ក្រោកអង្គុយ ហើយចាប់ផ្ដើមនិយាយស្ដី។ ព្រះយេស៊ូប្រគល់អ្នកកំលោះទៅម្ដាយ*
*វិញ។ ១៦គេស្ញែងខ្លាចទាំងអស់គ្នា ហើយលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ដោយពោលថា៖ «មានព្យាការីដ៏ប្រសើរឧត្ដម*
*មួយរូបបានមកនៅក្នុងចំណោមយើង ហើយព្រះជាម្ចាស់យាងមករំដោះប្រជារាស្ត្ររបស់ព្រះអង្គ»។ ១៧ពាក្យដែលគេនិយាយ*
*អំពីព្រះយេស៊ូ បានលេចឮពាសពេញក្នុងស្រុកយូដា និងតំបន់ជិតខាងទាំងមូល។*

-ក្នុងអត្ថបទនេះមានពាក្យ "ក្រោកឡើងវិញ" "ក្រោកអង្គុយ" តើពាក្យទាំងនេះមានអត្ថន័យយ៉ាងណា?
-អ្នកដែលឃើញហេតុការណ៍ពោលកោតសរសើរព្រះជាម្ចាស់ ចុះបងប្អូនវិញ កោតសរសើរព្រះអង្គយ៉ាងដូចម្ដេចដែរ?
តើអត្ថបទនេះរំឭកអ្វីដល់បងប្អូន អំពីជំនឿលើព្រះយេស៊ូ?

*អត្ថបទផ្សេងទៀត៖*
*១ពង្សាវតារក្សត្រ ១៧:១៧-២៤,*
*កាឡាទី ១:១១-១៩,*
*ទំនុកតម្កើង ៣០*



*អត្ថបទផ្សេងទៀត៖*
*២សម ១២:៧-១០, ១៣,*
*កាឡ ២:១៦, ១៩-២១,*
*ទន ៣២*



## *ថ្ងៃអាទិត្យទី១១ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃអាទិត្យទី១៦ ខែមិថុនា ឆ្នាំ២០១៣*

# ព្រះ◌េយស៊ូលើកលែងទោសឲ្យស្ត្រីមានបាបម្នាក់

*លក ៧:៣៦-៥០*

*៣៦មានបុរសម្នាក់ខាងគណៈផារីស៊ី* បានយាងព្រះយេស៊ូទៅសោយព្រះស្ងោយ ព្រះអង្គក៏យាងទៅផ្ទះបុរសនោះ ហើយគង់*
*រួមតុជាមួយគាត់។ ៣៧នៅក្រុងនោះ មានស្ត្រីម្នាក់មានកេរ្តិ៍ឈ្មោះមិនល្អ។ ពេលឮថា ព្រះយេស៊ូគង់នៅក្នុងផ្ទះអ្នកខាងគណៈ*
*ផារីស៊ី*នោះ នាងយកដបថ្មកែវដាក់ប្រេងក្រអូបចូលមក។ ៣៨នាងនៅពីក្រោយព្រះយេស៊ូក្រាបទៀបព្រះបាទាព្រះអង្គ នាងយំ*
*សម្រក់ទឹកភ្នែកជោកព្រះបាទាព្រះយេស៊ូហើយយកសក់មកជូត។បន្ទាប់មកនាងថើបរួចយកប្រេងក្រអូបមកចាក់ពីលើផង។*
*៣៩ពេលបុរសម្ចាស់ផ្ទះឃើញដូច្នោះ គាត់រិះគិតក្នុងចិត្តថា៖ «បើលោកនេះពិតជាព្យាការី*មែន ច្បាស់ជាលោកជ្រាបថា ស្ត្រី ដែ*
*លពាល់លោកនេះជាស្ត្រីប្រភេទណាពុំខាន គឺនាងជាមនុស្សបាប»។ ៤០ព្រះយេស៊ូមានព្រះបន្ទូលទៅបុរសខាងគណៈផារីស៊ី*
*នោះថា៖ «លោកស៊ីម៉ូនខ្ញុំចង់និយាយរឿងមួយជាមួយលោក»។ លោកស៊ីម៉ូនទូលតបទៅព្រះអង្គថា៖ «សូមលោកគ្រូមាន*
*ប្រសាសន៍មកចុះ»។ ៤១ព្រះយេស៊ូមានព្រះបន្ទូលថា៖ «មានមនុស្សពីរនាក់ជំពាក់ប្រាក់គេ ម្នាក់ជំពាក់ប្រាំរយ ម្នាក់ទៀតហាសិប។*
*៤២ដោយអ្នកទាំងពីរគ្មានប្រាក់សងម្ចាស់ប្រាក់ ក៏លុបបំណុលចោល ឈប់ទារពីអ្នកទាំងពីរនោះទៅ។ ក្នុងចំណោមអ្នកទាំងពីរ តើ*
*អ្នកណាស្រឡាញ់ម្ចាស់បំណុលជាង ?»។ ៤៣លោកស៊ីម៉ូនទូលឆ្លើយថា៖ «តាមយោបល់ខ្ញុំ គឺអ្នកដែលជំពាក់ប្រាក់ច្រើនជាង»។*
*ព្រះយេស៊ូមានព្រះបន្ទូលទៅលោកស៊ីម៉ូនថា៖ «លោកមានយោបល់ត្រឹមត្រូវមែន»។ ៤៤បន្ទាប់មក ព្រះអង្គបែរទៅរកស្ត្រីនោះរួច*
*មានព្រះបន្ទូលទៅលោកស៊ីម៉ូនថា៖ «សូមមើលស្ត្រីនេះចុះ! ខ្ញុំបានចូលមកក្នុងផ្ទះលោក តែលោកពុំបានយកទឹកមកលាង*
*ជើងខ្ញុំទេ រីឯនាង នាងបានសម្រក់ទឹកភ្នែកជោកជើងខ្ញុំ ព្រមទាំងយកសក់នាងមកជូតទៀតផង។ ៤៥លោកមិនបានថើប ខ្ញុំទេ*
*រីឯនាងវិញតាំងពីខ្ញុំចូលមក នាងចេះតែថើបជើងខ្ញុំឥតឈប់ឈរសោះឡើយ។៤៦លោក មិនបានយកប្រេងមកលាបក្បាលខ្ញុំទេ*
*រីឯនាងវិញ នាងបានចាក់ប្រេងក្រអូបលាបជើងខ្ញុំ។ ៤៧ហេតុនេះហើយ ខ្ញុំសុំប្រាប់ឲ្យលោកដឹងថា នាងសម្តែងសេចក្តីស្រឡាញ់*
*ជាខ្លាំងយ៉ាងនេះ ព្រោះព្រះជាម្ចាស់បានប្រោសឲ្យនាងរួចពីបាបជាច្រើន។ រីឯអ្នកដែលព្រះជាម្ចាស់លើកលែងទោសឲ្យតិច*
*ក៏សម្តែងសេចក្តីស្រឡាញ់តិចដែរ»។៤៨ព្រះយេស៊ូមានព្រះបន្ទូលទៅស្ត្រីនោះថា៖«ខ្ញុំអត់ទោស ឲ្យនាងបានរួចពីបាបហើយ»។*
*៤៩អស់អ្នកដែលអង្គុយរួមតុជាមួយ រិះគិតក្នុងចិត្តរៀងៗខ្លួនថា៖ «តើលោកនេះមានឋានៈអ្វីបានជាហ៊ានអត់ទោសឲ្យមនុស្ស*
*រួចពីបាបដូច្នេះ ?»។ ៥០ព្រះយេស៊ូមានព្រះបន្ទូលទៅនាងទៀតថា៖ «ជំនឿរបស់នាងបានសង្គ្រោះនាងហើយ សូមអញ្ជើញទៅ*
*វិញ ដោយសុខសាន្តចុះ»។*

-ហេតុអ្វីស្ត្រីម្នាក់នោះស្រឡាញ់ព្រះយេស៊ូខ្លាំងដូច្នេះ ? តើបងប្អូនសព្វថ្ងៃមានចិត្តដូចនាងយ៉ាងណា ?
-តើស្ត្រីនោះទទួលការសង្គ្រោះដោយសារបុណ្យកុសលឬអ្វី ? តើអត្ថបទនេះមានអត្ថន័យយ៉ាងណាអំពីជំនឿក្នុងគ្រីស្តសាសនាយើង ? បងប្អូនចង់ទូលអ្វីខ្លះទៅព្រះយេស៊ូ ?

*ថ្ងៃអាទិត្យទី១២ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃអាទិត្យទី២៣ ខែមិថុនា ឆ្នាំ២០១៣*

# លោកសិលាប្រកាសថា ព្រះយេស៊ូជាព្រះគ្រីស្ត

*លូក ៩:១៨-២៤*

*១៨ថ្ងៃមួយ ពេលព្រះយេស៊ូនៅអធិដ្ឋាន *ដាច់ឡែកពីបណ្ដាជនពួកសាវ័ក *ក៏នៅជាមួយព្រះអង្គដែរ។ ព្រះអង្គមានព្រះបន្ទូលសួរ
គេថា៖ «តើមហាជនទាំងឡាយថាខ្ញុំជានរណា?»។ ១៩ពួកសាវ័កទូលឆ្លើយថា៖ «អ្នកខ្លះថាលោកគ្រូជាលោកយ៉ូហានបាទីស្ដ
អ្នកខ្លះថា លោកជាព្យាការីអេលី ហើយអ្នកខ្លះទៀតថា លោកជាព្យាការីមួយរូបពីសម័យបុរាណដែលរស់ឡើងវិញ»។ ២០ព្រះ
យេស៊ូសួរទៀតថា៖«ចុះអ្នករាល់គ្នាវិញតើអ្នករាល់គ្នាថាខ្ញុំជានរណាដែរ?»។លោកសិលាទូលព្រះអង្គថា៖«លោកជាព្រះគ្រីស្ដ *
ដែលព្រះជាម្ចាស់ចាត់ឲ្យមក»។ ២១ព្រះយេស៊ូក៏ហាមប្រាមគេមិនឲ្យនិយាយប្រាប់អ្នកណាជាដាច់ខាត។ ២២ព្រះអង្គមាន
ព្រះបន្ទូលទៀតថា៖ «បុត្រមនុស្ស *ត្រូវរងទុក្ខវេទនាយ៉ាងខ្លាំង។ ពួកព្រឹទ្ធាចារ្យ * ពួកនាយកបូជាចារ្យ * ពួកធម្មាចារ្យ *នឹង
បោះបង់លោកចោល ថែមទាំងសម្លាប់លោកទៀតផង។ ប៉ុន្តែបីថ្ងៃក្រោយមក លោកនឹងរស់ឡើងវិញ»។ ២៣បន្ទាប់មក ព្រះយេស៊ូ
មានព្រះបន្ទូលទៅគេទាំងអស់គ្នាថា៖ «បើអ្នកណាចង់មកតាមក្រោយខ្ញុំ ត្រូវលះបង់ខ្លួនឯងចោល ត្រូវលីឈើឆ្កាងរបស់ខ្លួនរៀង
រាល់ថ្ងៃ ហើយមកតាមខ្ញុំចុះ ២៤ដ្បិតអ្នកណាចង់បានរួចជីវិត អ្នកនោះនឹងបាត់បង់ជីវិតពុំខាន ប៉ុន្តែអ្នកណាបាត់បង់ជីវិតព្រោះ
តែខ្ញុំ អ្នកនោះនឹងបានរួចជីវិតវិញ។*

-ចម្លើយរបស់សន្តៈសិលាទូលទៅព្រះយេស៊ូ គឺជាជំនឿរបស់ព្រះសហគន៍យើង។ តើជំនឿនេះមានអត្ថន័យយ៉ាងដូចម្ដេច សូមបងប្អូនរិះគិត?

-តើព្រះយេស៊ូមានព្រះបន្ទូលអំពីទុក្ខលំបាករបស់បុត្រមនុស្សយ៉ាងណា? អំពីអ្នកដែលចង់ទៅតាមក្រោយព្រះអង្គយ៉ាងណា? តើបងប្អូនរស់នៅតាមព្រះបន្ទូលនេះយ៉ាងណាដែរសព្វថ្ងៃ? បងប្អូនមានអ្វីចង់ទូលទៅព្រះយេស៊ូឬទេ?

*អត្ថបទផ្សេងទៀត៖*
*សក ១២:១០-១១, ១៣:១,*
*កាឡ ៣:២៦-២៩,*
*ទន ៦៣*



*ថ្ងៃអាទិត្យទី១៣ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃអាទិត្យទី៣០ ខែមិថុនា ឆ្នាំ២០១៣*

## ព្រះយេស៊ូយាងកាត់ភូមិសាសន៍សាម៉ារី

*អត្ថបទផ្សេងទៀត៖*
*១ពង្ស ១៩:១៦ខ,*
*១៩-២១,*
*កាឡ ៥:១, ១៣-១៨,*
*ទន ១៦*



*លក ៩:៥១-៦២*
៥១ លុះជិតដល់ថ្ងៃកំណត់ ដែលព្រះយេស៊ូត្រូវយាងចាកចេញពីលោកនេះទៅ ព្រះអង្គសម្រេចព្រះហឫទ័យយាងទៅក្រុង
យេរូសាឡឹម ៥២ ព្រះអង្គបានចាត់អ្នកខ្លះឲ្យទៅមុន។ អ្នកទាំងនោះ ចេញដំណើរទៅដល់ភូមិមួយរបស់អ្នកស្រុកសាម៉ារី ដើម្បី
រៀបចំកន្លែងថ្វាយព្រះអង្គ។ ៥៣ ប៉ុន្តែអ្នកស្រុកពុំព្រមទទួលព្រះអង្គឲ្យស្នាក់ឡើយ ព្រោះព្រះអង្គយាងឆ្ពោះទៅក្រុងយេរូសាឡឹម។
៥៤ សាវ័កយ៉ាកុប និងយ៉ូហានឃើញដូច្នោះក៏ទូលព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់! តើព្រះអង្គសព្វព្រះហឫទ័យឲ្យយើងខ្ញុំ
ហៅរន្ទះភ្លើងមកកម្ទេចអ្នកទាំងនេះឬ?»។ ៥៥ ព្រះយេស៊ូបែរទៅរកគេ ហើយស្ដីបន្ទោសគេយ៉ាងខ្លាំង។ ៥៦ បន្ទាប់មកព្រះអង្គ
យាងឆ្ពោះទៅកាន់ភូមិមួយផ្សេងទៀតជាមួយសាវ័ក*។ ៥៧ កាលព្រះយេស៊ូកំពុងយាងតាមផ្លូវជាមួយសាវ័ក មានបុរសម្នាក់ទូល
ព្រះអង្គថា៖ «ខ្ញុំប្របាទសុខចិត្តទៅតាមលោក ទោះបីលោកអញ្ជើញទៅទីណាក៏ដោយ»។ ៥៨ ព្រះយេស៊ូមានព្រះបន្ទូលតបទៅ
គាត់វិញថា៖ «សត្វកញ្ជ្រោងមានរូងរបស់វា បក្សាបក្សីក៏មានសំបុករបស់វាដែរ ប៉ុន្តែបុត្រមនុស្ស*គ្មានទីជម្រកសម្រាកសោះ
ឡើយ»។ ៥៩ ព្រះអង្គមានព្រះបន្ទូលទៅម្នាក់ទៀតថា៖ «សុំអញ្ជើញមកតាមខ្ញុំ»។ ប៉ុន្តែអ្នកនោះទូលព្រះអង្គថា៖ «សូមលោក
មេត្តាអនុញ្ញាតឲ្យខ្ញុំប្របាទទៅបញ្ចុះសពឪពុកសិន»។ ៦០ ព្រះយេស៊ូមានព្រះបន្ទូលតបទៅគាត់វិញថា៖ «ទុកឲ្យមនុស្សស្លាប់
បញ្ចុះសពគ្នាគេចុះ។ រីឯអ្នកវិញ ចូរទៅផ្សាយដំណឹងអំពីព្រះរាជ្យ*របស់ព្រះជាម្ចាស់»។ ៦១ មានម្នាក់ទៀតទូលព្រះអង្គថា៖
«លោកម្ចាស់! ខ្ញុំប្របាទសុខចិត្តទៅតាមលោកដែរ ប៉ុន្តែសូមអនុញ្ញាតឲ្យខ្ញុំប្របាទទៅជម្រាបលាក្រុមគ្រួសារសិន»។ ៦២ ព្រះ
យេស៊ូមានព្រះបន្ទូលទៅគាត់វិញថា៖ «អ្នកណាកាន់នង្គ័ល ហើយបែរជាងាកមើលក្រោយ អ្នកនោះគ្មានសារប្រយោជន៍អ្វីដល់
ព្រះរាជ្យ*របស់ព្រះជាម្ចាស់ឡើយ»។

-តើព្រះយេស៊ូមានព្រះហឫទ័យយ៉ាងណាចំពោះអ្នកដែលជំទាស់នឹងព្រះអង្គ? ចុះបងប្អូនវិញរស់នៅយ៉ាងណាដែរតាមព្រះបន្ទូលនេះ?

-ព្រះយេស៊ូមានព្រះបន្ទូលថា ព្រះអង្គគ្មានទីជម្រកទេ។ តើឃ្លានេះមានអត្ថន័យយ៉ាងណាដែរ ចំពោះការរស់នៅរបស់បងប្អូនដែលជាអ្នកដើរតាមព្រះអង្គ?

# មរណសាក្សី
# នៅប្រទេសកម្ពុជា

ក្នុងប្រវត្តិព្រះសហគមន៍ទូទាំងពិភពលោក មានគ្រីស្ទបរិស័ទជាច្រើនរូបសុខចិត្តប្ដូជាជីវិតព្រោះតែជំនឿរបស់ខ្លួន។ នៅប្រទេសកម្ពុជា នាងរស្មីជាគ្រីស្ទបរិស័ទម្នាក់ ដែលសុខចិត្តប្ដូជាជីវិតព្រោះតែជំនឿរបស់នាងដែរ។

# នាងស្ទើជាមរណសាក្សី

«មានក្មេងស្រីម្នាក់អាយុប្រហែល ១៨ឆ្នាំ ជាទាសកររបស់គ្រីស្តបរិស័ទម្នាក់។ ម្ចាស់នាងអញ្ជើញនាងឲ្យទទួលអគ្គសញ្ញាជ្រមុជទឹក និងទៅជាគ្រីស្តបរិស័ទ។ តែក្រោយពេលម្ចាស់របស់នាងទទួលមរណៈភាពអស់ទៅ នាងក៏ធ្លាក់ទៅក្នុងកណ្តាប់ដៃអ្នកទទួលមត៌កដែលមានចិត្តកាចសាហាវ។ បុរសនោះយកនាងទៅលក់ឲ្យជនដែលគ្មានមេត្តា ទោះបីនាងអង្វរសុំឲ្យលក់នាងទៅគ្រីស្តបរិស័ទយ៉ាងណាក្តី ក៏បុរសនោះពុំព្រមដែរ។ ម្ចាស់ថ្មីគ្មានមេត្តានោះ បង្ខំឲ្យនាងធ្វើតាមជំនឿរបស់គេ ប៉ុន្តែនាងប្រកែកជានិច្ច មិនព្រមធ្វើតាមទេ។ ជននោះធ្វើទុក្ខបុកម្នេញគ្រប់បែបយ៉ាង បង្ខំនាងឲ្យធ្វើតាម តែពុំបានសម្រេចដូចបំណងឡើយ។ ដោយឈឺចិត្តព្រោះពុំអាចឈ្នះទាសកររបស់ខ្លួនបាន បុរសនោះក៏ប្រគល់នាងឲ្យទៅមិត្តភក្តិរបស់ខ្លួនម្នាក់ទៀត ដែលជាមនុស្សមានចិត្តឃោរឃៅដូចគ្នា។ បុរសក្រោយនេះ ក្រេវក្រោធយ៉ាងខ្លាំងវាយដំច្រំធាក់នាងជាទម្ងន់រហូតដល់នាងស្លាប់។ នាងស្លាប់ព្រោះតែជំនឿលើព្រះអម្ចាស់។ ដោយឃើញទឹកចិត្តឥតប្រែប្រួលរបស់នាងរស្មីចំពោះព្រះយេស៊ូគ្រីស្តយ៉ាងខ្លាំងដូច្នេះ គ្រីស្តបរិស័ទឯទៀតៗមានចិត្តរំភើបគោរពកោតសរសើរដល់នាងជាខ្លាំង ហើយគេនាំយកសពនាងទៅធ្វើបុណ្យយ៉ាងអធិកអធមទៅតាមលទ្ធភាពរបស់ពួកគេ»។







# សក្ខីភាពផ្សេងៗនៅក្នុងសម័យប៉ុលពត

ក្នុងពេលប៉ុលពតកាន់អំណាច ៣ឆ្នាំ ៨ខែ ២០ថ្ងៃ គឺពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ ប្រជាជនកម្ពុជារាប់លាននាក់ត្រូវគេសម្លាប់។ ក្នុងកាលៈទេសៈដ៏លំបាកនេះ មានគ្រីស្តបរិស័ទខ្លះ បោះបង់ជំនឿរបស់ខ្លួន តែផ្ទុយទៅវិញ បងប្អូនខ្លះទៀតមានជំនឿកាន់តែរឹងមាំឡើងៗ។



### គេចាប់គ្រីស្តបរិស័ទយើងមួយចំនួន

«ពួកខ្មែរក្រហមចូលក្នុងផ្ទះខ្ញុំ គេនិយាយទៅកាន់ឪពុកខ្ញុំថា៖

-មិត្តឯងកាន់សាសនាកាតូលិកមែនទេ ?

-មែន ខ្ញុំកាន់សាសនាកាតូលិកមែន។

-មិត្តឯងកាន់សាសនាតាមជនជាតិបារាំងឬ ?

-ទេ! ព្រះយេស៊ូមិនមែនជាជនជាតិបារាំងទេ។ ព្រះអង្គយាងមកពីព្រះជាម្ចាស់ដើម្បីសង្គ្រោះមនុស្សទូទាំងពិភពលោក។

-មិត្តឯងនិយាយបានល្អណាស់ សូមមកតាមយើង ហើយចាំមើលថាតើព្រះយេស៊ូនោះសង្គ្រោះឯងយ៉ាងណា ?

ពួកខ្មែរក្រហមនាំឪពុកខ្ញុំ និងបងស្រីខ្ញុំពីរនាក់ដែលមានអាយុ ១៨ និង ១៩ឆ្នាំចេញទៅ។ យើងលែងបានឃើញមុខពួកគាត់ចាប់ពីពេលនោះរហូតមក។ »

### នាងម្នាក់រៀបរាប់ថា៖

«រាត្រីថ្ងៃបុណ្យណូអែលឆ្នាំ១៩៧៥ នាងខ្ញុំនឹកដល់ព្រះយេស៊ូយ៉ាងខ្លាំង ហើយអធិដ្ឋានទាំងយំផង។ ក្រោយអធិដ្ឋានរួច

នាងខ្ញុំហាក់ដូចជាសប្បាយក្នុងចិត្តយ៉ាងខ្លាំង ហើយរិះគិតអំពីទុក្ខលំបាករបស់ខ្លួន ដែលរួមជាមួយនឹងទុក្ខលំបាករបស់ព្រះយេស៊ូ។ ពេលនោះ នាងខ្ញុំហាក់ដូចជាមានកម្លាំងជាថ្មីឡើងវិញ។ ព្រះវិញ្ញាណផ្ដល់កម្លាំងឲ្យនាងខ្ញុំ និងឲ្យនាងខ្ញុំនឹកសង្ឃឹមជានិច្ច។ ពេលខ្លះកាប់ដីបណ្ដើរ នាងខ្ញុំអធិដ្ឋានបណ្ដើរថា៖ «ឱព្រះបិតាអើយ! កូនសូមអរព្រះគុណព្រះអង្គដែលប្រទានកម្លាំងមកកូន ព្រះអង្គពិតជាឈ្វេងយល់អំពីការងារដែលកូនធ្វើ និងពីទុក្ខលំបាកទាំងប៉ុន្មានដែលកូនបានទទួលអស់ហើយ! កូនវេទនាណាស់។»





**ស្ត្រីគ្រីស្តបរិស័ទម្នាក់ទៀតក៏រៀបរាប់ដែរថា៖**

«កាលដែលមិនទាន់វេទនា ដូចជាមិនសូវជឿប៉ុន្មានទេ ដូចជាមិនចាប់អារម្មណ៍ប៉ុន្មានទេ ជឿតាមតែគេទៅ។ ដល់រងទុក្ខវេទនា ជំនឿប្រែជារឹងមាំ ចាក់ឫសចូលទៅខាងក្នុងយ៉ាងជ្រៅមិនអាចរលំបានឡើយ ខ្ញុំសង្ឃឹមទ្វេឡើងថែមទៀត។ វេទនាអញ្ចឹង ខ្ញុំមិនដែលដាក់ទោសព្រះជាម្ចាស់ទេ គឺដាក់ទោសលើអ្នកកាន់កាប់ប្រទេសដែលប្រព្រឹត្តអំពើពុករលួយ បានជានគរត្រូវតោកយ៉ាកវេទនាដល់ថ្នាក់ដូច្នេះ។ ខ្ញុំនឹកថា យើងពិតជាបុត្រធីតាដ៏ជាទីស្រឡាញ់របស់ព្រះបិតា ព្រោះព្រះអង្គប្រោសប្រទានឲ្យយើងរងទុក្ខវេទនាដូចព្រះបុត្រារបស់ព្រះអង្គដែរ។»

«ក្នុងសម័យនោះយើងគ្មានគម្ពីរសម្រាប់អានទេ តែខ្ញុំនៅចាំព្រះបន្ទូលខ្លះៗដូចជា៖ ខ្ញុំជាប្រភពនៃជីវិត ខ្ញុំជាពន្លឺបំភ្លឺមនុស្សលោក។ ខ្ញុំចងចាំជានិច្ចថា ព្រះយេស៊ូជាជីវិត ជាពន្លឺ ទោះបីពេលនេះខ្ញុំរងទុក្ខវេទនាយ៉ាងណាក៏ដោយ ក៏ព្រះអង្គពិតជាជីវិត និងជាពន្លឺសម្រាប់ខ្ញុំពិតប្រាកដមែន។ អ្នកណារងទុក្ខវេទនា អ្នកនោះពិតជាមានសុភមង្គល។ អ្នកណាស្រេកឃ្លាន អ្នកនោះពិតជាមានសុភមង្គល។»

«ខ្មែរក្រហមបានកម្ទេចព្រះវិហារយើងចោលស្ទើរគ្រប់ទីកន្លែង ហើយគេយកកន្លែងនោះដាំចេក ដាំល្ពៅ។ល។ ទោះយ៉ាងណាក៏ដោយ ក៏គេមិនអាចកម្ទេចជំនឿយើងបានឡើយ។ យើងមានជំនឿកាន់តែមាំមួន។ យើងសង្ឃឹមលើព្រះជាម្ចាស់ជានិច្ច។ ម្នាក់ៗធ្វើពិធីបុណ្យទាំងឡាយក្នុងជម្រៅចិត្តរបស់ខ្លួន ក្នុងកាលៈទេសៈដ៏សែនឈឺចាប់បំផុតនេះ។»











ឆ្នាំ នៃ ជំនឿ ២០១២
២០១៣

**MGR OLIVIER SCHMITTHAEUSLER**
APOSTOLIC VICAR OF PHNOM PENH - CAMBODIA
BISHOP’S RESIDENCE
PO BOX 123 - ROUNG CHAK VILLAGE,
SANGKAT PHNOM PENH THMEY, KHAN SEN SOK
PHNOM PENH CITY - KINGDOM OF CAMBODIA
FAX +855 23 218 431 - TEL +855 23 212 462
Email: apostolicvicariate.phnompenh@gmail.com